ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ប្រធានបទ៖ ទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ នៅក្នុងរាជធានីភ្នំពេញ

# "Stakeholder Perspectives on Declining Student Enrollment in High Schools in Phnom Penh"

ដោយ/By

ហេង ស្រៀន/HENG SRIEN

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# ប្រធានបទ៖ ទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ នៅក្នុងរាជធានីភ្នំពេញ

# "Stakeholder Perspectives on Declining Student Enrollment in High Schools in Phnom Penh"

ដោយ/By

ហេង ស្រៀន/HENG SRIEN

ឯកទេស៖ គ្រប់គ្រងអប់រំ

គ្រូដឹកនាំបន្ទោល៖ លោក លឹម វ៉ាន់

គ្រូដឹកនាំរង៖ បណ្ឌិត នី រដ្ឋា

ឆ្នាំសិក្សា២០២០-២០២២

# សេចក្ដីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ឧស្សាហ៍ៈរបស់នាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ នៅក្នុងរាជធានីភ្នំពេញ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទពិតប្រាកដមែន។ ហើយកន្លងមក ក៏ពុំទាន់មានករណីសិក្សាលើប្រធានបទនេះនៅឡើយទេ។ ទ្រឹស្ដី និងខ្លឹមសារដែលខ្ញុំបានដកស្រង់ ដើម្បីដាក់ជាឯកសារយោង និងបោះពុម្ពជាសាធារណៈ ខ្ញុំបាទបានប្រាប់ពីប្រភព អ្នកនិពន្ធ និងឆ្នាំបោះពុម្ពបានច្បាស់លាស់ដើម្បីធ្វើយ៉ាងណាឱ្យស្នាដៃនៃនិក្ខេបបទរបស់ខ្ញុំបាទមានតម្លៃ គុណភាព និងត្រូវបានទទួលស្គាល់ពីគណៈកម្មការវាយតម្លៃ។

ថ្ងៃអាទិត្យ ១៣កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**

**ហេង ស្រៀន**

# លិខិតបញ្ជាក់

លោក **លឹម វ៉ាន់** ជាគ្រូណែនាំគោល

បណ្ឌិត **នី រដ្ឋា** ជាគ្រូណែនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ហោង ស្រៀន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបាន សរសេរនិក្ខេបបទស្រាវជ្រាវស្តីពី«**ទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ នៅក្នុងរាជធានីភ្នំពេញ**» ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០២២



.....................................

**លឹម វ៉ាន់**



.....................................

**បណ្ឌិត នី រដ្ឋា**

# លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៧០២៥...អយក.ខុកក

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ឧទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ឧទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ឧទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ឧទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នួវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វង្សា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនីទ្ធ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧រោច ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួលៈ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ ដែអ

# លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: [illegible] អយក.ទុទន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គីមឡុង | សាកលវិទ្យាភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ីងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ វ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុតា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ធី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ផាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វេជអ

# លិខិតថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមសូមសំដែងនូវការគោរពដឹងគុណប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះ លោកឪពុក **ហាច់ ស៊្មើន** និងអ្នកម្តាយ **ហ៊ុន ទ្រី** ដែលបានផ្តល់កំណើត លះបង់កម្លាំងកាយកម្លាំងចិត្ត និងធនធានដើម្បីចិញ្ចឹមបីបាច់ថែរក្សា និងអប់រំរូបខ្ញុំបាទរហូតដល់មានអ្វីៗសព្វយ៉ាងដូចសព្វថ្ងៃនេះ។

សូមគោរពថ្លែងអំណាគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ ដែលមានគំនិតផ្តួចផ្តើមបើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនេះឡើង ដើម្បីពង្រឹងគុណភាព និងគុណវុឌ្ឍិរបស់គ្រូបង្រៀនឱ្យស្របតាមស្តង់ដារអាស៊ាន។

សូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **លឹម ខ៊ាន់** និង **លោកបណ្ឌិត នី រដ្ឋា** ជាគ្រូដឹកនាំបង្គោល និងដឹកនាំរង ។កន្លងមកលោកទាំងពីរបានយកចិត្តទុកដាក់ផ្តល់យោបល់និងធ្វើការណែនាំដល់រូបខ្ញុំបាទ នូវមតិល្អៗពីរបៀបរៀបចំកម្រងសំណួរ ការជ្រើសរើសសំណាកដើម្បីឱ្យបំពេញកម្រងសំណួរ ជាពិសេសជម្រុញឱ្យខ្ញុំបាទប្រឹងប្រែងជម្នះឧបសគ្គដើម្បីសម្រេចបាននូវការបញ្ចប់នៃការសរសេរនិក្ខេបបទប្រកបដោយគុណភាពខ្ពស់។ សូមថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាលសិស្សនៅតាមសាលាគោលដៅទាំង ០៦ដែលបានអនុញ្ញាតិ និងចូលរួមសហការណ៍ក្នុងអំឡុងពេលដំណើរការប្រមូលទិន្នន័យរហូតការស្រាវជ្រាវរបស់ខ្ញុំបាទរហូតសម្រេចបានលទ្ធផលជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរដ៏បវរមហាប្រសើរជូនចំពោះឯកឧត្តមបណ្ឌិត លោក លោកស្រីសាស្ត្រាចារ្យ ភរិយា កូន និងមិត្តភក្តិទាំងអស់ឱ្យទទួលបាននូវសុខភាពល្អ សុភមង្គល និងជាគជ័យគ្រប់ភារកិច្ចព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មូលន័យសង្ខេប

ការបោះបង់ការសិក្សាជាកង្វល់រួមរបស់អ្នកអប់រំ អ្នកធ្វើគោលនយោបាយ ភាគីពាក់ព័ន្ធក្នុងវិស័យអប់រំ មន្ត្រីអប់រំទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់មូលដ្ឋាន និងមាតាបិតាសិស្ស។ បើយោងតាមសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា(២០២២)បានបង្ហាញថាអត្រាបោះបង់ការសិក្សាមធ្យមសិក្សាបឋមភូមិមានការថយចុះ១,៦% តែសម្រាប់មធ្យមសិក្សាទុតិភូមិវិញ អត្រាបោះបង់ការសិក្សាមានការកើនឡើងទៅវិញដោយកើនរហូតដល់ ៩,៨០%។ មានពាក្យគន្លឹះមួយចំនួនដែលត្រូវបង្ហាញដោយមានដូចតទៅ៖សាលាមធ្យមសិក្សាទុតិយភូមិជាសាលាសម្រាប់សិស្សដែលមានអាយុចាប់ពី ១៥/១៦រហូតដល់១៨/១៩ឆ្នាំដែលការសិក្សាផ្តល់ឱ្យមានការរីកចំរើនគ្រប់ផ្នែក។តាម Nafla (2016)បានកំណត់ថា ភាគីពាក់ព័ន្ធក្នុងសាលារៀនមាន៖ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាលសិស្ស ដែលគណៈគ្រប់គ្រងបានជ្រើសរើសយកកម្រិតទុតិយភូមិ គ្រូកំពុងបង្រៀននៅកម្រិតទី១០ ១១ និង ១២ ចំណែកសិស្សយកអ្នកកំពុងរៀននៅថ្នាក់ទី១០ ១១ និង១២ ហើយមាតាបិតាយកអ្នកដែលមានកូនកំពុងរៀននៅថ្នាក់ទី១០ ១១ និង១២ ផងដែរ។

ដោយមើលឃើញបែបនេះ ក្នុងនាមជាអ្នកស្រាវជ្រាវក៏សម្រេចលើកយកបញ្ហានេះមកសិក្សាស្រាវជ្រាវក្រោមប្រធានបទ៖«ទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ នៅក្នុងរាជធានីភ្នំពេញ»។ ការសិក្សានេះធ្វើឡើងដើម្បីរកឱ្យឃើញនូវបញ្ហាប្រឈម និងកត្តាផ្សេងៗដែលនាំឱ្យសិស្សថយចុះនៅតាមសាលាទាំងនោះ នៅក្នុងរាជធានីភ្នំពេញ និងឈ្វេងយល់ពីទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ និងសាលាដែលមានសិស្សចេះតែកើនឡើង ដោយភាគីពាក់ព័ន្ធរួមមាន៖ គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាល។វិធីសាស្ត្រនៃការសិក្សានេះធ្វើតាមបែបបរិមាណវិស័យ និងគុណវិស័យដែលមានអ្នកចូលរួមឆ្លើយជា៖ គណៈគ្រប់គ្រងសាលារៀនចំនួន ០៦នាក់ លោកគ្រូអ្នកគ្រូកំពុងបង្រៀនកម្រិតវិទ្យាល័យចំនួន ៣០នាក់ សិស្សានុសិស្ស

ដែលកំពុងរៀនថ្នាក់ទី ១០ ១១ និងថ្នាក់ទី១២ចំនួន ១៦០នាក់ និងមាតាបិតា ឬអាណាព្យាបាលចំនួន ៥២នាក់ សរុបទាំងអស់មានចំនួន១៤៨នាក់ដែលបានចូលរួមបំពេញកម្រងសំនួរ។ បន្ទាប់មកចំលើយនេស់ភាគសំណាកត្រូវបានយកទៅវិភាគតាមកម្មវិធី **SPSS** ដើម្បីរកតំលៃមធ្យម និងគម្លាតស្តង់ដារ ( Means & Standard Deviation ) ។

ទាក់ទង និងការវិភាគពីបញ្ហាប្រឈម អ្នកស្រាវជ្រាវរកឃើញថា៖ បញ្ហានៅតាមកម្រិតបង្ហាញនៅមានកម្រិតទាបដែលអាចគ្រប់គ្រងបានដោយមាន( M= 2.10) ។ និងអាចឱ្យសាលាទាំងនោះដឹងពីកង្វះខាត និងអ្វីដែលត្រូវបំពេញបន្ថែមដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់សិស្ស និងឱ្យសហគមន៍មានទំនុកចិត្តលើសាលាឡើងវិញ ព្រមទាំងបញ្ជូនកូនឱ្យមករៀន និងចូលរួមក្នុងការអភិវឌ្ឍសាលារៀនទាំងនោះបន្តទៀត។

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** ........ i
**លិខិតបញ្ជាក់** ........ ii
**លិខិតឧទ្ទេសនាមគណ:កម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ iii
**លិខិតថ្លែងអំណរគុណ** ........ iv
**មូលន័យសង្ខេប** ........ vi
**បញ្ជីតារាង** ........ xi
**ជំពូកទី១៖ សេចក្តីផ្តើម** ........ 1
១.១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1
១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 5
១.៣.គោលបំណងនៃការស្រាវជ្រាវ ........ 7
១.៤. សំណួរស្រាវជ្រាវ ........ 7
១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ 8
១.៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 8
**ជំពូកទី២៖ ការរំលឹកទ្រឹស្តី** ........ 10
២.១. និយមន័យ ........ 10
២.២ ភាគីពាក់ព័ន្ធ ........ 11
២.២.១ នាយកសាលាល្អ ........ 11
២.២.២ គ្រូបង្រៀនល្អ ........ 13
២.២.៣ សាលារៀនស្អាត ........ 15
២.២.៤ អ្នកសិក្សាល្អ ........ 18
២.២.៥ អាណាព្យាបាល ឫមាតាបិតាសិស្ស ........ 18
២.២.៦ ភូមិ ឃុំមានសុវត្ថិភាព ........ 19
២.៣ ប្រវត្តិនៃការសិក្សានៅកម្រិតទុតិយភូមិ ........ 20

២.៣.១ ការអប់រំកម្រិតទុតិយភូមិក្រោយសម័យប៉ុលពត ដល់ឆ្នាំ ១៩៩៥ ...... 21
២.៣.២ ការអប់រំកម្រិតទុតិយភូមិសម័យបច្ចុប្បន្ន ...... 21
២.៤ លទ្ធផលសិក្សា និងបញ្ហាប្រឈមនៅកម្រិតទុតិយភូមិ ...... 22
២.៤.១ ការជ្រើសរើសសាលារៀន ...... 22
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ...... 25
៣.១. សេចក្តីផ្តើម ...... 25
៣.១.២. ដែនកំណត់នៃការស្រាវជ្រាវ ...... 25
៣.២. វិធីសាស្ត្រស្រាវជ្រាវ និងឧបករណ៍ប្រមូលទិន្នន័យ ...... 26
៣.២.១. វិធីសាស្ត្រប្រមូលទិន្នន័យ ...... 26
៣.២.២ ឧបករណ៍ប្រមូលទិន្នន័យ ...... 27
៣.៣.កម្រងសំណួរ ...... 27
៣.៤ ភាគសំណាក ...... 29
៣.៤.១. ការសាកល្បងកម្រងសំណួរ ...... 30
៣.៤.២.ក្រមសីលធម៌នៃការស្រាវជ្រាវ ...... 31
**ជំពូកទី៤៖ លទ្ធផលនិងការពិភាក្សា** ...... 33
៤.១.សេចក្តីផ្តើម ...... 33
៤.១.១ លទ្ធផលនៃការវិភាគទិន្នន័យផ្នែកទី១ ...... 33
**ជំពូកទី៥៖** ...... 79
សេចក្តីសន្និដ្ឋាន និងសំណូមពរ ...... 79
៥.១ សេចក្តីសន្និដ្ឋាន ...... 80
៥.២ អនុសាសន៍ និងសំណូមពរ ...... 81
**ឯកសារយោង** ...... 84
**ឧបសម្ព័ន្ធ (១)កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា** ...... 89
**ឧបសម្ព័ន្ធ (២) កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ** ...... 94
**ឧបសម្ព័ន្ធ (៣) កម្រងសំណួរសម្រាប់សិស្ស** ...... 101

**ឧបសម្ព័ន្ធ (៤) កម្រងសំណួរសំរាប់មាតាបិតា ឬអាណាព្យាបាល**............................107
**ឧបសម្ព័ន្ធ(៥)៖ លទ្ធផលវិភាគក្នុងកម្មវិធី** SPSS...................................................112
**ឧបសម្ព័ន្ធ (៦)៖ លិខិតឧទ្ទេសនាមពីមន្ទីរអប់រំ សម្រាប់ការចុះប្រមូលទិន្នន័យ** .......130
**ឧបសម្ព័ន្ធ (៧)៖ លិខិតឧទ្ទេសនាមគ្រូណែនាំគោល និងគ្រូណែនាំរង**......................132
**ឧបសម្ព័ន្ធ (៨)៖ លិខិតឧទ្ទេសគណៈកម្មការមេប្រយោគ** ..........................................135
**ឧបសម្ព័ន្ធ (៩)៖ លិខិតបញ្ជាប់ការ**.........................................................................137

# បញ្ជីតារាង

តារាង 1 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើទស្សនៈរបស់ភាគីពាក់ព័ន្ធចំពោះសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកាន់តែកើនឡើង តាមទស្សនៈរបស់ភាគីពាក់ព័ន្ធ តាមចំណុចនិមួយៗ (n= ២៤៧) ....................34
តារាង 2 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងអត្ថន័យលើការរៀបចំបរិស្ថានសាលារៀនតាមទស្សនៈរបស់ .37
តារាង 3 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងអត្ថន័យលើការរៀបចំបរិស្ថានសាលារៀន តាមទស្សនៈរបស់គ្រូ 39
តារាង 4 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងអត្ថន័យ លើការរៀបចំបរិស្ថានសាលារៀន តាមទស្សនៈរបស់សិស្ស ....................40
តារាង 5 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការរៀបចំបរិស្ថានសាលារៀន តាមទស្សនៈរបស់មាតាបិតា ឬអាណាព្យាបាល....................41
តារាង 6 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញសរុបតាមទស្សនៈភាគីទាំង ៤.............42
តារាង 7 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងបុគ្គលិក តាម .............43
តារាង 8 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ ការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់លោកគ្រូ អ្នកគ្រូ ....................44
តារាង 9 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់សិស្ស....................46
តារាង 10 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់មាតាបិតា ឬអាណាព្យាបាលលើ....................47
តារាង 11 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់ភាគីទាំង៤....................48
តារាង 12 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់គណៈគ្រប់គ្រង....................49
តារាង 13 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់គ្រូ ....................50
តារាង 14 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់សិស្ស....................51

តារាង 15 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់មាតាបិតា ឬអាណាព្យាបាល ....................................................................................................52
តារាង 16 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ....................................................................................................53
តារាង 17 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការគ្រប់គ្រងការរៀន និងបង្រៀន តាមទស្សនៈរបស់គណៈគ្រប់គ្រង ....................................................................................................54
តារាង 18 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការគ្រប់គ្រងការរៀន និងបង្រៀន តាមទស្សនៈរបស់គ្រូ ....................................................................................................56
តារាង 19 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងការរៀន និងបង្រៀនតាមទស្សនៈរបស់សិស្ស ....................................................................................................58
តារាង 20 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងការរៀន និងបង្រៀន តាមទស្សនៈរបស់មាតាបិតា ឬអាណាព្យាបាល....................................................................................................59
តារាង 21 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងការរៀន និងបង្រៀន តាមទស្សនៈរបស់គ្រប់ភាគី....................................................................................................61
តារាង 22 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញចំពោះបញ្ហាប្រឈម និងកត្តាផ្សេងៗដែលធ្វើឱ្យចំនួនសិស្សកាន់តែថយចុះ របស់ភាគីពាក់ព័ន្ធ លើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកាន់តែកើនឡើង តាមចំណុចនិមួយៗ ( n= ២៤៧ )....................................................................................................62
តារាង 23 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើបញ្ហាប្រឈមរបស់គណៈគ្រប់គ្រងសាលារៀន ....................................................................................................64
តារាង 24៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើបញ្ហាប្រឈមរបស់គ្រូ ..................67
តារាង 25 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើបញ្ហាប្រឈមរបស់សិស្ស..............69
តារាង 26៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើបញ្ហាប្រឈមរបស់មាតាបិតា ឬអាណាព្យាបាល....................................................................................................72
តារាង 27៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើបញ្ហាប្រឈម និងកត្តាផ្សេងៗ របស់ក្រុមទាំង៤....................................................................................................74

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសជាតិមានការរីកចម្រើន និង រុងរឿងទៅបានអាស្រ័យលើធនធានមនុស្សប្រកបដោយសក្តានុពល និង ជំនាញជាក់លាក់ដោយពួកគេមានការច្នៃប្រឌិត និងភាពប៉ិនប្រសព្វសមស្របតាមសម័យបច្ចេកវិទ្យាទំនើប ដោយសារថា ការរីកចំរើន ឬការអភិវឌ្ឍរបស់ប្រទេសមួយមិនមែនវាស់ស្ទង់ទៅលើអាគារខ្ពស់ស្កឹមស្កៃ ស្រស់ស្អាត ផ្លូវខ្វាត់ខ្វែងស្អាតរលោង និងមានស្ពានឆ្លងកាត់គ្រប់ទីកន្លែងនោះទេ តែគេវាស់វាបានតាមរយៈភាពសម្បូរបែបនៃធនធានមនុស្សដែលប្រសូត្រចេញពីប្រព័ន្ធអប់រំមួយមានការរៀបចំយ៉ាងល្អ (LAKSHMI, 2019)។ នៅក្នុងយុគ្គសម័យសេដ្ឋកិច្ចសកលនេះ ភាពជោគជ័យរបស់ជាតិសាសន៍ណាមួយពឹងផ្អែកទាំងស្រុងលើចំណេះដឹង ជំនាញ និងសមត្ថភាពរបស់ពលរដ្ឋខ្លួន។ ត្រង់ចំណុចនេះមិនមានអ្វីគួរឱ្យគេភ្ញាក់ផ្អើលនោះទេព្រោះថា សង្គមមួយដែលពលរដ្ឋទទួលបានការសិក្សាអប់រំខ្ពស់ ជាតិសាសន៍នោះនិងមានការរីកចំរើនផ្នែកសេដ្ឋកិច្ចមិនខានឡើយ (ក្រសួងអប់រំយុវជននិងកីឡា, ២០២១)។ ហេតុនេះហើយ នៅលើឆាកអន្តរជាតិក៏មានការរៀបចំជាកិច្ចប្រជុំផ្សេងៗដូចជា៖ កិច្ចប្រជុំស្តីពីការអប់រំសម្រាប់ទាំងអស់គ្នាដែលបានប្រព្រឹត្តឡើងនៅទីក្រុងដាកា ប្រទេសសេណេហ្កាល់ ក្នុងឆ្នាំ២០០០ និងទិសដៅអភិវឌ្ឍប្រកបដោតចិរភាពរបស់អង្គការសហប្រជាជាតិ។ បើយើងក្រលេកមកមើលប្រទេសកម្ពុជាវិញក៏មិននៅតែឯងដែរ រដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើវិស័យអប់រំ ដែលជាវិស័យមួយដ៏មានអាទិភាព ក៏ដូចជាកម្លាំងចលករដ៏មុតស្រួចក្នុងការចូលរួមកសាងប្រទេសជាតិ។ រាជរដ្ឋាភិបាលបានកំណត់គោលនយោបាយប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ សមិទ្ធិផលអប់រំ និងការរីកចំរើនជាបន្តបន្ទាប់ជាច្រើនដែលកម្ពុជាទទួលបានពីការអនុវត្តគោលដៅអភិវឌ្ឍសហសវត្សន៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា ដោយឈរលើមូលដ្ឋានដ៏

សំខាន់ដើម្បីឈានទៅសម្រេចការអប់រំក្នុងបរិបទឆ្នាំ២០៣០ខាងមុខតាមរយៈការលើកកំពស់គុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំ(ក្រសួងអប់រំយុវជននិងកីឡា ២០១៩)។

ដោយមើលឃើញពីភាពចាំបាច់នៃវិស័យអប់រំបែបនេះហើយ ទើបរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវគោលនយោបាយមួយគឺការពង្រីកភូមិសិក្សាឱ្យដល់មូលដ្ឋានរបស់ពលរដ្ឋក្នុងបំណងកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សានុសិស្ស ពិសេសក្មេងស្រីនិងកុមារក្នុងគ្រួសារក្រីក្រព្រមទាំងកុមារដែលងាយរងគ្រោះក្នុងទិសដៅសម្រេចឱ្យបាននូវគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នាដែលបានធ្វើនៅទីក្រុងដាកា ប្រទេសសេណេហ្កាល់ដែលមានប្រទេសនានា អង្គការអន្តរជាតិ និងភាគីពាក់ព័ន្ធចំនួន ១៦០ កាលពីឆ្នាំ២០០០ ដែលក្នុងនោះមានទាំងប្រទេសកម្ពុជាផងដែរនោះ ដែលកម្ពុជាខ្លួនឯងបានកំនត់ថា៖ពលរដ្ឋកម្ពុជាគ្រប់រូបត្រូវបានទទួលការអប់រំកម្រិតមូលដ្ឋានដោយឥតបង់ថ្លៃ ប្រកបដោយសមភាព សមធម៌ និងបរិយាប័ន្នយ៉ាងហោចណាស់ចប់ថ្នាក់ទី៩។ ក្នុងន័យនេះហើយទើបក្រសួងនានាដែលភាគីពាក់ព័ន្ធបាន និងកំពុងជ្រុំជ្រែងឱ្យមានដំណើរការទាំងគ្រឹះស្ថានសិក្សាសាធារណៈរបស់រដ្ឋ និងគ្រឹះស្ថានសិក្សាឯកជនឱ្យមានដំណើរការរលូនដោយការជ្រើសរើសគ្រឹះស្ថានសិក្សានោះទៅតាមធនធានស្ថានភាពនិងចំណង់ចំណូលចំណូលចិត្តរបស់សិស្ស និងមាតាបិតា ដែលគេប្រទះឃើញមានទាំងនៅទីក្រុងភ្នំពេញ តាមបណ្តាទីរួមខេត្តនានា ក៏ដូចជានៅតាមមូលដ្ឋានរបស់ប្រជាជនយើងទាំង ២៥ខេត្ត ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា (ក្រសួងអប់រំយុវជននិងកីឡា ២០១១)។

ដើម្បីរក្សាភាពគង់វង្សនៃការសិក្សារបស់សិស្ស សាលារៀននិមួយៗត្រូវតែជាសាលារៀនខ្ពស់មានលក្ខណៈសម្បត្តិដូចតទៅនេះ៖ ១.បេសកកម្ម៖ដោយសាលានិមួយៗត្រូវព្យាយាមលើកស្ទួយវិស័យអប់រំសិក្សារបស់សិស្សានុសិស្សឱ្យបានភាពស្មើៗគ្នានៅគ្រប់ស្ថានភាពឱ្យបានកាន់តែប្រសើរឡើង ទាំងសិស្សមានជីវភាពធូរជា ជីវភាពមធ្យម និងជីវភាពក្រីក្រដែលជាសិស្សជួបការលំបាក។ ២. បរិស្ថានសិក្សា៖សាលារៀនត្រូវមានបរិស្ថា នសិក្សាដែលគួរជាទីមនោរម្យ ដែលអាចធានាបាននូវសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់ និងសុខមាលភាពរបស់សិស្សានុសិស្ស និងបុគ្គលិកសិក្សាដែលជាគ្រូបង្រៀនឱ្យកាន់តែមាន

លក្ខណៈប្រសើរឡើង និងធ្វើឱ្យមាតាបិតា អាណាព្យាបាលសិស្សមានភាពកក់ក្តៅ និងទំនុកចិត្តមកលើសេវាកម្ម និងលក្ខណៈអំណោយផលនានាដែលសាលានោះមាន។ ៣.ការរៀន និងការបង្រៀន៖សំដៅដល់ការជានាគុណភាពនៃការផ្តល់សេវាបង្រៀននិងការរៀនឱ្យបានកាន់តែប្រសើរដោយការអប់រំនោះត្រូវផ្តោតលើសមាសភាពទាំង៥ មានដូចជា៖បញ្ញា កាយ សិល្បៈ ពលកម្ម សោភ័ណ និងមានការបណ្តុះបណ្តាលបំណិនជីវិតប្រកបដោយចតុស្តម្ភដល់សិស្សទាំងអស់។ ៤. ការលើកទឹកចិត្តគ្រូបង្រៀន៖ សំដៅដល់ការលើកទឹកចិត្ត និងកែលំអជីវភាពគ្រូបង្រៀនឱ្យបានសមរម្យ និងកាន់តែប្រសើរឡើងតាមរយៈមធ្យោបាយមួយចំនួនដូចជា៖ការចូលរួមជាថវិការបស់សប្បុរសជនជាតិ អន្តរជាតិ និងសហគមន៍។ បុគ្គលិកអប់រំត្រូវទទួលបានការលើកទឹកចិត្តតាមរយៈ៖ ការសរសើរ ការជូនរង្វាន់ជាទឹកប្រាក់ ឬប័ណ្ណសរសើរ ដំណើរកំសាន្តក្នុង និងក្រៅប្រទេស បង្កើតមូលនិធិជួយគ្រូដែលជួបការលំបាក ការបណ្តុះផ្នត់គំនិតឱ្យមានសេចក្តីស្រលាញ់មនុស្សជំនាន់ក្រោយ ការគោរពក្រមសិលធម៌វិជ្ជាជីវៈរបស់ខ្លួនទៅតាមនិយាម លើកទឹកចិត្តឱ្យបន្តអភិវឌ្ឍចំណេះដឹងលើផ្នែក កុំព្យូទ័រ និងភាសាបរទេស។ ៥. ការអភិវឌ្ឍធនធានមនុស្សមានន័យថា គុណភាពគ្រូជាសូចនាករកំនត់គុណភាពអប់រំ ហេតុនេះហើយការបណ្តុះបណ្តាលគ្រូ និងធ្វើវិក្រឹតការលើគ្រូបង្រៀនជាប្រចាំដូចភ្លៀងរលឹមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សនៅតាមសាលារៀន។ ៦.ការរៀបចំគំរោងអភិវឌ្ឍ៖មិនថាតែស្ថាប័នឯកជន ក្រុមហ៊ុនតូចធំនោះទេ វាត្រូវតែមានផែនការអភិវឌ្ឍរយៈពេលខ្លី រយៈវែងនិងរយៈមធ្យមដូចគ្នា។ បើងាកមកថ្នាក់សាលារៀន ក៏មិនខុសគ្នាដែរគឺថា សាលារៀននិមួយៗត្រូវមានគម្រោងថវិការអភិវឌ្ឍឱ្យបានច្បាស់លាស់ដើម្បីកំណត់បេសកកម្ម គោលនយោបាយ និងគោលដៅនៃកិច្ចដំណើរការរបស់សាលារៀនដោយមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តផែនការទាំងនោះ ដែលបានដាក់ចេញដោយមានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ ដែលមានដូចជា៖ សហគមន៍ មាតាបិតាសិស្ស អាជ្ញាធរដែនដី អង្គការដៃគូ និងសប្បុរសជន។ ៧.ការចូលរួមរបស់សហគមន៍ និងភាគីពាក់ព័ន្ធ៖មានន័យថាសាលារៀនត្រូវលើកទឹកចិត្តឱ្យមានការចូលរួមឱ្យបានទូលំទូលាយប្រកបដោយមនសិការក្នុងនាមជាដៃគូរវាងសាលារៀន និងសហគមន៍ព្រមទាំងការចូលរួមយ៉ាងផុសផុលពីសំនាក់លោកគ្រូ អ្នកគ្រូដោយការពេញចិត្ត។ ដោយក្នុងកិច្ចការដែលរៀនធ្វើគឺដើម្បីកសាងកុមារ គ្រួសារ និងសង្គមឱ្យក្លាយជាកោសិការបស់សង្គម ការចូលរួមផ្លាស់ប្តូរយោបល់

បទពិសោធ កែលំអរដោយស្មារតីស្ថាបនាតាមរយៈមធ្យោបាយនានាដូចជា ដោយផ្ទាល់មាត់ តាមរយៈសារអេឡិកត្រូនិក ឬបណ្ដាញសង្គមផ្សេងៗ( Facebook, WeChat, Instagram, ……)ជាដើម (ស៊ឹម, ២០២០)។

ដោយមើលឃើញពីភាពចាំបាច់បែបនេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាសម្រេចបង្កើតឱ្យមានគន្លងអាជីពក្នុងវិស័យអប់រំដោយផ្ដល់ការលើកទឹកចិត្តឱ្យមានការប្រណាំងប្រជែងយកពានរង្វាន់ **សម្ដេចតេជោសែន** ដែលបានចាប់ផ្ដើមពីឆ្នាំសិក្សា ២០១៣ - ២០១៤ ដោយកម្មវិធីប្រណាំងប្រជែងនោះរួមមាន៖ (ក្រសួងអប់រំយុវជននិងកីឡា ២០១៨)

១. នាយកសាលាខ្ពស់ ដោយកំណត់យក០១ឆ្នាំ ចំនួន ០៣នាក់ សរុប ០៧ឆ្នាំស្មើនឹង ២១នាក់។

២. គ្រូបង្រៀនខ្ពស់ ដោយក្នុង០១ឆ្នាំកំនត់យក ០៥នាក់ សរុប០៧ឆ្នាំស្មើនឹងចំនួន ៣៥នាក់។

៣. គ្រូបង្រៀនខ្ពស់ភាសាខ្មែរថ្នាក់ទី១ ទី២ ទី៣ ដោយក្នុង០១ឆ្នាំយក ០៥នាក់ សរុប០៤ ឆ្នាំស្មើនឹងចំនួន ២០នាក់។

៤. នាយកសាលាស្អាត ដោយក្នុង០១ឆ្នាំកំនត់យក ០៥នាក់ សរុប០៤ឆ្នាំស្មើនឹង ២០នាក់។

ក្រៅពីការប្រកួតប្រជែងសម្រាប់លោក អ្នកគ្រូហើយនោះ នៅមានកម្មវិធីសម្រាប់សិស្សានុសិស្សផងដែរដូចជា៖កម្មវិធីកូនខ្ពស់ សិស្សខ្ពស់ មិត្តខ្ពស់ ដែលក្រសួងអប់រំ យុវជន និងកីឡាបានបូកសរុបចលនាប្រឡងប្រណាំង ៣ល្អ “កូនល្អ សិស្សល្អ មិត្តល្អ” នៅថ្នាក់ជាតិ មានអ្នកចូលរួម ១៧៥នាក់ ស្រី ៥១ភាគរយ ដើម្បីអភិវឌ្ឍបំណិនយុវជន និងកុមារឱ្យក្លាយជាពលរដ្ឋល្អ។ ទាំងនេះជាការយកចិត្តទុកដាក់បន្ថែមពីថ្នាក់ដឹកនាំក្នុងគោលបំណងជំរុញ និងលើកទឹកចិត្តដល់បុគ្គលិកសិក្សាក្នុងគោលបំណងតែមួយគត់ គឺឱ្យពួកគាត់ប្រឹងប្រែងបំពេញភារកិច្ចឱ្យអស់ពីដៃពីជើងដើម្បីជំរុញឱ្យសិស្សានុសិស្សខិតខំរៀនសូត្រ និងទទួលបានចំណេះសម្បទា បំណិនសម្បទា និងចរិយាសម្បទា ម៉្យាងទៀតដើម្បីរក្សាសិស្សឱ្យនៅគង់វង់ក្នុងការសិក្សារបស់ពួកគេ និយាយឱ្យងាយស្ដាប់គឺបង្ការកុំឱ្យសិស្សបោះបង់ការសិក្សា ឬប្ដូរសាលាពីមួយទៅមួយ ដោយធ្វើយ៉ាងណាត្រូវរក្សាចំនួនសិស្សក្នុងគ្រឹះស្ថានសិក្សានិមួយឱ្យនៅមានចំនួន

ថែរ ពិសេសធ្វើយ៉ាងណាកុំឱ្យមានតំថយសិស្សនៅតាមសាលារៀនកម្រិតមធ្យមសិក្សាទុតិភូមិ ពិសេសនៅភូមិសាស្ត្ររាជធានីភ្នំពេញតែម្តង (ណារ៉ុន ២០២១)។ ក្នុងនោះផងដែរ ក្រសួងអប់រំយុវជន និងកីឡា បានដាក់ចេញគម្រោងកែលម្អបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារបរិក្ខារអប់រំនៅកម្ពុជា (CPISEEF) ជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន មានថវិកា ២២,៨៣លានដុល្លារអាមេរិក ក្នុងនោះ ថវិកា ២០,៦៩លានដុល្លារអាមេរិក គាំទ្រដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន និងថវិកា ២,១៤ លានដុល្លារអាមេរិក គាំទ្របដិភាគដោយរាជរដ្ឋាភិបាលកម្ពុជា មានរយៈពេលអនុវត្តពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២២។ វឌ្ឍនភាពសំខាន់ៗរួមមាន៖ សាងសង់អគារសិក្សា ២៦កន្លែង នៅខេត្តកណ្តាល ១០ ខេត្តកំពង់ចាម ១០ និងរាជធានី ៦។ គម្រោងនេះគ្របដណ្តប់លើវិទ្យាល័យ ២៦ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ១ ក្នុងនោះសង់អគារសិក្សា ២៣ខ្នង ស្មើ ២៨៩បន្ទប់ អគារធនធាន ១៧កន្លែង អន្តេវាសិកដ្ឋាន ១ខ្នង ផ្ទះគ្រូ ៥កន្លែង ទីលានបាល់ទាត់ ៨ ទីលានបាល់បោះ ១៥ បង្គន់អនាម័យ ៣២ខ្នង ស្មើ ១៦០បន្ទប់ អណ្តូងទឹក ២៣ របងសាលារៀនប្រវែង ៦៤០ម៉ែត្រ ធ្វើផ្លូវនិងលូបង្ហូរទឹកបេតុងប្រវែង ៧៥០ម៉ែត្រ បំពាក់គ្រឿងសង្ហារឹម និងបរិក្ខារផ្គត់ផ្គង់ទឹក។ បច្ចុប្បន្ន ការអនុវត្តគម្រោងសម្រេចបាន ៥៥,៤៧ភាគរយ ។

## ១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមស្ថិតិEMIS ២០២១ -២០២៣ បានបង្ហាញថា៖ អនុវិស័យការអប់រំបឋមសិក្សាសម្រេចបានតាមគោលដៅចំនួន៧០.៦% កំពុងអនុវត្តចំនួន២៣.៥% ចំណែកចំណុចមិនទាន់បានអនុវត្តចំនួន ៥.៩%ប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ ការអប់រំកុមារតូចសម្រេចបានដល់ទៅ៧១.៤% កំពុងអនុវត្តមានចំនួន២៨.៦% និងមិនទាន់អនុវត្តស្មើនឹង ០.០%។ ផ្ទុយទៅវិញ បើក្រឡេកមកមើលការអប់រំមធ្យមសិក្សាវិញ ៥៨,៣%(ភាគរយ) ចំណែកកំពុងអនុវត្តវិញ មាន២៥%(ភាគរយ) និងមិនបានអនុវត្ត ១៦,៧% (ភាគរយ)។

| មធ្យមសិក្សាទុតិយភូមិ | ២០១៩-២០២០ | ២០១៩-២០២០ | | ២០២០-២០២១ | ២០២០-២០២១ | |
|---|---|---|---|---|---|---|
| | សរុប | សរុប | កើន ថយ | ស្រី | ស្រី | កើន ថយ |
| អត្រាឡើងថ្នាក់ | ៩១,៤ | ៨០,៤ | -១១ | ៩១,៧ | ៨១,២ | -១០,៥ |
| អត្រាត្រួតថ្នាក់ | ០,២ | ១,១ | +០,៩ | ០,២ | ០,៩ | +០,៧ |
| អត្រាបោះបង់ការសិក្សា | ៨,៤ | ១៨,៥ | +១០,១ | ៨,១ | ១៧,៩ | +៩,៨ |
| អត្រាឆ្លងភូមិសិក្សា | ៨១,៣ | ៧៨,២ | -៣,១ | | | |

យោងតាមទិន្នន័យពីរឆ្នាំសិក្សាជាប់ៗគ្នាគឺឆ្នាំសិក្សា២០១៩-២០២០ និងឆ្នាំសិក្សា ២០២០-២០២១ បានបង្ហាញថា៖ នៅឆ្នាំសិក្សា**២០១៩-២០២០** អត្រាឡើងថ្នាក់ថយចុះ ១១%(ភាគរយ) អត្រាត្រួតថ្នាក់កើនឡើង ០.៩%(ភាគរយ) អត្រាបោះបង់ការសិក្សាកើនឡើងដល់ ១០.១%(ភាគរយ) ស្រីថយ ០,៦%(ភាគរយ) តែនៅកម្រិតមធ្យមសិក្សាទុតិយភូមិបែរជាមានកំណើនទៅវិញ ដោយកើនឡើងរហូតដល់១០,១%(ភាគរយ) ក្នុងនោះស្រីកើន ៩,៨%(ភាគរយ) (ក្រសួងអប់រំយុវជននិងកីឡា ២០២២)។

នៅកម្រិតមធ្យមសិក្សាទុតិយភូមិមានអត្រាធ្លាក់ចុះនៃចំនួនសិស្សគួរឱ្យព្រួយបារម្ភពីសំណាក់ក្រសួងអប់រំ យុវជននិងកីឡា មន្ទីរអប់រំដែលជាអ្នកគ្រប់គ្រងផ្ទាល់ សហគមន៍ដែលចំណុះឱ្យសាលាទាំងនោះ ហើយកាន់តែពិសេសទៀតនោះគឺ ទស្សនៈរបស់ភាគីពាក់ព័ន្ធចំពោះសាលារៀនដែលមានរហូតដល់ថ្នាក់ទី១០ ទី១១ ទី១២ ព្រោះថាវាកម្រិតទុតិយភូមិដែលទាមទារឱ្យមានការប្រឹងប្រែងខ្លាំងទាំងពីសំណាក់សាលារៀនផ្ទាល់ និងសិស្សានុសិស្សខ្លួនឯងដើម្បីសម្រួចសមត្ថភាព និងត្រៀមខ្លួនចាប់យកជំនាញ វិជ្ជាជីវៈនៅសាលាបណ្តុះបណ្តាលបច្ចេកទេស ឬមហាវិទ្យាល័យបន្ទាប់ពីចប់ថ្នាក់វិទ្យាល័យរបស់ពួកគេ។ ក្រៅពីនេះ បើគេពិនិត្យមើលលើផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ បានកំណត់ថា ការអប់រំឈរលើគោលការណ៍ចំនួន៥ ដែលមានដូចតទៅ៖ គុណភាព សមភាព បរិយាបន្ន ការសិក្សាពេញមួយជីវិត និងទាំង

អស់គ្នា( (ក្រសួងអប់រំយុវជននិងកីឡា ២០១៩)និងរបាយការណ៍របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញពីឆ្នាំសិក្សា២០១៧ ដល់ ២០២២ ត្រឹមឆមាសទី១ បានបង្ហាញថា នៅតាមសាលាកម្រិតទុតិយភូមិពិតជាមានចំនួនសិស្សថយចុះពិតប្រាកដមែន។

ហេតុនេះហើយទើប អ្នកសិក្សាលើកយកប្រធានបទមួយដែលមានចំណងជើងថា«**ទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ នៅក្នុងរាជធានីភ្នំពេញ**» មកសិក្សាស្រាវជ្រាវដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់។

## ១.៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ពីរគឺ៖

(១) រកឱ្យឃើញនូវបញ្ហាប្រឈម និងកត្តាផ្សេងៗដែលជាមូលហេតុធ្វើឱ្យចំនួនសិស្សកាន់តែថយចុះ។

(២) ឈ្វេងយល់ពីទស្សនៈភាគីពាក់ព័ន្ធចំពោះសាលារៀនដែលមានសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកើនឡើង។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវនេះមានលក្ខណៈសុក្រិត និងអាចទទួលយកបាន ក្នុងនាមខ្ញុំបាទជាអ្នកស្រាវជ្រាវបានកំណត់យកសំនួរចំនួន០២សម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទខាងលើនេះដែលមានដូចខាងក្រោមនេះ៖

(១)តើមានបញ្ហាប្រឈមអ្វីខ្លះដែលនាំឱ្យមានតំថយសិស្សនៅសាលាទាំងនោះ?

(២)តើភាគីពាក់ព័ន្ធមានទស្សនៈដូចម្តេចខ្លះចំពោះសាលាដែលមានសិស្សថយចុះ និងសាលាដែលមានចំនួនសិស្សកើនឡើងវិញ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ទោះបីការសិក្សាស្រាវជ្រាវនេះ មិនបានផ្តោតឱ្យគ្រប់ជ្រុងជ្រោយលើ ទស្សនៈរបស់ភាគីពាក់ព័ន្ធចំពោះការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះយ៉ាងណាក្តី ក៏លទ្ធផលនៃការសិក្សាមួយនេះនិងបានចូលរួមចំណែកដូចតទៅ៖

១) ក្លាយជាទ្រឹស្តីមួយដែលអ្នកសិក្សា អ្នកស្រាវជ្រាវក្រោយៗទៀតយកទៅស្រាវជ្រាវបន្តតាមរយៈការពង្រីកវិសាលភាពនៃការស្រាវជ្រាវរបស់ខ្លួន។

២) អាចឱ្យសាលាទាំងនោះដឹងពីកង្វះខាត និងអ្វីដែលត្រូវបំពេញបន្ថែមដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់សិស្ស និងឱ្យសហគមន៍មានទំនុកចិត្តលើសាលាឡើងវិញ ព្រមទាំងបញ្ជូនកូនឱ្យមករៀន និងចូលរួមក្នុងការសាលារៀនទាំងនោះបន្តទៀត។

## ១.៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**ការស្រាវជ្រាវនេះចែកចេញជា ៥ជំពូក:**

**ជំពូកទី១៖ សេចក្តីផ្តើម**

ក្នុងជំពូកនេះបានបង្ហាញពី លំនាំបង្ហាញនៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២៖ ផ្នែករំលឹកទ្រឹស្តី**

ក្នុងជំពូកនេះជាការបង្ហាញ និង ការពារអំណះអំណាងរបស់កម្មវត្ថុនៃការសរសេរនិក្ខេបបទដោយលើកយកទ្រឹស្តីអ្នកប្រាជ្ញ អ្នកសិក្សាមុនៗ លិខិតបទដ្ឋានគតិយុត្តិនានា និងឯកសារផ្សេងៗដែលពាក់ព័ន្ធមកបង្ហាញ។

**ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ**

ក្នុងជំពូកនេះជាការលើកឡើងពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងគំរោងនៃការវិភាគ ការកំណត់អថេរ ការកំណត់ពេលវេលា ទីកន្លែងដែលត្រូវចុះទៅសិក្សាស្រាវជ្រាវ វិធីសាស្ត្រក្នុងការជ្រើសរើស និងប្រមូលទិន្នន័យ វិភាគសំណាក និងការប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យ។

**ជំពូកទី៤៖ លទ្ធផលសិក្សា និងការពិភាក្សា**

អ្នកស្រាវជ្រាវចង់បង្ហាញពីលទ្ធផលជាក់ស្តែងដែលទទួលបានពីការសិក្សាស្រាវជ្រាវដែលឆ្លើយតបទៅនិងសំណួរក្នុងចំណោទបញ្ហាខាងលើ។ ការពីភាក្សាគឺ ជាការប្រមូលទិន្នន័យយកមកវិភាគ និងពិភាក្សាប្រៀបធៀបលើទ្រឹស្តីដែលបានរកឃើញកន្លងមកដើម្បីរកឱ្យឃើញនូវចំនុចខ្វះចន្លោះ បញ្ហាប្រឈម ក្នុងបំណងកែតម្រូវឱ្យបានប្រសើរឡើង។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

ជំពូកនេះ អ្នកស្រាវជ្រាវមានទំនោរធ្វើសេចក្តីសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ដែលបានរកឃើញក្នុងជំពូកទី៤ និងលើកជាសំណូមពរនៅលើចំណុចដែលត្រូវកែលំអរ ឬចំណុចខ្វះខាតនានាក្នុងគោលបំណងចូលរួមចំណែកលើកកំពស់អត្រាគង់វង្សរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក៏ដូចជាចូលរួមអភិវឌ្ឍគុណភាពអប់រំផងដែរដើម្បីជាផ្នែកមួយនៃការរួមចំណែកកសាងប្រទេសជាតិឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

# ជំពូកទី២៖ ការរំលឹកទ្រឹស្តី

នៅក្នុងប្រធានបទនេះ អ្នកស្រាវជ្រាវ ត្រូវធ្វើការស្រាវជ្រាវរកឱ្យឃើញពីទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ ដោយករណីសិក្សានេះត្រូវបានធ្វើការសិក្សាស្រាវជ្រាវនៅសាលាវិទ្យាល័យក្នុងរាជធានីភ្នំពេញ។ ដើម្បីឈានដល់ការយល់ពីអត្ថប្រយោជន៍គួរគប្បីឈ្វេងយល់ទ្រឹស្តី និងចំណុចសំខាន់ៗដែលជាប់ពាក់ព័ន្ធជាមុនក្នុងការទទួលបានមូលដ្ឋានក្នុងការបកស្រាយ។

## ២.១. និយមន័យ

សាលាមធ្យមសិក្សាទុតិយភូមិជាសាលាសម្រាប់សិស្សដែលមានអាយុចាប់ពី ១៥/១៦រហូតដល់ ១៨/១៩ឆ្នាំដែលការសិក្សាផ្តល់ឱ្យមានការរីកចំរើនគ្រប់ផ្នែក (Métais, 2002)។ យោងតាមវចនានុក្រមខេមប្រ៊ិច(Cambridge 2011)បង្ហាញថា ភាគីពាក់ព័ន្ធគឺបុគ្គលម្នាក់ឬមនុស្សមួយក្រុមដែលមានភាគហ៊ុនក្នុងរបររកស៊ីណាមួយ។ ន័យមួយទៀតគឺបុគ្គលមានដូចជាៈ នយោជិក អតិថិជន ឬពលរដ្ឋដែលជាប់ពាក់ព័ន្ធទៅនឹងអង្គការ សង្គមហើយមានទំនួលខុសត្រូវចំពោះអង្គការនោះ និងទទួលបានផលប្រយោជន៍ពេលទទួលបានជោគជ័យ (Cambridge)។ ជាមួយគ្នានេះដែរ យោងតាម GLOSSARY OF EDUCATION REFORM (2014)ភាគីពាក់ព័ន្ធមានន័យថា បុគ្គលណាមួយដែលបានដាក់ទុនក្នុងផ្នែកសុខុមាលភាព និងភាពជោគជ័យរបស់សិស្សដែលរួមមាន៖ គណគ្រប់គ្រងបុគ្គលិករដ្ឋបាល លោកគ្រូ អ្នកគ្រូ មាតាបិតា សិស្សានុសិស្ស សមាជិករបស់សហគមន៍ ពណិជ្ជករក្នុងមូលដ្ឋាន (REFORM, 2014)។ ក្រៅពីនេះគេអាចថាជា គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូអាណាព្យាបាលសិស្ស និងសិស្សានុសស្សិដោយសារពួកគេសុទ្ធតែមានការគិត ទស្សនៈ និងទំនួលខុសត្រូវដោយឡែកពីគ្នា និងការចូលរួមឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលខ្ពស់ ឬមិនខ្ពស់ (Germ Janmaat, 2016)។

## ២.២ ភាគីពាក់ព័ន្ធ

ដើម្បីឱ្យសាលារៀនមួយដំណើរការបានដោយរលូន និងទទួលបានលទ្ធផលជាវិជ្ជមានទៅតាមចង់បាននិងកំនត់របស់រាជរដ្ឋាភិបាល ក៏ដូចជាទិសដៅកំណែទំរង់របស់ក្រសួងអប់រំ យុវជន និងកីឡានោះតម្រូវឱ្យមានការចូលរួមរបស់គាគីពាក់ព័ន្ធជាច្រើនដូចជា៖ នាយកសាលា (គណៈគ្រប់គ្រង) លោកគ្រូអ្នកគ្រូ មាតាបិតាឬអាណាព្យាបាលសិស្ស និងសិស្សខ្លួនឯងផ្ទាល់តែម្តង។

ទោះបីមានរីកចំរើនគួរឱ្យកត់សំគាល់លើចំណេះដឹងគ្រប់ផ្នែក និងទំនើបកម្មលើវិធីសាស្ត្រនានាដែលទាក់ទងទៅនឹងរបៀបរបបនៃការគ្រប់គ្រងសាលាឱ្យមានគុណភាព និងការកែលំអសាលារៀនក្តី តែការកើនឡើងនៃចំណេះដឹងទាំងនេះបានបង្កើតឱ្យមានសំណួរដែលនៅមិនអាចដោះស្រាយរួចស្មើទៅនឹងសំណួរដែលគេបានស្រាយចំណាងរួចផងដែរ។ បើគិតតាមមូលដ្ឋានជារួម នេះអាចជាបច្ច័យខ្ពស់មួយដែរដោយសារថាគុណភាពរបស់សាលារៀនមួយអាចសម្រេចទៅបានទាមការចូលរួមពីភាគីច្រើន ដែលវាអាស្រ័យទៅលើបញ្ហាទាំងនោះថាវា ជាបញ្ហាសិក្សា សីលធម៌ ចិត្តសង្គម ឬការពេញចិត្ត ឬមិនពេញចិត្តរបស់លោកគ្រូ អ្នកគ្រូលើការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពឬយ៉ាងណា? (David Reynolds, 2002)។

### ២.២.១ នាយកសាលាល្អ

របៀបដឹកនាំរបស់នាយកសាលាមានភាពប្លែកៗគ្នាជាច្រើនដូចជា ការដឹកនាំតាមបែបចង្អុលបង្ហាញ ការដឹកនាំតាមបែបសហការជាដើម។ តែការដឹកនាំតាមរបៀបណាមួយ វាអាស្រ័យលើស្ថានភាពជាក់ស្តែង ហេតុនេះហើយ ខ្ញុំបាទសូមលើកយកសូចនាករសម្រាប់កំណត់ថា នាយកសាលានោះបែបណាដែលមានដូចតទៅ៖ ១)គុណវុឌ្ឍិ សំដៅដល់សញ្ញាប័ត្រឬកម្រិតវប្បធម៌ដែលគាត់មានដូចជា សញ្ញាប័ត្រ

បរិញ្ញាប័ត្រជាន់ខ្ពស់ ឬសមមូល បរិញ្ញាប័ត្រ ឬសមមូល ឬសញ្ញាប័ត្រផ្សេងៗទៀតដែលបានកំណត់ដោយក្រសួងសាមី ហេតុនេះហើយទើបក្រសួងអប់រំ យុវជន និងកីឡាបង្កលក្ខណៈងាយស្រួល និងប្រើយន្តការលើទឹកចិត្តដល់មន្ត្រីរបស់ខ្លួនតាមរយៈការផ្តល់ឱកាសរៀនបន្តដើម្បីពង្រឹងគុណវុឌ្ឍិ បន្ទាប់មកតម្លើងថ្នាក់របស់ពួកគាត់។ ២)សមត្ថភាពជំនាញ មានន័យថា គាត់ត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំ ចេះសម្របសម្រួល ដឹកនាំ គ្រប់គ្រង និងច្នៃប្រឌិត ចំណេះដឹងផ្នែកបច្ចេកវិទ្យាពត៌មាន ភាសាបរទេស មានបទពិសោធចាប់ពី ៥ឆ្នាំឡើងទៅ និងចេះលើកទឹកចិត្តសិស្សថែមទៀតផង។ ៣)ការរៀបចំផែនការសំដៅដល់ការកំណត់ចក្ខុវិស័យ បេសកកម្ម និងគោលបំណងឱ្យបានជាក់លាក់សម្រាប់សាលារបស់ខ្លួនឱ្យដំណើរការទៅមុខជាលំដាប់។ ក្រៅពីនេះត្រូវចេះរៀបចំផែនការ ចេះអនុវត្តការងារឱ្យមានតំលៃ ចេះធ្វើឱ្យសាលា និងសហគមន៍ជាជាតុពីរដែលមិនអាចខ្វះគ្នាបានក្នុងបំណងអភិវឌ្ឍសាលារបស់ខ្លួនឱ្យមានការរីកចំរើនឥតឈប់ឈរ ក្នុងន័យនេះហើយ ទើបក្រសួងបានសហការជាមួយវិទ្យាស្ថានជាតិអប់រំបើកវគ្គបណ្តុះបណ្តាលជាច្រើនមានដូចជា វគ្គនាយកជាដើម។ ៤)ការដឹកនាំការបង្រៀន និងរៀន ជាការផ្តួចផ្តើម និងគាំទ្រឱ្យមានការប្រជុំក្រុមបច្ចេកទេសឱ្យបានទៀងទាត់ដើម្បីចែករំលែកបទពិសោធខ្ពស់ៗ ព្រមលើកយកចំណុចប្រឈមដាក់លើតុដើម្បីពិភាក្សារកដំណោះស្រាយទាំងអស់គ្នា។ លើសពីនេះទៅទៀតត្រូវមានការត្រួតពិនិត្យនិងវាយតំលៃជាប្រចាំនូវការរៀន និងបង្រៀន ព្រមទាំងបញ្ចូលពីវិធីសាស្ត្រថ្មីៗក្នុងការបង្រៀនបំផុសឱ្យបុគ្គលិកក្រោមឱវាទអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់ និងចេះលើកទឹកចិត្តលោកគ្រូ អ្នកគ្រូឱ្យចេះសាមគ្គីគ្នាដើម្បីភាពរីកចំរើនរបស់អង្គភាព។ ៥) ការអភិវឌ្ឍខ្លួនឯង ជាកត្តាចាំបាច់ដើម្បីដើម្បីធ្វើឱ្យការងារគ្រប់គ្រងកាន់តែមានប្រសិទ្ធភាប្រសើរឡើង ចេះស្វ័យវាយតំលៃ និងបន្តអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ខ្លួនឯងផង និងជំរុញបុគ្គលិកផងដើម្បីឧត្តមភាពនៃការងារ។ ៦)ការគ្រប់គ្រងសាលារៀន សំដៅដល់ការងារគ្រប់គ្រងទាំងរដ្ឋបាល និងបច្ចេកទេសដែលមានដូចជា៖ ការធ្វើឱ្យផែនការអភិវឌ្ឍសាលាមានដំណើរការ ការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស ការរៀបចំសេវាបង្រៀនឱ្យបានត្រឹមត្រូវនិងមានសុក្រឹតភាព ការរៀបចំបរិស្ថានសាលារៀនឱ្យមានភាពទាក់ទាញសម្រាប់គ្រប់គ្នា កសាងសាលារៀនឱ្យក្លាយជាទីប្រកបដោយសុវត្ថិភាពទាំងសម្រាប់គ្រូ និងសិស្សានុសិស្ស។ ៧)ការជានាគណនេយ្យភាព ជាការផ្តល់តម្លា

ភាពផ្នែកគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ព្រមទាំងទ្រព្យសម្បត្តិរដ្ឋថែមទៀតផង។ ក្រៅពីនេះ នូវមានចំណុចមួយចំនួនទៀតដូចជា៖ រៀបចំកិច្ចបញ្ជីការគណនេយ្យហិរញ្ញវត្ថុ បញ្ជីសារពើភ័ណ្ឌ បញ្ជីគ្រប់គ្រងវត្តមានបុគ្គលិក និងបិទផ្សាយតារាងតម្លាភាពហិរញ្ញវត្ថុ សម្ភារៈទ្រព្យសម្បត្តិ និងបុគ្គលិក។ ៨)ការពង្រឹងទំនាក់ទំនងជាមួយសហគមន៍ ដូចដែលយើងបានដឹងហើយថា សហគមន៍ជាប្រភពមិនចេះរីងស្ងួតក្នុងការចូលរួមជាថវិការ និងសម្ភារៈផ្សេងៗសម្រាប់ការអភិវឌ្ឍសាលា ហេតុនេះហើយនាយកសាលាត្រូវផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋានទៅជាមួយសហគមន៍ បង្កើត និងរក្សាស្នាដៃសិស្សដើម្បីឱ្យមាតាបិតា ក៏ដូចជាសហគមន៍បានឃើញ និងកាន់តែមានការគាំទ្រច្រើនជាងមុន។ មិនត្រឹមតែប៉ុណ្ណោះ នាយកត្រូវរៀបចំឱ្យមានមូលនិធិសមធម៌អប់រំ ដោយសហការជាមួយវិស័យរដ្ឋ និងឯកជន។ ៩)ក្រមសីលធម៌វិជ្ជាជីវៈ ជារបស់ដែលនាំឱ្យមន្ត្រីរាជការរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូរ។ ដើម្បីទទួលបានកិត្តិយស និងសេចក្តីថ្លៃថ្នូនាយកសាលាគួរមានៈ មនសិការវិជ្ជាជីវៈ មានការទទួលខុសត្រូវចំពោះមុខនាទីរបស់ខ្លួន មានសីលធម៌ គុណធម៌ និងយុត្តិធម៌ចំពោះបុគ្គលិក និងមនុស្សជុំវិញខ្លួន។ ១០)លទ្ធផលគ្រប់គ្រប់ សំដៅដល់ការបញ្ជ្រាបបុគ្គលិកឱ្យមានការយល់ដឹងពីកម្មវិធីសិក្សាតាមកម្រិតថ្នាក់ ឱ្យមានសមត្ថភាពលើវិធីស្ត្រាស្ត្រ និងបច្ចេកទេសបង្រៀន និងចេះថែរក្សា និងផ្គត់ផ្គង់សៀវភៅសិក្សាឱ្យបានខ្ពស់។ ១១)ការអភិវឌ្ឍយុវជន ដូចសុភាសិតខ្មែរតែងពោលថា "ទំពាំងស្នងឫស្សី"មានន័យថា បើទំពាំងដុះមកខ្ពស់ ហើយមានការថែទាំដឹតដល់ថែមទៀតនោះ យើងបានឫស្សីខ្ពស់សម្រាប់យកមកប្រើប្រាស់មិនខានឡើយ។ មិនខុសគ្នាដែរយុវជនប្រៀបបានទៅនឹងទាំពាំងដែលទាមទារឱ្យមានការយកចិត្តទុកដាក់តាំងពីពួកគេនៅតូចៗដោយសាលាត្រូវៈ រៀបចំឱ្យមានក្រុមប្រឹក្សាកុមារ ឬយុវជន ក្លឹបសិក្សារបស់សិស្សដើម្បីឱ្យពួកគេចេះដោះដូរយោបល់ បណ្តុះវប្បធម៌ចែករំលែក និងការរស់នៅជាមួយគ្នាប្រកបដោយសុខុដុមរមនា សកម្មភាពបណ្តុះបណ្តាលកុមារជាដើម (ក្រសួងអប់រំយុវជននិងកីឡា ២០១៦)។

### ២.២.២ គ្រូបង្រៀនល្អ

គោលនយោបាយស្តីពីគ្រូបង្រៀនត្រូវបានដាក់ចេញដោយក្រសួងអប់រំ យុវជននិងកីឡា ក្នុងគោលដៅពង្រឹងសមត្ថភាពបុគ្គលិកអប់រំឱ្យមានសគុណវុឌ្ឍិស្របតាមការរីកចំរើនរបស់សកលលោក តំបន់ និង

ប្រទេសយើង លើសពីនេះទៅទៀតដើម្បីផ្ដល់ចំណេះដឹងដល់សិស្សស្របតាមតម្រូវការទីផ្សារការងារនាសម័យកាលបច្ចុប្បន្ននេះ។ ស្រដៀងគ្នានេះដែរ ក៏មានការប្រកួតប្រជែងជ្រើសរើសគ្រូបង្រៀនខ្ពស់ផងដែរ ក្នុងគោលដៅជ្រើសរើសគ្រូបង្រៀនខ្ពស់ និងអាចជំរុញលោកគ្រូ អ្នកគ្រូឱ្យប្រឹងប្រែងបំពេញការងារដើម្បីក្លាយខ្លួនជាគ្រូបង្រៀនខ្ពស់ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។ ហេតុនេះហើយខ្ញុំបាទសូមលើកយកចំណុចសំខាន់ៗដើម្បីកំណត់ថា គ្រូបង្រៀនល្អមានលក្ខណៈវិនិច្ឆ័យដូចម្ដេចខ្លះ?

១)គុណវុឌ្ឍិ សំដៅដល់សញ្ញាប័ត្រឬកម្រិតវប្បធម៌ដែលគាត់មានដូចជា សញ្ញាប័ត្របរិញ្ញាប័ត្រជាន់ខ្ពស់ ឬសមមូល បរិញ្ញាប័ត្រ ឬសមមូល ឬសញ្ញាប័ត្រ សញ្ញាប័ត្របណ្ដុះបណ្ដាលគ្រូ និងសញ្ញាប័ត្រផ្សេងៗទៀតដែលបានកំណត់ដោយក្រសួងសាមី។ ២)សមត្ថភាពជំនាញ មានន័យថា គាត់ត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំ ដឹកនាំ គ្រប់គ្រង និងច្នៃប្រឌិត ចំណេះដឹងផ្នែកបច្ចេកវិទ្យាពត៌មាន ភាសាបរទេស មានជំនាញវិភាគ និងបកស្រាយពត៌មាន និងចេះលើកទឹកចិត្តសិស្ស។ ៣)ភាពជាអ្នកដឹកនាំ ចង់បង្ហាញថា លោកគ្រូ អ្នកគ្រូត្រូវវិនិច្ឆ័យឱ្យបានត្រឹមត្រូវ មានតម្លាភាព និងយុត្តិធម៌ ចេះដឹកនាំសិស្សឱ្យចូលរួមការងារសង្គម និងសហគមន៍។ លើសពីនេះទៀត ត្រូវមានការរៀបចំរដ្ឋបាលថ្នាក់ តាមដាន វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស គ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព ទទួលខុសត្រូវ កែលម្អ និងផ្ដល់ឱកាសដល់សិស្សឱ្យស្មើភាព និងជម្រុញសកម្មភាពក្លឹបសិក្សា។ ៤)ការស្រាវជ្រាវ និងគំនិតច្នៃប្រឌិតសំដៅដល់ការវាយតម្លៃលើ ការស្រាវជ្រាវបន្ថែមសរបស់លោកគ្រូ អ្នកគ្រូអំពីវិធីសាស្ត្រនិងបច្ចេកទេសបង្រៀនថ្មី ការចូលរួមផលិតសំភារៈឧបទ្ទេស ការរៀបចំកិច្ចតែងការបង្រៀន ការរៀបផែនទីគំនិតថ្មីៗក្នុងដំណើរការបង្រៀនរបស់ខ្លួន ការរិះរកវិធីសាស្ត្រនានាដើម្បីជួយសិស្សដែលរៀនយឺតឱ្យមានចំណូលចិត្តចង់សិក្សា និងរៀនទាន់សិស្សដ៏ទៃទៀតនៅតាមកម្រិតថ្នាក់ដូចគ្នាជាដើម។ លើសពីនេះទៅទៀត លោកគ្រូ អ្នកគ្រូក៏គួរចូលរួមដឹកនាំសិស្សឱ្យធ្វើកិច្ចការស្រាវជ្រាវ និងធ្វើយ៉ាងណាឱ្យថ្នាក់រៀនមានសកម្មភាពរស់រវើកជានិច្ចដូចដែលសព្វថ្ងៃនេះក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពង្រឹងលើការបង្រៀនដោយប្រើប្រាស់វិធីសាស្ត្របែបរិះរក (**Inquiry-Based Learning**)។ ៥)លទ្ធផលសិក្សារបស់សិស្ស សំដៅដល់ការយកចិត្តទុកដាក់ដល់និយ័តភាពរបស់សិស្ស ការបង្ហាត់បង្រៀនសិស្សឱ្យមានចំណេះដឹងស្រមស្របតាមកម្មវិធីសិក្សា ការរក្សាភាព

គង់វង្សរបស់សិស្សនៅតាមកម្រិតថ្នាក់និមួយៗ ការធ្វើឱ្យអត្រាឡើងថ្នាក់ស្មើ ឬខ្ពស់ជាងថ្នាក់ជាតិដែលបានកំនត់។ ៦)លទ្ធផលសិក្សារបស់សិស្ស សំដៅដល់សមត្ថភាពរបស់សិស្សសមស្របទៅតាមកម្មវិធីដែលខ្លួនសិក្សា អត្រាបោះបង់ទាបជាង ឬស្មើការកំនត់របស់ថ្នាក់ជាតិ លើសពីនេះទៀតអត្រាឡើងថ្នាក់ស្មើ ឬខ្ពស់ជាងថ្នាក់ជាតិ។ ជាមួយគ្នានេះដែរ លោកគ្រូ អ្នកគ្រូត្រូវយកចិត្តតុកដាក់លើសិស្សរៀនយឺត ត្រូវជួយបណ្តុះគំនិតឱ្យសិស្សមានការច្នៃប្រឌិត ជួយឱ្យសិស្សប្រលងជាប់ថ្នាក់រាជធានី ខេត្ត ឬថ្នាក់ជាតិ។ ៧)ក្រមសីលធម៌វិជ្ជាជីវៈ មានន័យថា លោកគ្រូ អ្នកគ្រូត្រូវប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈក្នុងនាមជាគ្រូបង្រៀន មានសីលធម៌គុណធម៌ និងយុត្តិធម៌ក្នុងការរស់នៅ។ ក្រៅពីនេះ ត្រូវចេះថែរក្សា និងទុកដាក់សម្ភារៈបរិក្ខាឱ្យមានសណ្តាប់ធ្នាប់សម្រាប់អង្គភាពទាំងមូល។ ភារកិច្ចចុងក្រោយរបស់លោកគ្រូ អ្នកគ្រូគឺ ការអភិវឌ្ឍយុវជនដែលសំដៅដល់ ការផ្តល់ប្រឹក្សាយោបល់ក្នុងដំណើរការរៀបចំក្រុមប្រឹក្សាយុវជន ការចូលរួមក្នុងក្លឹបសិក្សា ឬ កងកាយរឹទ្ធ ការជំរុញ និងដឹកនាំសកម្មភាពសង្គម ព្រមទាំងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពបណ្តុះបណ្តាលយុវជន (ក្រសួងអប់រំ យុវជននិង កីឡា ២០១៦)។ ដើម្បីឆ្លុះបញ្ចាំងលើចំណុចទាំងឡាយស្តីអំពីនាយកសាលាខ្ពស់ ខ្ញុំបាទសូមលើកយកការស្រាវជ្រាវមួយដែលធ្វើឡើងនៅប្រទេសអារ៉ាប់រួមរកឃើញថា ការគ្រប់គ្រងការរៀន និងបង្រៀនមានទំនាក់ទំនងជាមួយនឹងការគ្រប់គ្រងបុគ្គលិកពិតប្រាកដមែន (Ahbabi, 2016)។ ស្របគ្នានេះដែរក៏មានការសិក្សាជ្រាវមួយទៀតក៏បានរកឃើញថា ការគ្រប់គ្រងការរៀន និងបង្រៀនទទួលឥទ្ធិពលពីកត្តាគ្រប់គ្រងបុគ្គលិកមែនដោយទាមទារឱ្យគណៈគ្រប់គ្រងសម្រិតសម្រាំងបុគ្គលិកប្រកបដោយសមត្ថភាពលើការគ្រប់គ្រងថ្នាក់រៀន សម្ភារៈឧបទ្ទេស និងមានភាពប៉ិនប្រសព្វក្នុងការសម្របសម្រួល (រស្មី ២០១៩)។

### ២.២.៣ សាលារៀនស្អាត

សាលារៀនប្រៀបបានទៅនឹងថ្នាលបណ្តុះសំណាប ឬកូនឈើ។ បើកសិកររៀបចំថ្នាលបានល្អ នោះកូនឈើ ឬសំណាបដែលបានសាបព្រោះនោះ ប្រាកដជាដុះលូតលាស់បានល្អ និងជាទីគាប់ភ្នែកដល់អ្នកផងទាំងពួងដែលច្រើដំណើរឆ្លងកាត់រមែងឈប់មើល ព្រមទាំងសាកសួរពីរបៀបធ្វើថ្នាល និងការថែទាំសំណាប ឬកូនឈើនោះមិនខានឡើយ។ សាលារៀនក៏មិនខុសគ្នាពីថ្នាលដែរ ។បើសាលានោះល្អ នោះ

សហគមន៍ដែលជាមាតាបិតាសិស្សនឹងបញ្ជូនកូនចៅមកសាលានោះមិនខានឡើយ (ក្រសួងអប់រំយុវជន និងកីឡា, សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងសាលារៀន, ២០១៨)។ ហេតុនេះហើយ ទើបក្រសួងអប់រំយុវជន និងកីឡាបានដាក់ចេញជាឧបករណ៍វាយតម្លៃរៀនស្អាតដោយមានសូចនាករសម្រាប់វាយតម្លៃដូចតទៅ៖ ១) មានអត្តសញ្ញាណជាតិ សំដៅដល់សាលារៀនទាំងឡាយណាដែលមានៈ បាវចនាជាតិនៅតាមថ្នាក់នីមួយៗ ការតុបតែងថ្នាក់រៀនដោយបង្ហាញវប្បធម៌ និងប្រពៃណីជាតិខ្មែរ មានការតុបតែង និងតាំងរូបព្រះឆាយាលក្ខណ៍របស់ព្រះមហាក្សត្រ ការដាក់ផ្លាកឈ្មោះសាលា ឬផ្លាកសញ្ញាផ្សេងៗជាភាសាខ្មែរ និងបទបញ្ជាផ្ទៃក្នុងសម្រាប់ឱ្យសិស្សមើលនិងអនុវត្ត។ ជាមួយគ្នានេះដែរ សាលាត្រូវមានវិធានការសម្រាប់ដាក់ចំពោះសិស្សណាដែលមិនគោរពវិន័យសាលា បម្រាមមិនឱ្យប្រើប្រាស់គ្រឿងអេឡិកត្រូនិកគ្រប់ប្រភេទក្នុងម៉ោងសិក្សា។ ការដាក់ពិន័យចំពោះសិស្សដែលចោលសំរាមក្នុងទីធ្លាសាលាជាដើម។ ក្រៅពីនេះ ត្រូវមានការហាមប្រាមមិនឱ្យប្រើប្រាស់គ្រឿងញៀន ឬពាក្យស្លោកទាំងក្នុង និងក្រៅថ្នាក់រៀន។ ២) ភាពស្អាតនៅក្នុងបរិវេណសាលា បន្ទប់រៀន បន្ទប់អនាម័យនិងភាពបៃតងដោយតម្រូវឱ្យៈ នៅតាមទីធ្លាសាលាត្រូវមានសណ្តាប់ធ្នាប់ខ្ពស់ មានធុងសម្រាមឱ្យបានគ្រប់គ្រាន់ មានបង្គន់អនាម័យគ្រប់គ្រាន់ដោយបែងចែកដាច់គ្នារវាងបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រី។ ជាមួយគ្នានេះដែរ ក៏ត្រូវមានការថែរក្សាបរិស្ថានដោយមានរៀបចំសួនផ្កា សួនបន្លែ ការដាំដើមឈើដើម្បីឱ្យកាន់តែភាពតាក់ទាញសម្រាប់សិស្ស លោកគ្រូ អ្នកគ្រូ ជាពិសេសគឺសហគមន៍ និងមាតាបិតាសិស្ស។ ៣)ទីតាំងលេងកម្សាន្ត ចំណតយានជំនិះ និងទីតាំងដាក់ធុងសម្រាម ជាផ្នែកមួយសំខាន់ដែលសាលាត្រូវរៀបចំឱ្យមានកន្លែងសម្រាប់លោកគ្រូ អ្នកគ្រូអង្គុយលេងដោយរៀបចំឱ្យមាន អនាម័យល្អ រៀបចំកន្លែងសម្រាប់សិស្សអង្គុយអានសៀវភៅ ទីតាំងសម្រាប់សិស្សលេងកីឡា ទីតាំងលេងកំសាន្ត មានចំណតយានជំនិះនៅកន្លែងដែលបានកំនត់ប្រកបដោយបរិស្ថានស្អាត និងអនាម័យ។ ដើម្បីឱ្យសាលាកាន់តែមានបរិស្ថានខ្ពស់ទៀតនោះ គេត្រូវមានធុងសម្រាមក្នុបរិវេណសាលា និងទុកដាក់ឱ្យមានរបៀបរៀបរយ ព្រមទាំងមានការបែងប្រភេទធុងដាក់សម្រាមទៀតផង។ ៤)ការគ្រប់គ្រងសំណល់ មានន័យថា ត្រូវមានទីតាំងដាក់សំណល់ស្ថិតនៅឆ្ងាយពីអាការសិក្សា មានការប្រមូលសំណល់ផ្សេងៗជាប្រចាំ ត្រូវបង្ហូរសំណល់រាវតាមលូមេឱ្យត្រឹមត្រូវដោយមិនមានការបង្ហូរសំណល់រាវពាសវាល

ពាសកាល ជាពិសេសមានកិច្ចសហការ ឬកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសម្រាម។ ៥)អនាម័យចំណី អាហារជាផ្នែកសំខាន់បំផុតដល់សុខភាពសិក្សារបស់សិស្ស ហេតុនេះសាលារៀនគួរកំណត់ដូចតទៅ៖ អាហារលក់នៅសាលាជារបស់មានគុណភាព មានការចំអិនបានឆ្អិនល្អ គ្មានជាតិគីមី មានអនាម័យខ្ពស់ គ្មានរុយរោម និងត្រូវមានការវេចខ្ចប់បានត្រឹមត្រូវ។ ៦) ការប្រើប្រាស់ទឹកស្អាត ការបំពុលដោយក្លិននិង ការបំពុលដោយផ្សែង សំដៅដល់ៈ ការមានទឹកស្អាតគ្រប់គ្រាន់នៅសាលារៀនដោយទឹកស្អាតនោះត្រូវឆ្លង កាត់ការត្រួតពិនិត្យ មិនមានក្លិនស្អុយចេញពីបង្គន់អនាម័យ ឬកន្លែងធ្វើម្ហូប មិនមានការបំពុលដោយផ្សែង ដោយសារតែការដុតសម្រាម ថង់ផ្លាស្ទិកក្នុងបរិវេណសាលារៀន មិនមានការជក់បារីក្នុងសាលឡើយថែមទាំង មានបម្រាមហាមមិនឱ្យជក់បារីនៅសាលាទៀតផង។ ៧)សុខុមាលភាពគ្រូ សិស្ស និងបុគ្គលិកអប់រំ សំដៅ ដល់ការបំពាក់សម្ភារៈសង្គ្រោះបន្ទាន់ ការមានក្រុមសង្គ្រោះបឋមប្រចាំការរៀងរាល់ថ្ងៃ និងបន្ទប់សង្គ្រោះបន្ទាន់។ ៨)អត្តសញ្ញាណមន្ត្រីរាជការ ដោយតម្រូវឱ្យមានការពាក់ស្លាកសំគាល់គ្រប់ម៉ោងបំពេញការងារទោះក្នុង សាលាក្តី ឬក្រៅសាលាក្តី តម្រូវឱ្យមានសំលៀកបំពាក់សមស្រមតាមប្រពៃណីជាតិ មានការគោរពម៉ោងបំពេញ ការងារ និងស្រាវជ្រាវជាប្រចាំ លើសពីនេះទៅទៀត ត្រូវប្រកាន់ខ្ជាប់វប្បធម៌តម្លៃគំរូខ្ពស់របស់មន្ត្រីរាជការ និងអ នាម័យស្អាត។ ១០)ការចាត់តាំងអនុវត្តការងារគ្រប់គ្រងអនាម័យ បរិស្ថាន ជាការបែងចែកវេនសម្អាតដើម្បី ធ្វើអនាម័យថ្នាក់ និងក្នុងបរិវេណសាលារៀន ជាការរៀបចំវាយតម្លៃប្រធានថ្នាក់ឆ្នើមប្រចាំខែ និងប្រចាំឆ្នាំ ព្រម ទាំងមានការបិទរូបថត និងឈ្មោះប្រធានថ្នាក់ឆ្នើមប្រចាំខែ ឆ្នាំ។ កាន់តែពិសេសទៀតនោះ មានការផ្តល់ជា លិខិតសរសើរដល់ប្រធានថ្នាក់ឆ្នើមប្រចាំខែថែមទៀត (ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)។ ជាមួយគ្នា នេះដែរមានការសិក្សាស្រាវជ្រាវមួយរកឃើញថា បរិស្ថានសាលារៀនពិតជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹង ការរៀន និងបង្រៀនរបស់លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សពិតប្រាកដមែន (Freiberg, 1999)។ ស្របគ្នានេះ ដែរមានការសិក្សាមួយផ្សេងទៀតបានរកឃើញថា សាលារៀនមួយជោគជ័យត្រូវមានសិទ្ធិអំណាចលើការ គ្រប់គ្រងថវិកា កម្មវិធីសិក្សា បុគ្គលិក និងសិទ្ធិអំណាចក្នុងការធ្វើកំណែប្រែការរៀន និងបង្រៀនឱ្យស្របតាម តម្រូវការជាក់ស្តែង (Wohlstetter, 2010)។

### ២.២.៤ អ្នកសិក្សាល្អ

អ្នកសិក្សាល្អ គឺជាសិស្សទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបានបំពេញលក្ខខណ្ឌចម្បងៗក្នុងនាមជាសិស្សដូចដែលបានកំនត់ដោយក្រសួងអប់រំ យុវជន និងកីឡាដែលមានដូចជា៖ សុខភាពខ្ពស់បរិបូណ៌ មានអាហារូបត្ថមគ្រប់គ្រាន់ គោរពម៉ោងរៀនបានទៀងទាត់ ចេះរៀនតាមបែបសម័យទំនើប ចេះសហការជាមួយមិត្តរួមថ្នាក់ ចេះចូលរួមសកម្មភាពសង្គម ប្រកាន់ខ្ជាប់សីលធម៌ (សន, ២០១៩)។ ជាមួយគ្នានេះដែរ អ្នករៀន និងការរៀនត្រូវតែឱ្យមានលក្ខណៈបន្សុីគ្នាដោយកម្មវិធីសិក្សានោះត្រូវផ្តោតលើចំណាប់អារម្មណ៍ សមត្ថភាព បទពិសោធរៀនសូត្រ និងឥរិយាបថរបស់សិស្សដោយធ្វើយ៉ាងណាឱ្យសិស្សមានការរីកចំរើនយ៉ាងហោចណាស់លើផ្នែកបញ្ញា និងសមត្ថភាពច្បាស់លាស់ព្រោះវត្ថុបំណងនៃការអប់រំសម័យបច្ចុប្បន្ននេះទាមទាឱ្យអ្នកសិក្សាទទួលបានចំណេះសម្បទា បំណិនសម្បទាផង និងចរិយាសម្បទាផង។

តាមការសិក្សាមួយដែលត្រូវបានធ្វើឡើងនៅប្រទេសកាណាដាបានបង្ហាញ ទំនាក់ទំនងរវាងគ្រូ និងសិស្សពិតជាបានជះឥទ្ធិពលលើបោះបង់ការសិក្សារបស់សិស្សក្នុងទ្រង់ទ្រាយធំពិតប្រាកដមែន។ ដោយក្នុងការសិក្សានោះគេបានរកឃើញថា ទំនាក់ទំនងអវិជ្ជមានរវាងគ្រូ និង សិស្សបានបណ្តាលឱ្យមានការបោះបង់ការសិក្សាយ៉ាងច្រើនដែលមានចំនួនរហូតដល់ ១៤%។ ក្រៅពីកត្តាខាងលើនេះហើយ កត្តាភេទ អាយុ និងស្ថានភាពសេដ្ឋកិច្ចសង្គមក៏ជាបច្ច័យរួមផ្សំដែលនាំឱ្យសិស្សានុសិស្សបោះបង់ចោលការសិក្សាទាំងនៅវ័យក្មេងផងដែរ (Rick N. Noble1, 2020)។

### ២.២.៥ អាណាព្យាបាល ឬមាតាបិតាសិស្ស

ការចូលរួមរបស់មាតាបិតា ឬអាណាព្យាបាលសិស្សពិតជាមានសារៈសំខាន់មិនខាចខ្វះបានឡើយព្រោះផ្ទះត្រូវបានកំណត់ថាជាសាលារៀនទីពីររបស់សិស្សគ្រប់រូបក្នុងគោលដៅដើម្បីបំពេញចន្លោះខ្វះខាតដែលគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូមិនអាចបំពេញបានគ្រប់ជ្រុងជ្រោយរហូតដល់ក្រសួងកំណត់

ជាខ្លឹមសារដែលមានចំនួនបីដូចតទៅ៖ ១)ខ្លឹមសារសម្រាប់អប់រំមាតាបិតា និងសិស្ស ២)ការបំប៉នមាតាបិតា និងសិស្ស និងទី៣) ការអនុវត្តការពិនិត្យតាមដាន (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។ ស្របទៅនឹងអ្វីដែលក្រសួងបានដាក់ចេញនេះ ក៏មានការសិក្សាមួយដែលធ្វើនៅប្រទេសប៉ាគីស្ថានបានបង្ហាញថា ការយល់ដឹង និងឱ្យតម្លៃលើការអប់រំរបស់មាតាបិតា ឬអាណាព្យាបាលទាក់ទងនឹងបញ្ហាសិក្សារបស់កូនពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការកែប្រែចន្ទះរបស់ឪពុកម្តាយ ឬអាណាព្យាបាលសិស្ស និងការលើកទឹកចិត្តឱ្យពួកគាត់ចូលរួមក្នុងដំណើរការទាំងឡាយណាដែលទាក់ទងនឹងការអប់រំរបស់កូនៗពួកគេឱ្យបានកាន់តែប្រសើរថែមទៀត ដោយសាលាបង្កលក្ខណៈបែបណាឱ្យឪពុកម្តាយ ឬអាណាព្យាបាលសិស្សមានអារម្មណ៍ថាសាលាកំពុងស្វាគមន៍ពួកគាត់ នោះពួកគាត់និងស្វែងរកការទាក់ទងកាន់តែជិតស្និទ្ធជាមួយលសាលា ដែលមានលក្ខណៈអំណោយផលពេលនោះពួកគាត់និងចូលរួមក្នុងសកម្មភាពរបស់សាលាកាន់តែសកម្ម និងមានប្រសិទ្ធភាពជាងមុន។ លើសពីនេះទៅទៀត សាលាត្រូវធ្វើយ៉ាងណាឱ្យពួកគាត់យល់ថា ពួកគាត់ជាមាតាបិតា ឬអាណាព្យាបាលដែលទទួលបានការគោរពពីសាលា ដោយរាល់ការបញ្ចេញមតិយោបល់ត្រូវបានសាលាស្តាប់ ហើយសាលានោះត្រូវជាកន្លែងមានសុវត្ថិភាព និងផ្តល់ការគាំទ្រដល់ការសិក្សារបស់កូនៗពួកគាត់ (Baig, 2022)។

## ២.២.៦ ភូមិ ឃុំមានសុវត្ថិភាព

តើភូមិឃុំសង្កាត់មានសុវត្ថិភាពមានគោលការណ៍ប៉ុន្មានចំនុច?អ្វីខ្លះ?

ភូមិ-ឃុំ មានសុវត្ថិភាព រួមមានលក្ខណៈសម្បត្តិ៩យ៉ាង៖ ១. គ្មានសកម្មភាពលួច ឆក់ប្លន់ គ្រប់ប្រភេទ។ ២. គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។ ៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ។

៤. គ្មានក្មេងទំនើង។ ៥. គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ, ការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ និងបទល្មើសគ្រប់ប្រភេទ។ ៦. គ្មានគ្រោះថ្នាក់ចរាចរណ៍។ ៧. គ្មានគ្រោះថ្នាក់ដោយគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ ៨. មានវិធានការណ៍ទប់ស្កាត់ គ្រប់គ្រង និងការឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព ៩. គ្មានការត្រួតពិនិត្យខុសច្បាប់ (រាជរដ្ឋាភិបាល ២០២១)។

## ២.៣ ប្រវត្តិនៃការសិក្សានៅកម្រិតទុតិយភូមិ

មរតកអប់រំរបស់ប្រទេសកម្ពុជាត្រូវបានឆ្លុះបញ្ចាំងតាមរយៈតាមរយៈការរីកចំរើនលើគ្រប់វិស័យនាសម័យមហានគរ ដោយមានប្រាសាទរាប់មិនអស់ទូទាំងប្រទេស។ តាមទស្សនៈអប់រំ គេមិនអាចកសាងប្រទេសមួយឱ្យឈានដល់អរិយធម៌ខ្ពស់កប់ពពកបែបនេះបានដោយពុំមានចូលរួមពីវិស្វករ អ្នកបច្ចេកទេស អ្នកវិទ្យាសាស្ត្រ និងអ្នកដឹកនាំប្រកបដោយចំណេះដឹង និងជំនាញខ្ពស់នោះបានឡើយ។ មនុស្សទាំងនោះពិតជាក្រុមបញ្ញវ័នដែលទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវមិនខានឡើយដោយឆ្លងកាត់សាលារៀនមានប្រព័ន្ធច្បាស់លាស់។ នៅសម័យនោះ ប្រទេសកម្ពុជាមានសកលវិទ្យាល័យសម្រាប់សិក្សាជាន់ខ្ពស់ និងមានអ្នកប្រាជ្ញខាងអក្សរសាស្ត្រ សាសនា ក្បួនច្បាប់ និងអ្នកចេះដឹងគ្រប់ជំនាញ។

ហេតុនេះ គេអាចសន្និដ្ឋានបានថា សាលាទុតិយភូមិនៅប្រទេសកម្ពុជាមានតាំងពីសម័យអង្គរមកម្ល៉េះ ព្រោះមុននិងឈានដល់មហាវិទ្យាល័យ គេត្រូវឆ្លងកាត់ថ្នាក់មធ្យមសិក្សាទុតិយភូមិជាមុនសិន (ស៊ន, ២០១៥)។ តែការអប់រំកម្រិតមធ្យមសិក្សា (secondary education) មានលក្ខណៈពេញលេញ និងទំនើបមានចាប់ពីឆ្នាំ១៩៣៥ ដោយមានសាលារៀនចំនួន០៣ និងមានសិស្សានុសិស្សចំនួន ៣៧០នាក់ ។

ក្រៅពីការសិក្សានៅកម្រិតមធ្យម ក៏មានផងដែរថ្នាក់បច្ចេកទេស និងរដ្ឋបាលដែលមានសាលារៀនចំនួន ០២ និងសិស្សានុសិស្សចំនួន ២៦០នាក់ ហើយចំនួនប្រជាជនកម្ពុជាសរុបនៅសម័យនោះមានចំនួន៣១៨៧០០០នាក់។ សម្រាប់សិស្សរៀននៅសម័យនោះ ពួកគេជាមនុស្សក្នុងគ្រួសាររាជវង្សានុវង្ស និងមនុស្សដែលចេញពីគ្រួសារអភិជន ដោយបន្ទាប់ពីចប់ថ្នាក់មធ្យមសិក្សារួច បើពួកគេចង់បន្តការសិក្សា

ថ្នាក់ឧត្តមសិក្សា ពួកគេត្រូវទៅរៀននៅទីក្រុងសៃហ្គន ហូជីមិញ ឬទីក្រុងប៉ារីសនាប្រទេសបារាំង (Slocomb, 2010)។

### ២.៣.១ ការអប់រំកម្រិតទុតិយភូមិក្រោយសម័យប៉ុលពត ដល់ឆ្នាំ ១៩៩៥

នៅសម័យប៉ុលពត អ្វីៗត្រូវបំផ្លាញខ្ទេចខ្ទីជាពិសេសគឺ ធនធានមនុស្សដែលជាកម្លាំងចលករចម្បងក្នុងការកសាងប្រទេស និងជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេស រហូតមានលើកជាពាក្យស្លោកមួយថា«អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ហើយអ្នកចេះតិចបង្រៀនអ្នកអត់ចេះសោះ»។ លុះក្រោយមករាជរដ្ឋាភិបាលបានកសាងថនធានមនុស្សជាបន្តបន្ទាប់ ពិសេសគឺការកសាងធនធានមនុស្សនៅកម្រិតទុតិយភូមិ ដោយបណ្តុះបណ្តាលគ្រូប្រមាណ ៣៥០០នាក់គិតត្រឹមដំណាច់ឆ្នាំ ១៩៩៥។ ស្របគ្នានេះដែរ ក៏មានសាលារៀនកម្រិតទុតិយភូមិចំនួន ៦១ និងសិស្សសរុបចំនួន ៤៣៥៦០ នាក់ (នាយកដ្ឋានបុគ្គលិក, ១៩៩៨)។

### ២.៣.២ ការអប់រំកម្រិតទុតិយភូមិសម័យបច្ចុប្បន្ន

ការអប់រំកម្រិតទុតិយភូមិជាការសិក្សាមួយយ៉ាងសំខាន់ដែលលផ្តល់ឱ្យសិស្សនូវបំណិនសម្បទា និងចរិយាសម្បទាដើម្បីឱ្យសិស្សានុសិស្សទាំងនោះត្រៀមខ្លួនសម្រាប់៖ ការបណ្តុះបណ្តាលបច្ចេកទេស ការអប់រំឧត្តមសិក្សា ឱកាសការងារ និងមុខរបរ/ការងារជាមួយនឹងបំណិនសតវត្សទី២១ និងបំណិនបដិវត្តន៍ឧស្សាហកម្ម៤.០ ។ ដោយមានការប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាល និងក្រសួងអប់រំយុវជន និងកីឡាបានធ្វើឱ្យមានកំណើនទាំងចំនួនសាលារៀន បុគ្គលិកអប់រំពិសេសសនៅកម្រិតទុតិយភូមិដេលមានសាលារៀនរហូតដល់ ៥៥៩ និងបុគ្គលិកអប់រំចំនួន ៣៣,៨៥៨នាក់ និងសាលបច្ចេកតេសចំនួន១៤នៅទៅទាំងប្រទេស (នាយកដ្ឋានប្រព័ន្ធពត៌មានគ្រប់គ្រងអប់រំ, ២០២១)។

សមាហរណកម្មបាននាំឱ្យប្រទេសជាតិនិមួយៗក្នុងពិភពលោកកាន់តែខិតជិតគ្នា និងផ្លាស់ប្តូរនូវបទពិសោធ ជំនាញនានាក្នុងបំណងបង្កើនការរីកចំរើនឱ្យប្រទេសរៀងៗខ្លួន។ ហើយការរីកចំរើនទាំងនោះ គេមិនអាចមើលរំលងឡើយនូវការចូលរួមរបស់វិស័យអប់រំ ពិសេសគឺការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ព្រោះថា ជាដំណាក់កាលសំខាន់មួយមុនពួកគេឈានជើងចូលថ្នាក់ឧត្តមសិក្សា ឬចាប់យកជំនាញបច្ចេកទេស។

## ២.៤ លទ្ធផលសិក្សា និងបញ្ហាប្រឈមនៅកម្រិតទុតិយភូមិ

### ២.៤.១ ការជ្រើសរើសសាលារៀន

ដោយសារសកលភាវូបនិយកម្មធ្វើឱ្យពិភពលោកក្លាយជា ពិភពលោកមួយ ភូមិមួយ (One World One Village) (Soars, 2022) ដែលនាំឱ្យវិស័យនានាមានការរីកចំរើន ក្នុងនោះក៏មានវិស័យអប់រំផងដែរ ហេតុមានការធ្វើឯកជនូបនិយកម្មលើសាលារៀនដែលបង្កលក្ខណៈងាយស្រួលក្នុងការជ្រើសរើសសាលាឱ្យកូនចៅរបស់ពលរដ្ឋរៀន ដោយអ្នកខ្លះជ្រើសយកសាលារៀនសាធារណៈ ខ្លះទៀតជ្រើសរើសយកសាលារៀនបង់ថ្លៃ។ យោងតាមការសិក្សាមួយដែលធ្វើឡើងដោយ Sonja Kosunen និង Alejandro Carrasco (2014) នៅប្រទេសហ្វាំងឡង់ និងប្រទេសឈីលីបានបង្ហាញថា កត្តាជ្រើសរើសសាលាឱ្យកូនរបស់ខ្លួនមានដូចជា កេរ៍ឈ្មោះរបស់សាលារៀននោះ និងឋានៈសង្គមរបស់គ្រួសារនោះឯង ។ស្រដៀងគ្នានេះដែរ មានការសិក្សាមួយផ្សេងទៀតបានបង្ហាញថា គ្រួសារភាគច្រើនបញ្ជូនទៅសាលាណាមួយដោយគិតលើសកម្មភាពឬ សមិទ្ធិផលសិក្សារបស់សិស្សដែលរៀននៅសាលានោះ។ ឪពុកម្តាយខ្លះទៀតក៏ផ្តល់តម្លៃដល់សមាសភាពសេដ្ឋកិច្ចសង្គមរបស់គ្រួសារខ្លួនដែលមានលក្ខណៈសមស្របទៅនឹងតម្លៃរបស់សាលារៀនដែលពួកគេត្រូវចំណាយ និង ទីតាំងរបស់សាលា។ ម្យ៉ាងទៀតក៏ផ្អែកលើកត្តាសេដ្ឋកិច្ចសង្គមរបស់គ្រួសារនិមួយៗផងដែរ ដោយពួកគេមិនសូវយកចិត្តទុកដាក់លើគុណភាពសាលារៀនណាស់ណាទេ ការចាំបាច់គឺបញ្ជូនកូនទៅសាលារៀន (Simon Burgess, 2014)។ មានការសិក្សាមួយផ្សេងទៀតដែរ ដែលធ្វើឡើងលើមាតាបិតាសិស្សចំនួន៥០០នាក់ បង្ហាញថា កត្តានាំឱ្យពួកគេជ្រើសរើសសាលាដោយសារ៖ ភាពងាយស្រួលក្នុងការទទួលបានពត៌មានពីសាលា ដំណើរការចុះឈ្មោះចូលរៀនមានលក្ខណៈអំណោយផល និងទីតាំងសាលាដែលសិស្សងាយស្រួលក្នុងការធ្វើដំណើរ។ ក្រៅពីនេះ នៅមានការសិក្សាស្រាវជ្រាវមួយផ្សេងទៀតដែលធ្វើឡើងនៅប្រទេសអារ៉ាប់រួម ( United Arab Emirates, UAE ) នាឆ្នាំ២០១៦ ដោយ Nafla បានបង្ហាញថា ដើម្បីឱ្យសាលាមានភាពទាក់ទាញ និងទទួលបានសិស្សជាប្រចាំ ព្រមទាំងអាចរក្សាសិស្សឱ្យនៅរៀនបានចប់ភូមិសិក្សាទាមទានូវកត្តាចំនួន ០៦គឺ ១.ការគ្រប់គ្រងបរិស្ថានសាលា

រៀន ២. ការគ្រប់គ្រងបុគ្គលិក ឬធនធានមនុស្ស ៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀន ៤. ការគ្រប់គ្រងរៀន និងបង្រៀន ៥. ទំនាក់ទំនងរវាងសាលារៀន និងអាណាព្យាបាលសិស្ស និងទី៦. ការចូលរួមរបស់មាតាបិតា និងសហគមន៍ទ្រទ្រង់សាលារៀននោះ។ ហេតុនេះគេអាចសន្និដ្ឋានបានថា សាលាមានចំនួនសិស្សប្រែប្រួលអាស្រ័យលើកត្តាដែលបានរៀបរាប់ខាងលើផ្អែកលើសម្មតិកម្មស្រាវជ្រាវមុនៗរបស់ស្រាវជ្រាវ។

## ២.៤.២ កត្តាបោះបង់ការសិក្សា

ដើម្បីរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសឱ្យដល់ចំណុចដៅរបស់សង្គមតាមផែនការ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយ និងវិធានការណ៍ជាច្រើនពិសេសគឺគោលនយោបាយលើវិស័យអប់រំ។ ព្រោះថាវិស័យនេះជាឆ្អឹងខ្នងទ្រទ្រង់ដល់ការរីកលូតលាស់របស់ប្រទេស ដែលគោលនយោបាយនោះមានដូចជាៈ គោលនយោបាយស្តីពីការសិក្សាពេញមួយជីវិត ដោយត្រូវបានកំណត់ជាច្បាប់រដ្ឋធម្មនុញមាត្រាទី ៦៥បានចែងថា «រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំបានទៅដល់ពលរដ្ឋគ្រប់រូប»។ ទោះមានការចែងក្នុងច្បាប់សម្រាប់ការជំរុញឱ្យទទួលបានការអប់រំហើយក្តី តែចំនួនសិស្សនៅកម្រិតទុតិយភូមិមានការថយចុះ ដែលជាកង្វល់រួម ព្រោះពួកគេជាយុវជន (យុវជនគឺ ជាពលរដ្ឋដែលមានអាយុចាប់ពី ១៥ ដល់៣០ឆ្នាំ ទាំងនៅលីវ និងមានគ្រួសារ) (រាជរដ្ឋាភិបាល ២០១៨) ។

យោងតាមលទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២០-២០២២ បានបញ្ជាក់ថា៖

អត្រាបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិមាន ៩,៨% គិតត្រឹមឆ្នាំ ២០២១។ តើមានមូលហេតុអ្វីខ្លះដែលនាំឱ្យសិស្សបោះបង់ការសិក្សា?។មានចំនុចជាច្រើនបានរួមចំណែកក្នុងការបោះបង់ការសិក្សារបស់សិស្សដែលមាន៖ កម្រិតអប់រំរបស់មាតាបិតា ចំនួនកូនច្រើនក្នុងបន្ទុកគ្រួសារ (Setyadharma, 2015)។ ជាមួយគ្នានេះដែរ មានការសិក្សានៅប្រទេសន័រវេបានបង្ហាញថា សិស្សដែលបោះបង់ការសិក្សាបណ្តាលមកពី៖ ១.ការសិក្សាត្រូវចំណាយថវិកាច្រើន ២.សិស្សានុសិស្សអាចចាប់ផ្តើមរៀនវិញបានក្រោយ

ពេលពួកគេបោះបង់ការសិក្សាអស់រយៈពេលណាមួយ (Simson, 2014)។ មានសិក្សាមួយទៀតដែលគេធ្វើឡើងនៅសហរដ្ឋអាមេរិកបានរកឃើញថា ការបោះបង់សិក្សារបស់សិស្សនៅកម្រិតទុតិយភូមិបណ្តាលមកពីកត្តាធំៗចំនួន២គឺ ១.ពួកគេបោះបង់ការសិស្សាដើម្បីរកប្រាក់ ២.ទោះពួកគេឈប់រៀនយូរប៉ុណ្ណាក្តី ក៏ពួកគេអាចចូលរៀនបានដែរ។ ក្នុងការសិក្សានេះគេបានផ្តល់អនុសិស្សចំនួន៤ដើម្បីរក្សាសិស្សឱ្យនៅរៀនហូតដល់ចប់ភូមិសិក្សាគឺ ១.ការរៀបចំបរិស្ថានសាលារៀន ២.របៀបរបបគ្រប់គ្រងសាលា ៣.ការស្វែងយល់ពីក្រុមជាតិសាសន៍របស់សិស្ស និងទី៤ .មើលលើទំនោររបស់សិស្ស (LAWTON, 1988)។ ក្រៅពីនេះ មានការសិក្សាមួយផ្សេងទៀតធ្វើឡើងនៅប្រទេសកាណាដា បានរកឃើញថា កត្តាទំនាក់រវាងគ្រូ និងសិស្សពិតបានរួនចំណែកដល់ការបោះបង់ចោលការសិក្សារបស់សិស្សពិតមែន ដោយវាទទួលខុសត្រូវចំនួន ១៤% ក្រៅពីកត្តាភេទ អាយុ សាសនា និងកត្តាសេដ្ឋកិច្ចសង្គម( (Rick N. Noble1 N. H., 2020)។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. សេចក្ដីផ្ដើម

វិធីសាស្ត្រស្រាវជ្រាវ( Research Design) ត្រូវបានគេកំនត់ថា ជាផែនការដើម្បីធ្វើការស្រាវជ្រាវ ហើយវាមានទំនាក់ទំនងទៅនឹងចំនុចចំនួន បីសំខាន់ៗដូចជា៖ទស្សនៈវិជ្ជា យុទ្ធសាស្ត្រនៃការស្វែងរកពត៌មាន និងវិធីសាស្ត្រដាក់លាក់នានាក្នុងការស្រាវជ្រាវ (Creswell, Mapping the Field of Mixed Methods Research, 2008)។ ក្នុងការស្រាវជ្រាវនេះមានកត្តាសំខាន់ៗចំនួនបីដែលអ្នកស្រាវជ្រាវត្រូវមានភាពច្បាស់លាស់គឺ ទីតាំងចិត្តសាស្ត្ររបស់អ្នកស្រាវជ្រាវ ការទទួលយកវិធីសាស្ត្រមកកែសម្រួលដើម្បីឱ្យមានសង្គតិភាពទៅនឹងស្ថានភាពជាក់ស្ដែងក្នុងតំបន់របស់អ្នកស្រាវជ្រាវ និងវិធីសាស្ត្រប្រមូលទិន្នន័យនិងការវិភាគទិន្នន័យ (Creswell, The Application of Mixed Methods Designs, December 2009)។

### ៣.១.១. វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សានេះធ្វើឡើងនៅរាជធានីភ្នំពេញដោយយកសាលារៀនចំណេះទូទៅរដ្ឋចំនួន ០៦ដែលមានចំនួនសិស្សកើនឡើង និងថយចុះក្នុងចំណោមវិទ្យាល័យទាំង ៤១ (នាយកដ្ឋានប្រព័ន្ធពត៌មានគ្រប់គ្រងអប់រំ ២០២២) ដោយជ្រើសរើសយកសាលាមធ្យមសិក្សាកម្រិតទុតិយភូមិដែលមានចំនួនសិស្សថយចុះចំនួន ០៣សាលា និងសាលាមធ្យមសិក្សាកម្រិតទុតិយភូមិដែលមានចំនួនសិស្សកើនឡើងចំនួន ០៣សាលាផងដែរដើម្បីធ្វើការប្រៀបធៀបគ្នាពីទស្សនៈ និងការយល់ឃើញរបស់ពួកគេ។

### ៣.១.២. ដែនកំណត់នៃការស្រាវជ្រាវ

គុណភាពនៃការស្រាវជ្រាវល្អ ឬមិនល្អ វាមិនអាស្រ័យតែលើភាពសមរម្យនៃវិធីសាស្ត្រស្រាវជ្រាវ និងឧបករណ៍ស្រាវជ្រាវតែមួយមុខនេះទេ តែវាក៏ត្រូវការពឹងផ្អែកលើយុទ្ធសាស្ត្រក្នុងការជ្រើសរើសសំណាកឱ្យបានត្រឹមត្រូវផងដែរ (A. Hoecker, 2009)ដោយគាត់បានលើកឡើងថា "សំណាកដែលគេជ្រើសរើស

យកមកស្រាវជ្រាវជាមនុស្សមួយក្រុម"។ ហើយភាគសំណាកដែលត្រូវយកមកធ្វើការសិក្សាស្រាវជ្រាវក្នុងនិក្ខេបបទនេះគឺ ភាគីពាក់ព័ន្ធដែលស្ថិតនៅកម្រិតកធ្យមសិក្សាទុតិយភូមិនៅតាមគ្រឹះស្ថានសិក្សាសាធារណៈនៅភូមិសាស្ត្ររាជធានីភ្នំពេញ។ ដោយមិនអាចចុះទៅសិក្សាលើមនុស្សទាំងអស់នៅរាជធានីភ្នំពេញ ហេតុនេះក្នុងនាមខ្ញុំបាទជាអ្នកស្រាវជ្រាវបានកំនត់យកមនុស្សមួយចំនួនក្នុងចំណោមពួកគេដើម្បីតំណាងឱ្យមនុស្សទាំងអស់នោះវិញដែលគេឱ្យឈ្មោះថា ភាគសំណាក។ ភាកសំណាកជាមនុស្សមួយក្រុមតូចតំណាងឱ្យមនុស្សមួយក្រុមធំ។ ក្នុងការសិក្សាស្រាវជ្រាវនេះ ប្រភពទិន្នន័យបែបបរិមាណជាភាគីពាក់ព័ន្ធយ៉ាងសំខាន់ដែលមានដូចតទៅ៖ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សដែលកំពុងរៀននៅថ្នាក់ទី១០ ១១និងទី១២ និងមាតាបិតា ឬអាណាព្យាបាល

- សិស្សនៅសាលាចំណេះទូទៅរដ្ឋដែលមានសិស្សថយចុះចំនួន ៣០នាក់ ដោយយកសិស្សថ្នាក់ទី១០ចំនួន ១០ នាក់ ថ្នាក់ទី១១ ចំនួន ១០ នាក់ និង ថ្នាក់ទី១២ ចំនួន ១០នាក់។
- សិស្សនៅសាលាចំណេះទូទៅរដ្ឋដែលមានសិស្សកើនឡើងចំនួន ៣០នាក់ ដោយយកសិស្សថ្នាក់ទី ១០ចំនួន ១០ នាក់ ថ្នាក់ទី១១ ចំនួន ១០ នាក់ និង ថ្នាក់ទី១២ ចំនួន ១០នាក់។
- លោកគ្រូ អ្នកគ្រូចំនួន ៣៦នាក់ ដោយជ្រើសរើសពីគ្រឹះស្ថានសិក្សាសាធារណៈកម្រិតទុតិយភូមិដែលមានចំនួនសិស្សថយចុះចំនួន១៨នាក់ និងគ្រឹះស្ថានសិក្សាសាធារណៈកម្រិតទុតិយភូមិដែលមានចំនួនសិស្សកើនឡើងចំនួន ១៨នាក់។
- អាណាព្យាបាលសិស្សចំនួន ៦០នាក់ដោយជ្រើសរើសចេញពីសាលាចំណេះទូទៅដែលមានចំនួនសិស្សថយចុះចំនួន ៣០នាក់ និងពីសាលាចំណេះទូទៅដែលមានសិស្សកើនឡើងចំនួន ៣០នាក់។

## ៣.២. វិធីសាស្ត្រស្រាវជ្រាវ និងឧបករណ៍ប្រមូលទិន្នន័យ

### ៣.២.១. វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាលើប្រធានបទ"ទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ នៅក្នុងរាជធានីភ្នំពេញ" ក្នុងគោលបំណងរកឱ្យឃើញពីបញ្ហាប្រឈម និងកត្តាផ្សេងៗដែលនាំឱ្យមានតំហាយសិស្សនៅតាមសាលាទាំងនោះ និងឈ្វេងយល់ពីទស្សនៈរបស់ភាគី

ពាក់ព័ន្ធលើសាលាដែលមានចំនួនសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកាន់តែកើនឡើងនៅរាជធានីភ្នំពេញសម្រាប់ធ្វើការសិក្សា។ បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតិចុះស្រាវជ្រាវពី វិទ្យាស្ថានជាតិអប់រំ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញរួចមក អ្នកសិក្សាបានចុះទៅតាមសាលាគោលដៅចំនួន ៦ដើម្បីស្នើសុំគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតាសិស្សដើម្បីបំពេញកម្រងសំនួរ និងឆ្លើយនូវសំនួរសម្ភាស។ ដោយយោងលើធនធាន និងពេលវេលាមានកំណត់ អ្នកស្រាវជ្រាវសម្រេចចិត្តជ្រើសរើសវិទ្យាល័យចំនួន៦នៅរាជធានីភ្នំពេញ ដោយបីសាលាជាសាលាដែលមានចំនួនសិស្សថយចុះ និងបីសាលាទៀតជាសាលាដែលមានចំនួនសិស្សកើនឡើង។

### ៣.២.២ ឧបករណ៍ប្រមូលទិន្នន័យ

- ការជ្រើសរើសដោយមិនចៃដន្យ ( Non- Probability Sample )
- ការជ្រើសរើសសាលារៀន ប្រើវិធី Quota sampling
- សិស្សនៅគ្រឹះស្ថានសិក្សាសាធារណៈដែលមានសិស្សថយចុះចំនួន 30នាក់ក្នុងមួយសាលា និងគ្រឹះស្ថានសិក្សាសិក្សាសាធារណៈដែលមានសិស្សកើនឡើងចំនួន ៣០នាក់ក្នុងសាលានិមួយៗព្រមទាំងលោកគ្រូ អ្នកគ្រូទាំងគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនចំនួន ៣៦នាក់។

## ៣.៣.កម្រងសំណួរ

អ្នកស្រាវជ្រាវជ្រើសរើសយកសំណួរបិទជំនួសឱ្យសំណួរបើកក្នុងការសាលសួរពត៌មានផ្ទាល់ខ្លួនរបស់ភាគសំណាក។ សំណួរបិទមានដូចជាប្រភេទសំណួរពហុជ្រើសរើសដោយអ្នកឆ្លើយងាយស្រួលឆ្លើយ និងចំណេញពេលវេលាក្នុងការឆ្លើយ ឬមិនចាំបាបច់សរសេរ ដោយកម្រងសំណួរទាំងនោះយកចេញពីៈ ១.Nafla (២០១៦) ក្រោមប្រធានបទ៖ ប្រសិទ្ធភាពសាលារៀន និង ការកែលំអរភាពជាអ្នកដឹកនាំ

២.ឧបករណ៍វង្វាយតម្លៃនាយកសាលាល្អ (២០១៦) ៣. ឧបករណ៍វង្វាយតម្លៃគ្រូបង្រៀនល្អ (២០១៦) និង៤. ឧបករណ៍វង្វាយតម្លៃសាលារៀនស្អាត (២០១៨)។ កម្រងសំណួរសំរាប់យកទៅប្រមូលទិន្នន័យចែកចេញជាផ្នែកៗដូចតទៅ៖

- កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងមាន០៥ផ្នែក
- កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូមាន០៥ផ្នែក
- កម្រងសំណួរសម្រាប់សិស្សមាន០៥ផ្នែក
- កម្រងសំណួរសម្រាប់មាតាបិតា អាណាព្យាបាលមាន ០៥ផ្នែក

ផ្នែកទី១នៃកម្រងសំណួរជាពត៌មានទូទៅរបស់អ្នកឆ្លើយដែលមានដូចជា៖ ភេទ អាយុ មុខរបរ បទពិសោធការងារ ទីកន្លែងការងារ កម្រិតវប្បធម៌ និងសញ្ញាប័ត្រ...។

ផ្នែកទី២នៃកម្រងសំណួរជាពត៌មានបង្ហាញពីសំណួរគោលដែលត្រូវចុះទៅប្រមូលទិន្នន័យពីភាគសំណាកដែលចែកចេញជា ០៥ផ្នែកដូចតទៅ៖

1. ការរៀបចំបរិស្ថានសាលារៀន
2. ការគ្រប់គ្រងបុគ្គលិក
3. ការគ្រប់គ្រងហិរញ្ញវត្ថុ
4. ការគ្រប់គ្រងការរៀន និងបង្រៀន
5. ផ្នែកទី០៣ នៃកម្រងសំណួរសួរទៅលើបញ្ហាប្រឈមដែលកើតមានចំពោះក្រុមសំណាកដែលត្រូវចុះទៅប្រមូលទិន្នន័យនោះឯង។

   ក្នុងសំណួរគោលនិមួយៗមានចែកចេញជាសំណួររងជាច្រើនទៀតទៅតាមលក្ខណៈវិនិច្ឆ័យដើម្បីឱ្យពត៌មានដែលប្រមូលបានមកយកទៅវិភាគមានលក្ខណៈសុក្រិត និងអាចទទួលយកបាន។ ជាឧទាហរណ៍ជាក់ស្តែង ចំណុច «ការរៀបចំបរិស្ថានសាលារៀន» ត្រូវបានចែកជា ០៦សំណួររងតទៅទៀត។ ចំណុច «ការគ្រប់គ្រងបុគ្គលិក »ត្រូវបានបែងចែកជា១៥ សំណួររងទៀត។ ចំណែកចំនុច «ការគ្រប់គ្រងហិរញ្ញវត្ថុ» ត្រូវបានចែកចេញជា ០៥សំណួររង ហើយចំនុចចុងក្រោយគឺ «ការគ្រប់គ្រងការរៀន និងបង្រៀន»ត្រូវបានចែកចេញជា ០៨សំណួររងទៀត។ សម្រាប់ផ្នែកទី០៣អំពីបញ្ហាប្រឈមត្រូវបានបែងចែកជា ១៤សំណួររង និងផ្នែកទី០៤ ជាកម្រងសំនួរសម្ភាស។

ដោយក្នុងផ្នែកទី ០១ជាសំនួរដែលសួរអំពីពត៌មានទូទៅ ឬផ្ទាល់ខ្លួនបានប្រើទំរង់ចំលើយជាពហុជ្រើសរើស និងបំពេញតាមរយៈការសរសេរ។ សម្រាប់សំណួរនៅផ្នែកទី០២និង ០៣ប្រើចម្លើយជាលក្ខណៈពហុជ្រើសរើសតាមទ្រង់០៥ចំលើយរបស់ Likert ( Likert scale )ដែលមានដូចតទៅ៖

- កម្រិតទី១ ៖មិនយល់ស្រប
- កម្រិតទី២ ៖យល់ស្របតិចតួច
- កម្រិតទី៣ ៖ពុំមានយោបល់
- កម្រិតទី៤ ៖យល់ស្រប
- កម្រិតទី៥ ៖យល់ស្របទាំងស្រុង

ផ្នែកទី៤ នៃកម្រងសំណួរសម្ភាស

## ៣.៤ ភាគសំណាក

សំណាកដែលត្រូវយកមកសិក្សាស្រាវជ្រាវក្នុងនិក្ខេបបទនេះមានចំនួន ០៤ក្រុមដូចជា៖

គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្សដែលជាភាគីពាក់ព័ន្ធនៅសាលាមធ្យមសិក្សាទុតិយភូមិសាធារណៈរបស់រដ្ឋនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ក្នុងការប្រមូលទិន្នន័យនេះមានសំណួរចំនួន ៤៥ត្រូវបានដាក់អោយភាគសំណាកឆ្លើយដែលមានចំនួនដូចជា៖

គណៈគ្រប់គ្រងចំនួន ០៦នាក់ លោកគ្រូ អ្នកគ្រូចំនួន ៣៦នាក់ សិស្សានុសិស្សចំនួន ១៨០នាក់ និងមាតាបិតា ឬអាណាព្យាបាលសិស្សចំនួន ៦០នាក់ដែលមានចំនួនសរុបស្មើនិង ២៨២នាក់។

បន្ទាប់ពីចុះប្រមូលទិន្នន័យរួច ក្រដាសដែលបានប្រមូលពីអ្នកឆ្លើយតបមានចំនួន ២៤៨ ច្បាប់ដែលស្មើនិង៨៧.៩៤ភាគរយ( ៨៧.៩៤%)។ តារាងខាងក្រោមនេះនឹងបង្ហាញពីចំនួនសំណាក់ដែលត្រូវចុះទៅប្រមូលទិន្នន័យ និងចំនួនសន្លឹកកិច្ចដែលបានទទួលពីអ្នកឆ្លើយតប និងអត្រាជាភាគរយរបស់អ្នកឆ្លើយតប។

| ភាគសំណាក | សន្លឹកដែលបានប្រគល់ | សន្លឹកដែលបានទទួល | ភាគរយ |
|---|---|---|---|
| គណៈគ្រប់គ្រង | ០៦ | ០៦ | ១០០% |

| | | | |
|---|---|---|---|
| លោកគ្រូ អ្នកគ្រូ | ៣៦ | ៣០ | ៨៣.៣៣% |
| សិស្ស | ១៨០ | ១៦០ | ៨៨.៨៨% |
| មាតាបិតា/អាណាព្យាបាល | ៦០ | ៥២ | ៨៦.៦៦% |
| សរុប | ២៨២ | ២៤៨ | ៨៧.៩៤% |

ភាគសំណាកដែលត្រូវចុះទៅប្រមូលទិន្នន័យមានទាំងពីរភេទគឺ ទាំងប្រុស ទាំងស្រី។ ចំនួននាក់ឆ្លើយតបលើផ្នែកគណៈគ្រប់គ្រងមានចំនួណ០៦នាក់ ក្នុងនោះមានស្រីចំនួន ០២នាក់ដែលស្មើនឹង ៣៣.៣៣% ប្រុសចំនួន០៤នាក់ដែលស្មើនឹង ៦៦.៦៦%។ ចំពោះលោកគ្រូ អ្នកគ្រូមានចំនួន៣០នាក់ ក្នុងនោះស្រីចំនួន០៧នាក់ដែលស្មើរនឹង ២១.៩០% ចំណែកប្រុសមានចំនួន ២៥នាក់ដែលស្មើនឹង ៧៨.១០%។ ក្រៅពីនេះនៅមានសសិស្សានុសិស្សដែលមានចំនួន១៦០នាក់ ដោយក្នុងនោះ ស្រីមានចំនួន ៨៨នាក់ដែលស្មើនឹង ៥៥% និងប្រុសមានចំនួន ៧២នាក់ដេលស្មើនឹង៥៤%។ ចំណោកមាតាបិតាឬអាណាព្យាបាលសិស្សវិញមានចំនួន ៥២នាក់ដោយក្នុងនោះស្រីចំនួន ២៩នាក់ដែលស្មើនិង ៥៥.៧៦ % និងប្រុសចំនួន ២៣នាក់ដែលស្មើនឹង ៤៤.២៣%។

| **ក្រុមសំណាក** | ភេទ | ចំនួនសំណាក | **ភាគរយ** |
|---|---|---|---|
| គណៈគ្រប់គ្រង | ប្រុស | ៤ | ៦៦.៦៦% |
| | ស្រី | ២ | ៣៣.៣៣% |
| លោកគ្រូ អ្នកគ្រូ | ប្រុស | ២៥ | ៧៨.១០% |
| | ស្រី | ៧ | ២១.៩០% |
| សិស្ស | ប្រុស | ៧៣ | ៤៣.៣០% |
| | ស្រី | ៨៨ | ៥៤.៧០% |
| មាតាបិតា/អាណាព្យាបាលសិស្ស | ប្រុស | ២៣ | ៤៤.២៣% |
| | ស្រី | ២៩ | ៥៥.៧៦% |
| សរុប | ២៤៨ | | |

## ៣.៤.១. ការសាកល្បងកម្រងសំណួរ

សារៈសំខាន់នៃការតេសសាកល្បងលើកម្រងសំណួរជារឿងដែលអ្នកស្រាវជ្រាវមិនត្រូវមើលរំលងឡើយ ដោយធ្វើលើសិស្សចំនួន ២០នាក់ និង គ្រូចំនួន ០៥នាក់។ ហេតុអ្វី?ការធ្វើតេសសាក

ល្បងលើកម្រងសំណួរអាចឱ្យអ្នកស្រាវជ្រាវដឹងពីគុណភាពនៃសំណួរ និងអាចកែសម្រួលសំណួរទាំងនោះ ដើម្បីឱ្យទិន្នន័យដែលទទួលបានសម្រេចទៅតាមគោលបំណងនៃការស្រាវជ្រាវ( Saunders et al, 2009)។ លើសពីនេះទៅទៀតវាក៏បានជួយអភិវឌ្ឍដំណើរការសមរម្យដើម្បីធ្វើការស្ទង់មតិឱ្យបានត្រឹមត្រូវ។ Bell (2005)បានគូសបញ្ជាក់ថា ការធ្វើតេសសាកល្បងកម្រងសំណួរអាចឱ្យអ្នកស្រាវជ្រាវដឹងនូវចំណុចដូចខាងក្រោម៖

- តើកម្រងសំណួរត្រូវប្រើរយៈពេលប៉ុន្មានក្នុងការបំពេញ?
- តើការណែនាំក្នុងកម្រងសំណួរមានភាពច្បាស់លាស់ដល់កម្រិតណា?
- តើសំណួរណាមិនច្បាស់លាស់ ឬធ្វើឱ្យអ្នកឆ្លើយមានការយល់ច្រឡំ?
- តើសំណួរណានាំឱ្យអ្នកឆ្លើយពិបាក?
- តើសំណួរណាគួរដកចេញ?
- ការរៀបចំកម្រងសំណួរនោះមានភាពច្បាស់លាស់ និងទាក់ទាញដែរឬទេ?

- កម្រងសំណួរបានតេស្តសាកល្បងជាមួយសិស្ស ២០នាក់

## ៣.៤.២.ក្រមសីលធម៌នៃការស្រាវជ្រាវ

ក្រមសីលធម៌គឺមានសារៈសំខាន់ណាស់សម្រាប់ការសិក្សាស្រាវជ្រាវ ពីព្រោះវាជានាប្រសិទ្ធភាពនៃការស្រាវជ្រាវ ក៏ដូចជាបង្កើនទំនុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយ មិនធ្វើឱ្យមានផលប៉ះពាល់ដល់អ្នកចូលរួមទេ និងរក្សាការសំងាត់។ ដើម្បីរក្សាក្រមសីលធម៌ យើងបានធ្វើការណែនាំខ្លួន ប្រាប់ពីគោលបំណង រយៈពេលសុំសម្ភាសន៍ឬសួរ ការសន្យាលើលក្ខណ្ឌមួយចំនួនដូចជា ការរក្សាការសម្ងាត់ជូនគាត់ ព័ត៌មានដែលទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតឡើយ។ ហើយរាល់ការសម្ភាសន៍ ឬសួរត្រូវបានសុំការអនុញ្ញាតិ និងមានការឯកភាពពីអ្នកដែលឆ្លើយតបការសម្ភាស ឬសួរ។ ក្នុងដំណើការសម្ភាសន៍ឬសួរ គឺបានជ្រើសរើសកន្លែងដែលមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ។ អ្នក

សម្អាស ឬសួរបានស្លៀកពាក់សមរម្យ ទឹកមុខស្រស់ស្រាយ ញញឹមរួសរាយ និងបង្ហាញនូវភាពស្និទ្ធស្នាល សម្ដីទន់ភ្លន់ និងអង្គុយតាមបែបបទគោលការណ៍របស់អ្នកសម្អាស។

# ជំពូកទី៤៖ លទ្ធផលនិងការពិភាក្សា

## ៤.១.សេចក្តីផ្តើម

ក្នុងជំពូក៤នេះ អ្នកសិក្សាស្រាវជ្រាវនិងធ្វើការបង្ហាញពីលទ្ធនៃការសិក្សាតាមរយៈការបំពេញកម្រងសំនួររបស់ជាតុសំណាកដែលមានដូចជា៖ គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូដែលបង្រៀននៅកម្រិតទុតិយភូមិ សិស្សានុសិស្សដែលកំពុងរៀននៅថ្នាក់ទី១០ , ១១ និង១២ និងមាតាបិតា ឬអាណាព្យាបាលសិស្សដែលមានកូនកំពុងរៀននៅថ្នាក់ទី ១០ ១១ និង១២ក្នុងរាជធានីភ្នំពេញអំពី

" **ទស្សនៈរបស់ភាគីពាក់ព័ន្ធលើការសិក្សានៅសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ ក្នុងរាជធានីភ្នំពេញ**»ក្នុងគោលបំនងស្វែងរកឱ្យឃើញពី ការយល់ឃើញរបស់ភាគីពាក់ព័ន្ធ និងសារៈសំខាន់នៃទស្សនៈទូទៅរបស់ពួកគេលើការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ កម្រងសំណួរពិតមានសារៈសំខាន់មិនអាចកាត់ថ្លៃបានក្នុងការប្រមូលទិន្នន័យពីសំណាកចំនួន២៨២នាក់ ហើយការវិភាគទិន្នន័យដែលបានប្រមូលមកក្នុងជំពូកនេះនិងឆ្លុះបញ្ចាំងឱ្យឃើញពីភាពផ្សេងគ្នា ស្រដៀងគ្នាដែលនឹងលេចឡើងតាមរយៈសំណាក់ទាំង០៤ក្រុមផ្សេងគ្នានេះមិនខានឡើយ។

### ៤.១.១ លទ្ធផលនៃការវិភាគទិន្នន័យផ្នែកទី១

ផ្នែកទី១នេះគឺជាការបកស្រាយលើកម្រងសំនួរស្រាវជ្រាវទី១ «**តើមានបញ្ហាប្រឈមអ្វីខ្លះដែលនាំឱ្យមានតំថយសិស្សនៅសាលាទាំងនោះ?** » នៅតាមសាលារៀនគោលដៅដែលត្រូវចុះទៅប្រមូលទិន្នន័យ។ ឧបករណ៍សម្រាប់ការស្រាវជ្រាវនេះ គឺជាកម្រងសំណួរដែលបានដកស្រង់ខ្លឹមសារ និងកែសម្រួលចេញពីឯកសារ Al Ahb abi (ឆ្នាំ ២០១៦) ឧបករណ៍វាយតម្លៃសាលារៀនស្អាត (ឆ្នាំ២០១៨) ឧបករណ៍វាយតម្លៃនាយកសាលាខ្ពស់ (ឆ្នាំ២០១៦) ឧបករណ៍វាយតម្លៃគ្រូបង្រៀនខ្ពស់ (ឆ្នាំ២០១៦)របស់ក្រសួងអប់រំ

យុវជន និងកីឡាដែលចែកចេញជា ០៥ ផ្នែក និងមាន ៤៣ចំណុច។ ការវិភាគទិន្នន័យនេះវិភាគលើ **តម្លៃមធ្យម និងគម្លាតស្តង់ដា** ដែលត្រូវបានកំណត់តម្លៃដូចតទៅ (ដារី ២០២១)៖

- តម្លៃ ១.00-១.៥0 កម្រិតទាបបំផុត
- តម្លៃ ១.៥១-២.៥0 កម្រិតទាប
- តម្លៃ ២.៥១-៣.៥0 កម្រិតមធ្យម
- តម្លៃ ៣.៥១-៤.៥0 កម្រិតខ្ពស់
- តម្លៃ ៤.៥១-៥.00 កម្រិតខ្ពស់បំផុត

លទ្ធផលនៃផ្នែកទី០១ ត្រូវបានបង្ហាញក្នុងតារាងដូចខាងក្រោម៖

***តារាង 1 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើទស្សនៈរបស់ភាគីពាក់ព័ន្ធចំពោះសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកាន់តែកើនឡើង តាមទស្សនៈរបស់ភាគីពាក់ព័ន្ធ តាមចំណុចនិមួយៗ (n= ២៤៧)***

| ល.រ | **ខ្លឹមសារសំណួរ** | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សាលាមានទីធ្លាធំទូលាយដោយមានការរៀបចំបរិស្ថានបានខ្ពស់ | ៣.៧៥ | ១.០៧ | ខ្ពស់ |
| ២ | សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា | ៣.៨៥ | ១.០៦ | ខ្ពស់ |
| ៣ | សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា | ៣.៩៧ | ១.០៦ | ខ្ពស់ |
| ៤ | សាលាមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់ទាំងសិស្សប្រុស និងសិស្សស្រី | ៣.៧០ | ១.០៩ | ខ្ពស់ |
| ៥ | សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ | ២.៩៦ | ១.២៤ | ខ្ពស់ |
| ៦ | បន្ទប់ទឹកមានទឹក និងពន្លឺគ្រប់គ្រាន់ | ៣.៤៤ | ១.១៦ | មធ្យម |

| | | | | |
|---|---|---|---|---|
| ៧ | នាយកធ្វើជាគំរូផ្នែកឥរិយាបថដល់លោកគ្រូ អ្នកគ្រូ | ៣.៧០ | ០.៩៩ | ខ្ពស់ |
| ៨ | នាយកកំណត់នូវអ្វីដែលអាចជំរុញ និងលើកទឹកចិត្តដល់បុគ្គលិកក្នុងសាលាខ្លួន។ | ៣.៦៧ | ១.០១ | ខ្ពស់ |
| ៩ | នាយកមានទំនាក់ទំនងខ្ពស់ និងវិជ្ជមានជាមួយបុគ្គលិករបស់ខ្លួន | ៣.៧០ | ០.៩១ | ខ្ពស់ |
| ១០ | នាយកទទួលស្គាល់ និងឱ្យតម្លៃលើការខិតខំប្រឹងប្រែងរបស់បុគ្គលិករបស់ខ្លួន | ៣.៧៩ | ០.៩១ | ខ្ពស់ |
| ១១ | នាយកប្រគល់ភារកិច្ច និងអាជ្ញាដល់បុគ្គលិកដែលមានសមត្ថភាព | ៣.៦៣ | ០.៩១ | ខ្ពស់ |
| ១២ | នាយកសម្រេចបានស្នាដៃជាច្រើនជូនដល់សាលា | ៣.៥៧ | ០.៩៤ | ខ្ពស់ |
| ១៣ | នាយកបង្កើតបរិយាកាសវិជ្ជមានសម្រាប់គ្រប់គ្នា | ៣.៤២ | ១.០៩ | មធ្យម |
| ១៤ | នាយកផ្តល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ | ៣.៧៩ | ០.៩៦ | ខ្ពស់ |
| ១៥ | នាយកផ្តល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ | ៣.៦៩ | ០.៩២ | ខ្ពស់ |
| ១៦ | នាយកធ្វើជាអ្នកកណ្តាលក្នុងការដោះស្រាយឬជម្លោះដោយមិនលំអៀងទៅខាងភាគីណាមួយឡើយ | ៣.៦៥ | ០.៩៩ | ខ្ពស់ |
| ១៧ | នាយកបានដឹកនាំធ្វើផែនការថវិកា និងថវិកាសកម្មភាពសម្រាប់អភិវឌ្ឍសាលារៀន | ៣.៣០ | ១.១៧ | មធ្យម |
| ១៨ | នាយកបានដឹកនាំធ្វើផែនការសកម្មភាពប្រចាំឆ្នាំយ៉ាងទៀងទៀត | ៣.៣៩ | ១.០២ | មធ្យម |
| ១៩ | នាយកបានដឹកនាំធ្វើផែនការដោយមានភាគីច្រើនចូលរួម | ៣.៣៨ | ០.៩៧ | មធ្យម |
| ២០ | នាយករៀបចំផែនការ និងស្វែងរកប្រភពមូលនិធិនានាសម្រាប់កែលម្អសាលារៀន។ | ៣.៤៧ | ១.៥៥ | មធ្យម |

| | | | | |
|---|---|---|---|---|
| ២១ | នាយកបានបង្កើតគណកម្មការត្រួតពិនិត្យចំណាយ និងវាយតម្លៃគុណភាពទំនិញ | ៣.១៧ | ១.១៣ | មធ្យម |
| ២២ | នាយកមានកិច្ចសហប្រតិបត្តិការខ្ពស់ជាមួយគ្រូៗក្នុងការធ្វើផែនការរៀន និងបង្រៀនដើម្បីកំណត់គោលបំណងដែលសាលាចង់បាន | ៣.៥២ | ០.៩៧ | ខ្ពស់ |
| ២៣ | សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស | ៣.៣៦ | ១.១២ | មធ្យម |
| ២៤ | នាយកបែងចែកសេវាបង្រៀនស្របតាមឯកទេស និងគុណវុឌ្ឍិរបស់គ្រូ | ៣.៦៦ | ១.០១ | ខ្ពស់ |
| ២៥ | នាយកបែងចែកសេវាបង្រៀនស្របតាមឯកទេស និងគុណវុឌ្ឍិរបស់គ្រូ | ៣.៤៧ | ០.៩៩ | មធ្យម |
| ២៦ | គ្រូយកចិត្តទុកដាក់លើការរីកចំរើនរបស់សិស្សទាំងផ្នែកបុគ្គលិកលក្ខណៈ បញ្ញាស្មារតី សីលធម៌ និងរបៀបរបបប្រាស្រ័យទាក់ទងក្នុងសង្គម | ៣.៦៣ | ០.៩៩ | ខ្ពស់ |
| | | | | |
| ២៧ | នាយកត្រួតពិនិត្យកិច្ចការរដ្ឋបាលរបស់លោកគ្រូ អ្នកគ្រូ | ៣.៥២ | ០.៩២ | ខ្ពស់ |
| ២៨ | នាយកធ្វើថ្នាក់និទស្សន៍លើសកម្មភាពបង្រៀន និងរៀននៅតាមថ្នាក់ | ៣.៥០ | ០.០៧ | មធ្យម |
| ២៩ | នាយកវាយតម្លៃការរៀបចំផែនការបង្រៀន និងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូអ្នកគ្រូ | ៣.៥៤ | ០.៩៣ | ខ្ពស់ |
| **សរុប** | | **3.55** | **1.04** | **ខ្ពស់** |

តាមតារាងខាងលើ លទ្ធផលបង្ហាញថា ទស្សនៈរបស់ភាគីពាក់ព័ន្ធដែលមាន៖ គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាលសិស្សនៅកម្រិតទុតិយភូមិ

ជារួមក្នុងកម្រិត «ខ្ពស់» (M:3.៥៥ និង SD: 1.04)។ បើមើលតាមរៀងតាមលំដាប់តម្លៃមធ្យម ខ្លឹមសារចំនុចចំនួនបីដែលមានតម្លៃខ្ពស់ជាងគេនោះគឺ៖

ចំនុចទី៣ «សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា» ស្ថិតក្នុងកម្រិតខ្ពស់ដោយតម្លៃមធ្យម (M:៣.៩៧ និង SD:១.០៦)។

ចំនុចទី២ «សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា»ស្ថិតក្នុងលំដាប់ខ្ពស់ដោយតម្លៃ M:៣.៨៥ និងSD: ១.០៦។

ចំនុចទី១៤ «នាយកផ្តល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ» ស្ថិតក្នុងលំដាប់ខ្ពស់ដោយតម្លៃ M: ៣.៧៩ និងSD: ០.៩៧។ ផ្ទុយទៅវិញ បើគេរៀងលំដាប់តាមតម្លៃមធ្យម ដែលទាបជាងគេមានបួនចំណុចផងដែរដែលមានដូចតទៅ៖

ចំណុចទី ៤៣ «សាលាមិនមានទំនាក់ទំនងខ្ពស់រវាងគ្រូ សិស្ស និងអាណាព្យាបាល»ស្ថិតក្នុងលំដាប់ទាបដោយតម្លៃមធ្យម M:១.៩២ និងSD:១.០៩

ចំណុចទី៣៨ «សាលាបានយកលុយពីសិស្សពេលប្រឡង(ប្រចាំខែ ឆមាស ឬផ្សេងៗ) និងមិនបានផ្តល់ចំណាត់ថ្នាក់តាមសមត្ថភាពជាក់ស្តែងរបស់សិស្សទេ» ស្ថិតក្នុងលំដាប់ទាបដោយតម្លៃមធ្យម M:១.៩១ និងSD:១.២២

ចំណុចទី ៣៩ «បានគាបសិស្សឱ្យរៀនក្រៅម៉ោង» ស្ថិតក្នុងលំដាប់ទាបដោយតម្លៃមធ្យម M១.៨៦ និងSD:១.១៥

ចំណុចទី ៤០ »សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ»ស្ថិតក្នុងលំដាប់ទាបដោយតម្លៃមធ្យម M១.៨១ និងSD:១.១៧។ លទ្ធផលខាងលើ បង្ហាញពីទស្សនៈរួមរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិ តែលទ្ធផលតាមផ្នែកទាំង ៥នឹងបង្ហាញនៅតាមតារាងខាងក្រោមជាបន្តបន្ទាប់៖

*តារាង 2 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងអត្ថន័យលើការរៀបចំបរិស្ថានសាលារៀនតាមទស្សនៈរបស់*

*គណៈគ្រប់គ្រងសាលារៀន*

| ល.រ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សាលាមានទីធ្លាធំទូលាយដោយមានការរៀបចំបរិស្ថានបានខ្ពស់ | 4.17 | 0.40 | ខ្ពស់ |
| ២ | សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា | 4.33 | 0.51 | ខ្ពស់ |
| ៣ | សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា | 4.50 | 0.54 | ខ្ពស់ |
| ៤ | សាលាមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់ទាំងសិស្សប្រុស និងសិស្សស្រី | 4.00 | 1.54 | ខ្ពស់ |
| ៥ | សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ | 4.00 | 1.09 | ខ្ពស់ |
| ៦ | បន្ទប់ទឹកមានទឹក និងពន្លឺគ្រប់គ្រាន់ | 4.33 | 0.51 | ខ្ពស់ |
| **សរុប** | | 4.22 | 0.77 | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការរៀបចំបរិស្ថានសាលារៀន ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» (មធ្យម = 4.22 , គម្លាតស្តង់ដា = 0.77 )។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « ខ្ពស់ប» ដូចគ្នា។ ដូចនេះលទ្ធផលបង្ហាញថា ការរៀបចំសាលាបរិស្ថានសាលារៀនពិតជារៀបចំបានខ្ពស់ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី៣«សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា( M:4.50, SD:0.54 )» និង«សូចនាករទី២សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា( M:4.33, SD: 0.51»។ ក្រៅពីនេះស្ថិតនៅក្នុងកម្រិតចង្អុលបង្ហាញប្រហាក់ប្រហែលគ្នាដោយមានតម្លៃមធ្យមរៀងគ្នា ដោយកម្រិតចង្អុលបង្ហាញទាបបំផុតគឺ សូចនាករទី៤«សាលាមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់ទាំងសិស្សប្រុស និងសិស្សស្រី (M:4.00, SD:1.54» និងសូចនាករទី៥ «សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ (M:4.00,SD: 1.09)»។ ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 3 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងអត្ថន័យលើការរៀបចំបរិស្ថានសាលារៀន តាមទស្សនៈរបស់គ្រូ*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សាលាមានទីធ្លាធំទូលាយដោយមានការរៀបចំបរិស្ថានបានខ្ពស់ | 4.07 | 0.78 | ខ្ពស់ |
| ២ | សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា | 4.00 | 0.64 | ខ្ពស់ |
| ៣ | សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា | 3.93 | 1.01 | ខ្ពស់ |
| ៤ | សាលាមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់ទាំងសិស្សប្រុស និងសិស្សស្រី | 3.63 | 0.99 | ខ្ពស់ |
| ៥ | សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ | 2.80 | 1.32 | ខ្ពស់ |
| ៦ | បន្ទប់ទឹកមានទឹក និងពន្លឺគ្រប់គ្រាន់ | 3.80 | 0.71 | ខ្ពស់ |
| **សរុប** | | **3.70** | **0.91** | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការរៀបចំបរិស្ថានសាលារៀន ជារួមស្ថិតក្នុងកម្រិត « ខ្ពស់» (មធ្យម =3.70 , គម្លាតស្តង់ដា = 0.91 )។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» ច្រើនជាងកម្រិតចង្អុលផ្សេងទៀត។ ដូចនេះលទ្ធផលបង្ហាញថា ការរៀបចំសាលាបរិស្ថានសាលារៀនពិតជារៀបចំបានខ្ពស់ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី១«សាលាមានទីធ្លាធំទូលាយដោយមានការរៀបចំបរិស្ថានបានខ្ពស់(M:4.07, SD: 0.78) » និងសូចនាករទី២ សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា(M: 4.00, SD: **0.91**)»។ ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដែលការអនុវត្តក្នុងការរៀបចំបរិស្ថានសាលារៀននៅមានកម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នោះគឺសូចនាករទី៥ «សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ (M: 2.80, SD:1.32)»។ ក្រៅពីនេះស្ថិតនៅក្នុងកម្រិតចង្អុលបង្ហាញប្រហាក់ប្រហែលគ្នាដោយមានតម្លៃមធ្យមរៀងគ្នា។ ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀន

អនុវត្តមិនទាន់បានខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 4 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងអត្ថន័យ លើការរៀបចំបរិស្ថានសាលារៀន តាមទស្សនៈរបស់សិស្ស*

| ល រ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សាលាមានទីធ្លាធំទូលាយដោយមានការរៀបចំបរិស្ថានបានខ្ពស់ | 3.70 | 1.12 | ខ្ពស់ |
| ២ | សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា | 3.85 | 1.12 | ខ្ពស់ |
| ៣ | សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា | 3.96 | 1.12 | ខ្ពស់ |
| ៤ | សាលាមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់ទាំងសិស្សប្រុស និងសិស្សស្រី | 3.64 | 1.14 | ខ្ពស់ |
| ៥ | សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ | 2.99 | 1.23 | ខ្ពស់ |
| ៦ | បន្ទប់ទឹកមានទឹក និងពន្លឺគ្រប់គ្រាន់ | 3.36 | 1.22 | ខ្ពស់ |
| **សរុប** | | **3.58** | **1.16** | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការរៀបចំបរិស្ថានសាលារៀន ជារួមស្ថិតក្នុងកម្រិត « ខ្ពស់» (មធ្យម = **3.58**, គម្លាតស្តង់ដា = **1.16** )។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» ច្រើនជាងកម្រិតចង្អុលផ្សេងទៀត។ ដូចនេះលទ្ធផលបង្ហាញថា ការរៀបចំសាលាបរិស្ថានសាលារៀនពិតជារៀបចំបានខ្ពស់ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី៣ «សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា( M:3.96, SD: 1.12 )» និង

សូចនាករទី ២«សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា ( M: 3.85, SD: 1.12 )»។ ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដែលការអនុវត្តក្នុងការរៀបចំបរិស្ថានសាលារៀននៅមាន

កម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នោះគឺសូចនាករទី៥ «សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ ( M: 2.99, SD: 1.23 )» ។ក្រៅពីនេះស្ថិតនៅក្នុងកម្រិតចង្អុលបង្ហាញប្រហាក់ប្រហែលគ្នាដោយមានតម្លៃមធ្យមរៀងគ្នា។ ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានខ្ពស់ស្របទៅតាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 5 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការរៀបចំបរិស្ថានសាលារៀន តាមទស្សនៈរបស់មាតាបិតា ឬអាណាព្យាបាល*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សាលាមានទីធ្លាធំទូលាយដោយមានការរៀបចំបរិស្ថានបានខ្ពស់ | 3.65 | 1.10 | ខ្ពស់ |
| ២ | សាលាមានម្លប់ដើមឈើ និងបង់អង្គុយសម្រាប់ឱ្យសិស្សធ្វើការស្វ័យសិក្សា | 3.69 | 1.11 | ខ្ពស់ |
| ៣ | សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា | 3.94 | 0.93 | ខ្ពស់ |
| ៤ | សាលាមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់ទាំងសិស្សប្រុស និងសិស្សស្រី | 3.85 | 0.91 | ខ្ពស់ |
| ៥ | សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ | 2.85 | 1.21 | ខ្ពស់ |
| ៦ | បន្ទប់ទឹកមានទឹក និងពន្លឺគ្រប់គ្រាន់ | 3.35 | 1.18 | ខ្ពស់ |
| **សរុប** | | **3.55** | **1.07** | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការរៀបចំបរិស្ថានសាលារៀន ជារួមស្ថិតក្នុងកម្រិត « ខ្ពស់» ( មធ្យម =**3.55** , គម្លាតស្តង់ដា = **1.07** ) ។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» ច្រើនជាងកម្រិតចង្អុលផ្សេងទៀត។ ដូចនេះលទ្ធផលបង្ហាញថា ការរៀបចំសាលាបរិស្ថាន

សាលារៀនពិតជារៀបចំបានខ្ពស់ដោយមានសូចនាករចំនួន៣គឺ៖ សូចនាករទី៣«សាលាមានបន្ទប់ទឹកសម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីគ្នា(M: 3.94 , SD: 0.93 » និងសូចនាករទី៤

«សាលាមានបន្ទប់ទឹកគ្រប់គ្រាន់សម្រាប់ទាំងសិស្សប្រុស និងសិស្សស្រី (M: 3.85, SD: 0.91)» ។ ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដេលការអនុវត្តក្នុងការរៀបចំបរិស្ថានសាលារៀននៅមានកម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នោះគឺសូចនាករទី៥ «សាលាមានការដាក់វេនសម្អាតបន្ទប់ទឹកជាប្រចាំ (M: 2.85, SD: 1.21)»។ ក្រៅពីនេះស្ថិតនៅក្នុងកម្រិតចង្អុលបង្ហាញប្រហាក់ប្រហែលគ្នាដោយមានតម្លៃមធ្យមរៀងគ្នា។ ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តមិនទាន់បានខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 6 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញសរុបតាមទស្សនៈភាគីទាំង ៤*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | គណៈគ្រប់គ្រងសាលារៀន | 4.22 | 0.77 | ខ្ពស់ |
| ២ | គ្រូ | 3.70 | 0.91 | ខ្ពស់ |
| ៣ | សិស្ស | 3.58 | 1.16 | ខ្ពស់ |
| ៤ | មាតាបិតា ឬអាណាព្យាបាល | 3.55 | 1.07 | ខ្ពស់ |
| **សរុប** | | **3.76** | **0.97** | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការរៀបចំបរិស្ថានសាលារៀន ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» (មធ្យម = **3.76** , គម្លាតស្តង់ដា = **0.97** )។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» ដូចគ្នា ដោយមានតម្លៃដូចតទៅ៖ គណៈគ្រប់គ្រងសាលារៀនក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» (M: 4.22, SD: 0.77) គ្រូស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់» (M: 3.70, SD: 0.91) សិស្សស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» (M: 3.58, SD: 1.16) និងចុងក្រោយគឺមាតាបិតា ឬអាណា

ព្យាបាលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» ( M: 3.55, SD:1.07 ) ។ ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 7 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់គណៈគ្រប់គ្រង*

| ល រ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៧ | នាយកធ្វើជាគំរូផ្នែកឥរិយាបថដល់លោកគ្រូ អ្នកគ្រូ | 4.00 | 1.54 | ខ្ពស់ |
| ៨ | នាយកកំណត់នូវអ្វីដែលអាចជំរុញ និងលើកទឹកចិត្តដល់បុគ្គលិករបស់ខ្លួន។ | 4.17 | 0.75 | ខ្ពស់ |
| ៩ | នាយកមានទំនាក់ទំនងល្អ និងវិជ្ជមានជាមួយបុគ្គលិករបស់ខ្លួន | 4.00 | 1.09 | ខ្ពស់ |
| ១០ | នាយកទទួលស្គាល់ និងឱ្យតម្លៃលើការខិតខំប្រឹងប្រែងរបស់បុគ្គលិករបស់ខ្លួន | 3.50 | 1.64 | ខ្ពស់ |
| ១១ | នាយកប្រគល់ភារកិច្ច និងអាជ្ញារដល់បុគ្គលិកដែលមានសមត្ថភាព | 4.00 | 1.09 | ខ្ពស់ |
| ១២ | នាយកសម្រេចបានស្នាដៃជាច្រើនជូនដល់សាលា | 3.83 | 1.16 | ខ្ពស់ |
| ១៣ | នាយកបង្កើតបរិយាកាសវិជ្ជមានសម្រាប់គ្រប់គ្នា | 4.00 | 1.09 | ខ្ពស់ |
| ១៤ | នាយកផ្តល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ | 4.00 | 1.09 | ខ្ពស់ |
| ១៥ | នាយកទប់ស្កាត់រាល់បញ្ហា និងព្យាយាមធ្វើឱ្យបញ្ហាពីធំមកតូច | 4.33 | 0.51 | ខ្ពស់ |
| ១៦ | នាយកធ្វើជាអ្នកកណ្តាលក្នុងការដោះស្រាយ ឬជម្លោះដោយមិនលំអៀងទៅខាងភាគីណាមួយឡើយ | 3.50 | 1.64 | ខ្ពស់ |

| **សរុប** | **4.09** | **1.37** | ខ្ពស់ |
|---|---|---|---|

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា **ការគ្រប់គ្រងបុគ្គលិក** ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» (មធ្យម =**4.09** , គម្លាតស្តង់ដា = **1.37** )។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « ខ្ពស់» ដូចគ្នា។ ដូចនេះលទ្ធផលបង្ហាញថា**ការគ្រប់គ្រងបុគ្គលិក** ពិតជាគ្រប់គ្រងបានខ្ពស់ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី១៥ «នាយកទប់ស្កាត់រាល់បញ្ហា និងព្យាយាមធ្វើឱ្យបញ្ហាពីធំមកតូច (M: 4.33, SD: 0.51» និងសូចនាករទី៨ «នាយកកំណត់នូវអ្វីដែលអាចជំរុញ និងលើកទឹកចិត្តដល់បុគ្គលិករបស់ខ្លួន (M: 4.17, SD: 0.75។ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដេលការអនុវត្តក្នុងការរៀបចំបរិស្ថានសាលារៀននៅមានកម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នោះគឺសូចនាករទី១៦ ដោយកម្រិតចង្អុលបង្ហាញស្ថិតក្នុងកម្រិតមធ្យមដោយមានសូចនាករនោះនិយាយអំពី «នាយកធ្វើជាអ្នកកណ្តាលក្នុងការដោះស្រាយ ឬជម្លោះដោយមិនលំអៀងទៅខាងភាគីណាមួយឡើយ (M: 3.50, SD: 1.64)»។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង ៩ ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ ការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់លោកគ្រូ អ្នកគ្រូ*

| ល.រ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៧ | នាយកធ្វើជាគំរូផ្នែកឥរិយាបថដល់លោកគ្រូ អ្នកគ្រូ | 4.00 | 1.54 | ខ្ពស់ |
| ៨ | នាយកកំណត់នូវអ្វីដែលអាចជំរុញ និងលើកទឹកចិត្តដល់បុគ្គលិករបស់ខ្លួន។ | 4.17 | 0.75 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ៩ | នាយកមានទំនាក់ទំនងល្អ និងវិជ្ជមានជាមួយបុគ្គលិករបស់ខ្លួន | 4.00 | 1.09 | ខ្ពស់ |
| ១០ | នាយកទទួលស្គាល់ និងឱ្យតម្លៃលើការខិតខំប្រឹងប្រែងរបស់បុគ្គលិករបស់ខ្លួន | 3.50 | 1.64 | មធ្យម |
| ១១ | នាយកប្រគល់ភារកិច្ច និងអាជ្ញារដល់បុគ្គលិកដែលមានសមត្ថភាព | 4.00 | 1.09 | ខ្ពស់ |
| ១២ | នាយកសម្រេចបានស្នាដៃជាច្រើនជូនដល់សាលា | 3.83 | 1.16 | ខ្ពស់ |
| ១៣ | នាយកបង្កើតបរិយាកាសវិជ្ជមានសម្រាប់គ្រប់គ្នា | 4.00 | 1.09 | ខ្ពស់ |
| ១៤ | នាយកផ្តល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ | 4.00 | 1.09 | ខ្ពស់ |
| ១៥ | នាយកទប់ស្កាត់រាល់បញ្ហា និងព្យាយាមធ្វើឱ្យបញ្ហាពីធំមកតូច | 4.33 | 0.51 | ខ្ពស់ |
| ១៦ | នាយកធ្វើជាអ្នកកណ្តាលក្នុងការដោះស្រាយ ឬជម្លោះដោយមិនលំអៀងទៅខាងភាគីណាមួយឡើយ | 3.50 | 1.64 | មធ្យម |
| **សរុប** | | 3.93 | 1.16 | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងបុគ្គលិក ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» (M: 3.93, SD: 1.16)។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « ខ្ពស់» ដូចគ្នា។ ដូចនេះលទ្ធផលបង្ហាញថា ការគ្រប់គ្រងបុគ្គលិក ពិតជាគ្រប់គ្រងបានខ្ពស់ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី១៥ «នាយកទប់ស្កាត់រាល់បញ្ហា និងព្យាយាមធ្វើឱ្យបញ្ហាពីធំមកតូច ( M: 4.33, SD: 0.51» និងសូចនាករទី៨ «នាយកកំណត់នូវអ្វីដែលអាចជំរុញ និងលើកទឹកចិត្តដល់បុគ្គលិករបស់ខ្លួន ( M: 4.17, SD: 0.75)។ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដេលការអនុវត្តក្នុងការរៀបចំបរិស្ថានសាលារៀននៅមានកម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នោះគឺសូចនាករទី១៦ ដោយកម្រិតចង្អុលបង្ហាញស្ថិតក្នុងកម្រិតមធ្យមដោយមានសូចនាករនោះនិយាយអំពី «នាយកធ្វើជាអ្នកកណ្តាលក្នុងការដោះស្រាយឬជម្លោះដោយមិនលំអៀងទៅខាងភាគីណាមួយឡើយ ( M: 3.50, SD: 1.64)»។ ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបាន

ខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង ៩ ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់សិស្ស*

| ល រ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៧ | នាយកធ្វើជាគំរូផ្នែកឥរិយាបថដល់លោកគ្រូ អ្នកគ្រូ | 3.68 | 0.96 | ខ្ពស់ |
| ៨ | នាយកកំណត់នូវអ្វីដែលអាចជំរុញ និងលើកទឹកចិត្តដល់បុគ្គលិករបស់ខ្លួន។ | 3.70 | 0.93 | ខ្ពស់ |
| ៩ | នាយកមានទំនាក់ទំនងល្អ និងវិជ្ជមានជាមួយបុគ្គលិករបស់ខ្លួន | 3.68 | 0.88 | ខ្ពស់ |
| ១០ | នាយកទទួលស្គាល់ និងឱ្យតម្លៃលើការខិតខំប្រឹងប្រែងរបស់បុគ្គលិករបស់ខ្លួន | 3.83 | 0.81 | ខ្ពស់ |
| ១១ | នាយកប្រគល់ភារកិច្ច និងអាជ្ញារដល់បុគ្គលិកដែលមានសមត្ថភាព | 3.64 | 0.84 | ខ្ពស់ |
| ១២ | នាយកសម្រេចបានស្នាដៃជាច្រើនជូនដល់សាលា | 3.57 | 0.93 | ខ្ពស់ |
| ១៣ | នាយកបង្កើតបរិយាកាសវិជ្ជមានសម្រាប់គ្រប់គ្នា | 3.36 | 1.00 | មធ្យម |
| ១៤ | នាយកផ្តល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ | 3.81 | 0.94 | ខ្ពស់ |
| ១៥ | នាយកទប់ស្កាត់រាល់បញ្ហា និងព្យាយាមធ្វើឱ្យបញ្ហាពីធំមកតូច | 3.71 | 0.88 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ១៦ | នាយកធ្វើជាអ្នកកណ្ដាលក្នុងការដោះស្រាយ ឬជម្លោះដោយមិនលំអៀងទៅខាងភាគីណាមួយឡើយ | 3.69 | 0.97 | ខ្ពស់ |
| **សរុប** | | **3.66** | **0.91** | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងបុគ្គលិក ជារួមស្ថិតក្នុងកម្រិត «ខ្ពស់»(M: **3.66**, SD: **0.91**)។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « ខ្ពស់» ដូចគ្នា។ ដូចនេះលទ្ធផលបង្ហាញថាការគ្រប់គ្រងបុគ្គលិក ពិតជាគ្រប់គ្រងបានខ្ពស់ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី១០ «នាយកទទួលស្គាល់ និងឱ្យតម្លៃលើការខិតខំប្រឹងប្រែងរបស់បុគ្គលិករបស់ខ្លួន (M: 3.83, SD: 0.81)» និងសូចនាករទី១៤«នាយកផ្ដល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ(M: 3.81, SD: 0.94)»។ ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានខ្ពស់ស្របទៅតាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

***តារាង 10 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់មាតាបិតា ឬអាណាព្យាបាលលើ***

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៧ | នាយកធ្វើជាគំរូផ្នែកឥរិយាបថដល់លោកគ្រូ អ្នកគ្រូ | 3.85 | 1.03 | ខ្ពស់ |
| ៨ | នាយកកំណត់នូវអ្វីដែលអាចជំរុញ និងលើកទឹកចិត្តដល់បុគ្គលិករបស់ខ្លួន។ | 3.65 | 1.15 | ខ្ពស់ |
| ៩ | នាយកមានទំនាក់ទំនងល្អ និងវិជ្ជមានជាមួយបុគ្គលិករបស់ខ្លួន | 3.73 | 0.97 | ខ្ពស់ |
| ១០ | នាយកទទួលស្គាល់ និងឱ្យតម្លៃលើការខិតខំប្រឹងប្រែងរបស់បុគ្គលិករបស់ខ្លួន | 3.88 | 0.96 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ១១ | នាយកប្រគល់ភារកិច្ច និងអាជ្ញាវដល់បុគ្គលិកដែលមានសមត្ថភាព | 3.71 | 0.91 | ខ្ពស់ |
| ១២ | នាយកសម្រេចបានស្នាដៃជាច្រើនជូនដល់សាលា | 3.60 | 0.99 | ខ្ពស់ |
| ១៣ | នាយកបង្កើតបរិយាកាសវិជ្ជមានសម្រាប់គ្រប់គ្នា | 3.60 | 0.87 | ខ្ពស់ |
| ១៤ | នាយកផ្តល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ | 3.98 | 0.91 | ខ្ពស់ |
| ១៥ | នាយកទប់ស្កាត់រាល់បញ្ហា និងព្យាយាមធ្វើឱ្យបញ្ហាពីធំមកតូច | 3.69 | 0.98 | ខ្ពស់ |
| ១៦ | នាយកធ្វើជាអ្នកកណ្តាលក្នុងការដោះស្រាយឬជម្លោះដោយមិនលំអៀងទៅខាងភាគីណាមួយឡើយ | 3.67 | 0.96 | ខ្ពស់ |
| **សរុប** | | **3.74** | **0.97** | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងបុគ្គលិក ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» (M: **3.74**, SD: **0.97**)។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « ខ្ពស់» ដូចគ្នា។

ដូចនេះលទ្ធផលបង្ហាញថា ការគ្រប់គ្រងបុគ្គលិក ពិតជាគ្រប់គ្រងបានខ្ពស់ដោយមានសូចនាករចំនួនពីរគឺ ៖ សូចនាករទី១៤ «នាយកផ្តល់ការលើកទឹកចិត្ត និងជម្រុញបុគ្គលិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈ(M: 3.98 , SD: 0.91)» និងសុចនាករទី១០ «នាយកទទួលស្គាល់ និងឱ្យតម្លៃលើការខិតខំប្រឹងប្រែងរបស់បុគ្គលិករបស់ខ្លួន (M: 3.88, SD: 0.96)»។ ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 11 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងបុគ្គលិក តាមទស្សនៈរបស់ភាគីទាំង៤*

| លរ | ក្រុមសំណាក | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | **គណៈគ្រប់គ្រងសាលារៀន** | 4.09 | 1.37 | ខ្ពស់ |
| ២ | **លោកគ្រូ អ្នកគ្រូ** | 3.50 | 1.64 | ខ្ពស់ |
| ៣ | **សិស្សានុសិស្ស** | 3.66 | 0.91 | ខ្ពស់ |
| ៤ | **មាតាបិតា ឬអាណាព្យាបាល** | 3.74 | 0.97 | ខ្ពស់ |
| សរុប | | **3.74** | **1.22** | **ខ្ពស់** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការ**គ្រប់គ្រងបុគ្គលិក** ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» ( M = **3.74** , SD=**1.22** ) ។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» ដូចគ្នា ដោយមានតម្លៃដូចតទៅ៖ គណៈគ្រប់គ្រងសាលារៀនស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» ( M: 4.09 , SD: 1.37 ) គ្រូស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«មធ្យម» ( M: 3.50 , SD: 1.64 ) សិស្សស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» ( M:3.66, SD: 0.91 ) និងចុងក្រោយគឺមាតាបិតា ឬអាណាព្យាបាលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់»( M: 3.74, SD: 0.97 ) ។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 12 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់គណៈគ្រប់គ្រង*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១៧ | នាយកបានដឹកនាំធ្វើផែនការថវិកាសម្រាប់អភិវឌ្ឍសាលារៀន | 3.50 | 1.64 | មធ្យម |

| | | | | |
|---|---|---|---|---|
| ១៨ | នាយកបានដឹកនាំធ្វើផែនការសកម្មភាពប្រចាំឆ្នាំយ៉ាងទៀងទៀត | 4.00 | 1.09 | ខ្ពស់ |
| ១៩ | នាយកបានដឹកនាំធ្វើផែនការដោយមានភាគីច្រើនចូលរួម | 3.50 | 1.64 | មធ្យម |
| ២០ | នាយករៀបចំផែនការ និងស្វែងរកប្រភពមូលនិធិនានាសម្រាប់កែលម្អសាលារៀន។ | 3.67 | 1.36 | ខ្ពស់ |
| ២១ | សំភារៈដែលមាននៅសាលាភាគច្រើនល្អ និងអាចទទួលយកបាន | 3.33 | 1.86 | មធ្យម |
| **សរុប** | | **3.60** | **1.52** | **ខ្ពស់** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការ**គ្រប់គ្រងហិរញ្ញវត្ថុ** ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» ( M = **3.60** , SD=**1.52** ) ។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត«ខ្ពស់» និង« មធ្យម»។ ដោយមានតម្លៃដូចតទៅ៖ សូចនាករទី១៨ «ស្ថិនាយកបានដឹកនាំធ្វើផែនការសកម្មភាពប្រចាំឆ្នាំយ៉ាងទៀងទៀត (M:4.00, SD:1.09)» និងសូចនាករទី ២០ «នាយករៀបចំផែនការ និងស្វែងរកប្រភពមូលនិធិនានាសម្រាប់កែលម្អសាលារៀន(M: 3.67, SD: 1.36) ស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» ។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានខ្ពស់ស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 13 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់គ្រូ*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១៧ | នាយកបានដឹកនាំធ្វើផែនការថវិកាសម្រាប់អភិវឌ្ឍសាលារៀន | 3.07 | 1.11 | ខ្ពស់ |
| ១៨ | នាយកបានដឹកនាំធ្វើផែនការសកម្មភាពប្រចាំឆ្នាំយ៉ាងទៀងទៀត | 3.13 | 1.22 | ខ្ពស់ |

| ១៩ | នាយកបានដឹកនាំធ្វើផែនការដោយមានភាគីច្រើនចូលរួម | 3.17 | 1.08 | ខ្ពស់ |
|---|---|---|---|---|
| ២០ | នាយករៀបចំផែនការ និងស្វែងរកប្រភពមូលនិធិនានាសម្រាប់កែលម្អសាលារៀន។ | 3.27 | 1.01 | ខ្ពស់ |
| ២១ | សំភារៈដែលមាននៅសាលាភាគច្រើនល្អ និងអាចទទួលយកបាន | 3.00 | 1.23 | ខ្ពស់ |
| **សរុប** | | **3.12** | **1.13** | **មធ្យម** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រង**ហិរញ្ញវត្ថុ** ជារួមស្ថិតក្នុងកម្រិត «មធ្យម» ដោយមាន (M: **3.12** , SD: **1.13**)។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « មធ្យម» ដូចគ្នា។ ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី២០ «នាយករៀបចំផែនការ និងស្វែងរកប្រភពមូលនិធិនានាសម្រាប់កែលម្អសាលារៀន( M: 3.27, SD: 1.01» និងសូចនាករទី២១ «សំភារៈដែលមាននៅសាលាភាគច្រើនខ្ពស់ និងអាចទទួលយកបាន( M: 3.00, SD:1.23 )»។ ដូចនេះលទ្ធផលបង្ហាញថាការគ្រប់គ្រង**ហិរញ្ញវត្ថុ** ពិតជាគ្រប់គ្រងនៅមានកម្រិតមធ្យម និងត្រូវការការកែលម្អ និងដកពិសោធពីសាលានានាដើម្បីយកមកអនុវត្តឱ្យកាន់តែមានប្រសិទ្ធិភាពក្នុងអង្គភាពរបស់ខ្លួន។ ជារួម គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តនូវពុំបានគ្រប់ជ្រុងជ្រោយស្របទៅតាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួនទេ។

*តារាង 14 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់សិស្ស*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១៧ | នាយកបានដឹកនាំធ្វើផែនការថវិកាសម្រាប់អភិវឌ្ឍសាលារៀន | 3.26 | 1.20 | មធ្យម |

| | | | | |
|---|---|---|---|---|
| ១៨ | នាយកបានដឹកនាំធ្វើផែនការសកម្មភាពប្រចាំឆ្នាំយ៉ាងទៀងទៀត | 3.48 | 0.96 | មធ្យម |
| ១៩ | នាយកបានដឹកនាំធ្វើផែនការដោយមានភាគីច្រើនចូលរួម | 3.36 | 0.94 | មធ្យម |
| ២០ | នាយករៀបចំផែនការ និងស្វែងរកប្រភពមូលនិធិនានាសម្រាប់កែលម្អសាលារៀន។ | 3.41 | 0.99 | មធ្យម |
| ២១ | សំភារៈដែលមាននៅសាលាភាគច្រើនល្អ និងអាចទទួលយកបាន | 3.18 | 1.11 | មធ្យម |
| **សរុប** | | **3.33** | **1.04** | **មធ្យម** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងហិរញ្ញវត្ថុ ជារួមស្ថិតក្នុងកម្រិត «មធ្យម» ដោយមាន (M: **3.33** , SD: **1.04** )។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « មធ្យម» ដូចគ្នា។ ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី១៨ «នាយកបានដឹកនាំធ្វើផែនការសកម្មភាពប្រចាំឆ្នាំ យ៉ាងទៀងទៀត (M: 3.48, SD: 0.96» និងសូចនាករទី២១ «សំភារៈដែលមាននៅសាលាភាគច្រើនខ្ពស់ និងអាចទទួលយកបាន( M: 3.18, SD: 1.11 )»។ ដូចនេះលទ្ធផលបង្ហាញថាការគ្រប់គ្រងហិរញ្ញវត្ថុ ពិតជាគ្រប់គ្រងនៅមានកម្រិតមធ្យម និងត្រូវការការកែលម្អ និងដកពិសោធពីសាលានានាដើម្បីយកមកអនុវត្តឱ្យកាន់តែមានប្រសិទ្ធិភាពក្នុងអង្គភាពរបស់ខ្លួន។ ។ ជារួមមក គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តនូវពុំបានគ្រប់ជ្រុងជ្រោយស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួនទេ។

*តារាង 15 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់មាតាបិតា ឬអាណាព្យាបាល*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១៧ | នាយកបានដឹកនាំធ្វើផែនការថវិកាសម្រាប់អភិវឌ្ឍសាលារៀន | 3.52 | 1.03 | ខ្ពស់ |
| ១៨ | នាយកបានដឹកនាំធ្វើផែនការសកម្មភាពប្រចាំឆ្នាំយ៉ាងទៀងទៀត | 3.21 | 1.05 | មធ្យម |
| ១៩ | នាយកបានដឹកនាំធ្វើផែនការដោយមានភាគីច្រើនចូលរួម | 3.58 | 0.87 | ខ្ពស់ |
| ២០ | នាយករៀបចំផែនការ និងស្វែងរកប្រភពមូលនិធិនានាសម្រាប់កែលម្អសាលារៀន។ | 3.79 | 2.77 | ខ្ពស់ |
| ២១ | សំភារៈដែលមាននៅសាលាភាគច្រើនល្អ និងអាចទទួលយកបាន | 3.19 | 1.06 | មធ្យម |
| **សរុប** | | **3.45** | **1.36** | **មធ្យម** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងហិរញ្ញវត្ថុ ជារួមស្ថិតក្នុងកម្រិត «មធ្យម» ដោយមាន (M: **3.45** , SD: **1.36** )។ គ្រប់សូចនាករទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « មធ្យម» និង «ខ្ពស់»។ ដោយមានសូចនាករចំនួនពីរគឺ៖ សូចនាករទី១៨ «នាយកបានដឹកនាំធ្វើផែនការសកម្មភាពប្រចាំឆ្នាំយ៉ាងទៀងទៀត ( M: 3.21 , SD: 1.05» និងសូចនាករទី២១ «សំភារៈដែលមាននៅសាលាភាគច្រើនខ្ពស់ និងអាចទទួលយកបាន( M: 3.19, SD: 1.06 )»។ ដូចនេះលទ្ធផលបង្ហាញថាការគ្រប់គ្រងហិរញ្ញវត្ថុ ពិតជាគ្រប់គ្រងនៅមានកម្រិតមធ្យម និងត្រូវការការកែលម្អ និងដកពិសោធពីសាលានានាដើម្បីយកមកអនុវត្តឱ្យកាន់តែមានប្រសិទ្ធិភាពក្នុងអង្គភាពរបស់ខ្លួន។ ។ ជារួមមក គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តនូវពុំបានគ្រប់ជ្រុងជ្រោយស្របទៅតាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួនទេ។

*តារាង 16 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងហិរញ្ញវត្ថុ តាមទស្សនៈរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | គណៈគ្រប់គ្រងសាលារៀន | 3.60 | 1.52 | ខ្ពស់ |
| ២ | គ្រូ | 3.12 | 1.13 | មធ្យម |
| ៣ | សិស្ស | 3.33 | 1.04 | មធ្យម |
| ៤ | មាតាបិតា ឬអាណាព្យាបាល | 3.45 | 1.36 | មធ្យម |
| **សរុប** | | **3.37** | **1.26** | **មធ្យម** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងហិរញ្ញវត្ថុ ជារួមស្ថិតក្នុងកម្រិត «មធ្យម» ដោយមាន (M: **3.37** , SD: **1.26**)។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត « មធ្យម» និង«ខ្ពស់» ដោយមានមធ្យមតម្លៃដូចតទៅ៖ គណៈគ្រប់គ្រងសាលារៀនស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» (M: 3.60 , SD: 1.52 ) គ្រូស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«មធ្យម»(M: ៣.១២, SD: 1.១៣) សិស្សស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «មធ្យម» (M: 3.33, SD: 1.04) និងចុងក្រោយគឺមាតាបិតា ឬអាណាព្យាបាលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «មធ្យម»(M: 3.45 , SD: 1.36)។

ជារួមមក គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តនូវពុំបានគ្រប់ជ្រុងជ្រោយស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួនទេ។

*តារាង 17 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការគ្រប់គ្រងការរៀន និងបង្រៀន តាមទស្សនៈរបស់គណៈគ្រប់គ្រង*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ២២ | នាយកមានកិច្ចសហប្រតិបត្តិការខ្ពស់ជាមួយគ្រូៗក្នុងការធ្វើផែនការរៀន និងបង្រៀនដើម្បីកំណត់គោលបំណងដែលសាលាចង់បាន។ | 4.00 | 1.09 | ខ្ពស់ |
| ២៣ | សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស | 3.33 | 1.50 | មធ្យម |
| ២៤ | នាយកបែងចែកសេវាបង្រៀនស្របតាមឯកទេស និងគុណវុឌ្ឍិរបស់គ្រូ។ | 4.33 | 0.51 | ខ្ពស់ |
| ២៥ | នាយកបានបង្កលក្ខណៈងាយស្រួលតាមរយៈការផ្គត់ផ្គង់សម្ភារៈបរិក្ខារដែលលោកគ្រូ អ្នកគ្រូទាំងអស់អាចប្រើប្រាស់បានគ្រប់ៗគ្នា | 4.33 | 0.51 | ខ្ពស់ |
| ២៦ | គ្រូយកចិត្តទុកដាក់លើការរីកចំរើនរបស់សិស្សទាំងផ្នែកបុគ្គលិកលក្ខណៈ បញ្ញាស្មារតី សីលធម៌ និងរបៀបរបបប្រាស្រ័យទាក់ទងក្នុងសង្គម | 3.50 | 1.64 | មធ្យម |
| ២៧ | នាយកត្រួតពិនិត្យកិច្ចការរដ្ឋបាលរបស់លោកគ្រូ អ្នកគ្រូ | 3.50 | 1.64 | មធ្យម |
| ២៨ | នាយកធ្វើថ្នាក់និទស្សន៍លើសកម្មភាពបង្រៀន និងរៀននៅតាមថ្នាក់ | 3.50 | 1.64 | មធ្យម |
| ២៩ | នាយកវាយតម្លៃការរៀបចំផែនការបង្រៀន និងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ អ្នកគ្រូ | 3.78 | 1.22 | ខ្ពស់ |
| **សរុប** | | **4.00** | **1.09** | **ខ្ពស់** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងការរៀន និងបង្រៀន ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» ( M = **4.00** , SD=**1.09** ) ។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុង

កម្រិត «ខ្ពស់» និង«មធ្យម» ដោយមានតម្លៃដូចតទៅ៖ សូចនាករទី២៤ «នាយកបែងចែកសេវាបង្រៀនស្របតាមឯកទេស និងគុណវុឌ្ឍិរបស់គ្រូ( M: 4.33, SD: 0.51» និងសូចនាករទី២៥ «នាយកបានបង្កលក្ខណៈងាយស្រួលតាមរយៈការផ្គត់ផ្គង់សម្ភារៈបរិក្ខារដែលលោកគ្រូ អ្នកគ្រូទាំងអស់អាចប្រើប្រាស់បានគ្រប់ៗគ្នា( M: 4.33, SD: 0.51 )»។ ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដែលការអនុវត្តក្នុង ការគ្រប់គ្រងការរៀន និងបង្រៀននៅមានកម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នោះគឺសូចនាករទី២៣ «សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែងនិងទាក់ទាញដល់ការសិក្សារបស់សិស្ស( M:3.33, SD:1.50)»។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តនៅទាន់បានគ្រប់ជ្រុងជ្រោយស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 18 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើការគ្រប់គ្រងការរៀន និងបង្រៀន តាមទស្សនៈរបស់គ្រូ*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ២២ | នាយកមានកិច្ចសហប្រតិបត្តិការខ្ពស់ជាមួយគ្រូៗក្នុងការធ្វើផែនការរៀន និងបង្រៀនដើម្បីកំណត់គោលបំណងដែលសាលាចង់បាន | 3.40 | 0.85 | មធ្យម |
| ២៣ | សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស | 3.37 | 0.96 | មធ្យម |

| | | | | |
|---|---|---|---|---|
| ២៤ | នាយកបែងចែកសេវាបង្រៀនស្របតាមឯកទេស និងគុណវុឌ្ឍិរបស់គ្រូ | 3.37 | 1.03 | មធ្យម |
| ២៥ | នាយកបានបង្កលក្ខណៈងាយស្រួលតាមរយៈការផ្គត់ផ្គង់សម្ភារៈបរិក្ខារដែលលោកគ្រូ អ្នកគ្រូទាំងអស់អាចប្រើប្រាស់បានគ្រប់ៗគ្នា | 3.27 | 1.17 | មធ្យម |
| ២៦ | គ្រូយកចិត្តទុកដាក់លើការរីកចំរើនរបស់សិស្សទាំងផ្នែកបុគ្គលិកលក្ខណៈ បញ្ញាស្មារតី សីលធម៌ និងរបៀបរបបប្រាស្រ័យទាក់ទងក្នុងសង្គម | 3.80 | 0.55 | ខ្ពស់ |
| ២៧ | នាយកត្រួតពិនិត្យកិច្ចការរដ្ឋបាលរបស់លោកគ្រូ អ្នកគ្រូ | 3.33 | 1.06 | មធ្យម |
| ២៨ | នាយកធ្វើថ្នាក់និទស្សន៍លើសកម្មភាពបង្រៀន និងរៀននៅតាមថ្នាក់ | 3.57 | 0.72 | ខ្ពស់ |
| ២៩ | នាយកវាយតម្លៃការរៀបចំផែនការបង្រៀន និងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ អ្នកគ្រូ | 3.53 | 0.73 | ខ្ពស់ |
| **សរុប** | | **3.45** | **0.88** | **មធ្យម** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា **ការគ្រប់គ្រងការរៀន និងបង្រៀន** ជារួមស្ថិតក្នុងកម្រិត «មធ្យម» (M = **3.45** , SD=**0.88**)។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» និង«មធ្យម» ដោយមានតម្លៃដូចតទៅ៖ សូចនាករទី២៤ «នាយកបែងចែកសេវាបង្រៀនស្របតាមឯកទេស និងគុណវុឌ្ឍិរបស់គ្រូ(M:៣.៣៧, SD: 1.03» និងសូចនាករទី២៥ «នាយកបានបង្កលក្ខណៈងាយស្រួលតាមរយៈការផ្គត់ផ្គង់សម្ភារៈបរិក្ខារដែលលោកគ្រូ អ្នកគ្រូទាំងអស់អាចប្រើប្រាស់បានគ្រប់ៗគ្នា (M: 3.27, SD: 1.17)»។ ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដែលការអនុវត្តក្នុង ការគ្រប់គ្រងការរៀន និងបង្រៀននៅមានកម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នោះគឺសូចនាករទី២៣ «សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស( M: 3.33, SD:1.50 )»។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តនៅទាន់បានគ្រប់ជ្រុងជ្រោយស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 19 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងការរៀន និងបង្រៀនតាមទស្សនៈរបស់សិស្ស*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ២២ | នាយកមានកិច្ចសហប្រតិបត្តិការខ្ពស់ជាមួយគ្រូៗក្នុងការធ្វើផែនការរៀន និងបង្រៀនដើម្បីកំណត់គោលបំណងដែលសាលាចង់បាន | 3.51 | 0.99 | ខ្ពស់ |
| ២៣ | សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស | 3.38 | 1.15 | មធ្យម |
| ២៤ | នាយកបែងចែកកាលវិភាគបង្រៀនសមស្របតាមមុខវិជ្ជាឯកទេស និងសមត្ថភាពរបស់គ្រូ | 3.73 | 0.97 | ខ្ពស់ |
| ២៥ | នាយកបានបង្កលក្ខណៈងាយស្រួលក្នុងការបង្រៀនតាមរយៈការផ្គត់ផ្គង់សម្ភារៈសម្រាប់បង្រៀនដល់លោកគ្រូ អ្នកគ្រូទាំងទៅតាមភាពជាក់ស្តែង | 3.48 | 0.93 | មធ្យម |
| ២៦ | គ្រូយកចិត្តទុកដាក់លើការរីកចំរើនរបស់សិស្សទាំងផ្នែកបុគ្គលិកលក្ខណៈ បញ្ញាស្មារតី សីលធម៌ និងរបៀបប្រាស្រ័យទាក់ទងក្នុងសង្គម | 3.53 | 1.04 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ២៧ | នាយកត្រួតពិនិត្យកិច្ចការរដ្ឋបាលរបស់លោកគ្រូ អ្នកគ្រូ | 3.58 | 0.86 | ខ្ពស់ |
| ២៨ | នាយកចុះមើលសកម្មភាពបង្រៀន និងរៀនរបស់គ្រូ និងសិស្សនៅតាមថ្នាក់ | 3.48 | 1.11 | មធ្យម |
| ២៩ | នាយកវាយតម្លៃការរៀបចំផែនការបង្រៀន និងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ អ្នកគ្រូ | 3.53 | 0.91 | ខ្ពស់ |
| **សរុប** | | **3.52** | **0.99** | **ខ្ពស់** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងការរៀន និងបង្រៀន ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» ( M = **3.52** , SD=**0.99** ) ។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» និង«មធ្យម» ដោយមានតម្លៃដូចតទៅ៖ សូចនាករទី២៤ «នាយកបែងចែកសេវាបង្រៀនស្របតាមឯកទេស និងគុណវុឌ្ឍិរបស់គ្រូ( M: 3.73, SD: 0.97 » និងសូចនាករទី២៣

«សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស( M: 3.38, SD:1.15 )»។ ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដែលការអនុវត្តក្នុង ការគ្រប់គ្រងការរៀន និងបង្រៀននៅមានកម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នោះគឺសូចនាករទី២៣ «សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស( M: 3.38, SD: 1.15 )»។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តនៅទាន់បានគ្រប់ជ្រុងជ្រោយស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 20 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើ ការគ្រប់គ្រងការរៀន និងបង្រៀន តាមទស្សនៈរបស់មាតាបិតា ឬអាណាព្យាបាល*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ២២ | នាយកមានកិច្ចសហប្រតិបត្តិការខ្ពស់ជាមួយគ្រូៗក្នុងការធ្វើផែនការរៀន និងបង្រៀនដើម្បីកំណត់គោលបំណងដែលសាលាចង់បាន | 3.60 | 0.99 | ខ្ពស់ |
| ២៣ | សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស | 3.31 | 1.11 | មធ្យម |
| ២៤ | នាយកបែងចែកកាលវិភាគបង្រៀនសមស្របតាមមុខវិជ្ជាឯកទេស និងសមត្ថភាពរបស់គ្រូ | 3.52 | 1.12 | ខ្ពស់ |
| ២៥ | នាយកបានបង្កលក្ខណៈងាយស្រួលក្នុងការបង្រៀនតាមរយៈការផ្គត់ផ្គង់សម្ភារៈសម្រាប់បង្រៀនដល់លោកគ្រូ អ្នកគ្រូទាំងទៅតាមភាពជាក់ស្តែង | 3.42 | 1.05 | មធ្យម |
| ២៦ | គ្រូយកចិត្តទុកដាក់លើការរីកចំរើនរបស់សិស្សទាំងផ្នែកបុគ្គលិកលក្ខណៈ បញ្ញាស្មារតី សីលធម៌ និងរបៀបប្រាស្រ័យទាក់ទងក្នុងសង្គម | 3.81 | 0.99 | ខ្ពស់ |
| ២៧ | នាយកត្រួតពិនិត្យកិច្ចការរដ្ឋបាលរបស់លោកគ្រូ អ្នកគ្រូ | 3.46 | 0.91 | មធ្យម |
| ២៨ | នាយកចុះមើលសកម្មភាពបង្រៀន និងរៀនរបស់គ្រូ និងសិស្សនៅតាមថ្នាក់ | 3.54 | 1.03 | ខ្ពស់ |
| ២៩ | នាយកវាយតម្លៃការរៀបចំផែនការបង្រៀន និងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ អ្នកគ្រូ | 3.58 | 1.01 | ខ្ពស់ |
| **សរុប** | | **3.53** | **1.03** | **ខ្ពស់** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងការរៀន និងបង្រៀន ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» (M =**3.53** , SD=**1.03**) ។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុង

កម្រិត «ខ្ពស់» និង«មធ្យម» ដោយមានតម្លៃដូចតទៅ៖ សូចនាករទី២៦ «គ្រូយកចិត្តទុកដាក់លើការរីកចំរើនរបស់សិស្សទាំងផ្នែកបុគ្គលិកលក្ខណៈ បញ្ញាស្មារតី សីលធម៌ និងរបៀបប្រាស្រ័យទាក់ទងក្នុងសង្គម (M:3.81, SD: 0.99)» និងសូចនាករទី២២ «នាយកមានកិច្ចសហប្រតិបត្តិការខ្ពស់ជាមួយគ្រូៗក្នុងការធ្វើផែនការរៀន និងបង្រៀនដើម្បីកំណត់គោលបំណងដែលសាលាចង់បាន (M: 3.60, SD:0.99)» ។ ទន្ទឹមគ្នានេះដែរមានចំណុចខ្លះដែលការអនុវត្តក្នុង ការគ្រប់គ្រងការរៀន និងបង្រៀននៅមានកម្រិតនៅឡើយដែលទាមទារមានការកែលម្អ និងប្រឹងប្រែងបន្ថែមពីថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ នោះគឺសូចនាករទី២៣ «សាលាបានបង្កើតឱ្យមានបរិយាកាសប្រកួតប្រជែង និងទាក់ទាញដល់ការសិក្សារបស់សិស្ស (M: 3.31, SD: 1.11)» និងទី២៥ «នាយកបានបង្កលក្ខណៈងាយស្រួលក្នុងការបង្រៀនតាមរយៈការផ្តត់ផ្គង់សម្ភារៈសម្រាប់បង្រៀនដល់លោកគ្រូ អ្នកគ្រូទាំងទៅតាមភាពជាក់ស្តែង(M: 3.42, SD: 1.05» ។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានគ្រប់ជ្រុងជ្រោយស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន ។

*តារាង 21 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើការគ្រប់គ្រងការរៀន និងបង្រៀនតាមទស្សនៈរបស់គ្រប់ភាគី*

| លរ | **បរិយាយ** | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | គណៈគ្រប់គ្រងសាលារៀន | 4.00 | 1.09 | ខ្ពស់ |
| ២ | គ្រូ | 3.45 | 0.88 | ខ្ពស់ |
| ៣ | សិស្ស | 3.52 | 0.99 | ខ្ពស់ |
| ៤ | មាតាបិតា ឬអាណាព្យាបាល | 3.53 | 1.03 | ខ្ពស់ |
| **សរុប** | | **3.62** | **1.00** | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា **លើការគ្រប់គ្រងការរៀន និងបង្រៀន** ជារួមស្ថិតក្នុងកម្រិត «ខ្ពស់» (M = 3.62 , SD=1.00)។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» និងមធ្យម ដោយមានតម្លៃដូចតទៅ៖ គណៈគ្រប់គ្រងសាលារៀនស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» (M: 4.00 , SD: 1.09) គ្រូស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«មធ្យម»(M: 3.45 , SD: 0.88) សិស្សស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់» (M: 3.52, SD: 0.99 ) និងចុងក្រោយគឺមាតាបិតា ឬអាណាព្យាបាលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ខ្ពស់»(M: ៣.៥៣, SD: ១.០៣)។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានត្រឹមត្រូវស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

*តារាង 22 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញចំពោះបញ្ហាប្រឈម និងកត្តាផ្សេងៗដែលធ្វើឱ្យចំនួនសិស្សកាន់តែថយចុះ របស់ភាគីពាក់ព័ន្ធ លើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកាន់តែកើនឡើង តាមចំណុចនិមួយៗ (n= ២៤៧)*

*កម្រងសំណួរលើបញ្ហាប្រឈម*

| ល រ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៣០ | សាលាមានការខ្វះ និងលើសគ្រូបង្រៀនតាមឯកទេស | 2.31 | 1.23 | ទាប |
| ៣១ | មានភាពយឺតយ៉ាវក្នុងការបញ្ជូនលទ្ធផលសិក្សារបស់សិស្សពីគ្រូទទួលបន្ទុកថ្នាក់ | 2.01 | 1.28 | ទាប |
| ៣២ | បង្រៀនមិនទាន់កម្មវិធីសិក្សាដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ | 2.18 | 1.20 | ទាប |
| ៣៣ | គ្រូមកបង្រៀនមិនទៀងទាត់ (មកយឺត ចេញមុន អវត្តមានច្រើនដង) | 2.17 | 1.28 | ទាប |

| | | | | |
|---|---|---|---|---|
| ៣៤ | ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត | 2.18 | 1.32 | ទាប |
| ៣៥ | សាលាមានក្មេងទំនើងដែលបន្កអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា | 3.00 | 1.16 | មធ្យម |
| ៣៦ | សាលាមានក្មេងទំនើងដែលបន្កអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា | 2.60 | 1.35 | មធ្យម |
| ៣៧ | សាលាមានសំឡេងរំខាន និងក្លិនមិនខ្ពស់ដែលបង្ក ផលប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស | 2.32 | 1.27 | ទាប |
| ៣៨ | សាលាបានយកលុយពីសិស្សពេលប្រឡង(ប្រចាំខែ ឆមាស ឬផ្សេងៗ) និងមិនបានផ្តល់ចំណាត់ថ្នាក់តាម សមត្ថភាពជាក់ស្តែងរបស់សិស្សទេ | 1.91 | 1.22 | ទាប |
| ៣៩ | គ្រូបានគាបសិស្សឱ្យរៀនក្រៅម៉ោង | 1.86 | 1.15 | ទាប |
| ៤០ | សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ | 1.81 | 1.17 | ទាប |
| ៤១ | សាលាមិនមានសាមគ្គីភាពរវាងគណៈគ្រប់គ្រង | 2.06 | 1.19 | ទាប |
| ៤២ | សាលាមិនមានសាមគ្គីភាពរវាងគណៈគ្រប់គ្រង និង គ្រូ | 2.02 | 1.15 | ទាប |
| ៤៣ | សាលាមិនមានទំនាក់ទំនងខ្ពស់រវាងគ្រូសិស្ស និង អាណាព្យាបាល | 1.92 | 1.09 | ទាប |
| **សរុប** | | **2.16** | **0.07** | **ទាប** |

តាមតារាងខាងលើ លទ្ធផលបង្ហាញថា **បញ្ហាប្រឈម និងកត្តាផ្សេងៗដែលធ្វើឱ្យចំនួនសិស្សកាន់តែថយចុះ របស់ភាគីពាក់ព័ន្ធ លើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកាន់តែកើនឡើង** របស់ភាគីពាក់ព័ន្ធដែលមាន៖ គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាលសិស្សនៅកម្រិតទុតិយភូមិជារួមក្នុងកម្រិត «ទាប» (M: **2.16** និង SD: **0.07**)។ បើមើលតាមរៀងតាមលំដាប់តម្លៃមធ្យម ខ្លឹមសារចំនុចចំនួនបីដែលមានតម្លៃខ្ពស់ជាងគេនោះគឺ៖

សូចនាករទី ៣៥៖ «សាលាមានក្មេងទំនើងដែលបន្តអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា ( M: 3.00, SD: 1.16 )»ដែលសស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«មធ្យម» ។

សូចនាករទី៣៦៖ «សាលាមានក្មេងទំនើងដែលបន្តអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា ( M: 2.60, SD:1.35 )» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«មធ្យម»។

ផ្ទុយទៅវិញ បើគេរៀងលំដាប់តាមតម្លៃមធ្យម ដែលទាបជាងគេមានបួនចំណុចផងដែរ ដែលមានដូចតទៅ៖

សូចនាករទី៤០៖ «សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ ( M: 1.81, SD: 1.17 )» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប»។

សូចនាករទី៣៩៖ «គ្រូបានគាបសិស្សឱ្យរៀនក្រៅម៉ោង ( M: 1.86, SD: 1.15 )»ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប»។

ដូចនេះ គេអាចសន្និដ្ឋានបានថា បញ្ហាប្រឈមនៅសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិស្ថិតក្នុងម្រិតមួយដែលអាចគ្រប់គ្រង ដោយសារមានការសហការគ្នាបានល្អរវាងគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុស្ស មាតាបិតា និងភាគីផ្សេងទៀត។ តែក៏នៅចំណុចមួយដេលត្រូវពង្រឹងបន្ថែម និងបន្តទៀត ដើម្បីឱ្យបញ្ហាប្រឈមទាំងនេះឱ្យស្ថិតក្នុងកម្រិតជាអតិប្បរមា។

*តារាង 23 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើបញ្ហាប្រឈមរបស់គណៈគ្រប់គ្រងសាលារៀន*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៣០ | សាលាមានការខ្វះ និងលើសគ្រូបង្រៀនតាមឯកទេស | 3.67 | 1.03 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ៣១ | មានភាពយឺតយ៉ាវក្នុងការបញ្ជូនលទ្ធផលសិក្សារបស់សិស្សពីគ្រូទទួលបន្ទុកថ្នាក់ | 2.17 | 1.47 | ទាប |
| ៣២ | បង្រៀនមិនទាន់កម្មវិធីសិក្សាដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ | 2.17 | 1.47 | ទាប |
| ៣៣ | គ្រូមកបង្រៀនមិនទៀងទាត់ (មកយឺត ចេញមុន អវត្តមានច្រើនដង) | 1.17 | 0.40 | ទាប |
| ៣៤ | ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត | 2.17 | 1.47 | ទាប |
| ៣៥ | សាលាមានក្មេងទំនើងដែលបន្កអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា | 3.67 | 0.81 | ខ្ពស់ |
| ៣៦ | សាលាមានក្មេងទំនើងដែលបន្កអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា | 1.17 | 0.40 | ទាបបំផុត |
| ៣៧ | សាលាមានសំឡេងរំខាន និងខ្លឹនមិនខ្ពស់ដែលបង្កផលប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស | 2.33 | 1.36 | ទាប |
| ៣៨ | សាលាបានយកលុយពីសិស្សពេលប្រឡង(ប្រចាំខែ ឆមាស ឬផ្សេងៗ) និងមិនបានផ្តល់ចំណាត់ថ្នាក់តាមសមត្ថភាពជាក់ស្តែងរបស់សិស្សទេ | 1.17 | 0.40 | ទាបបំផុត |
| ៣៩ | គ្រូបានគាបសិស្សឱ្យរៀនក្រៅម៉ោង | 1.83 | 1.329 | ទាប |
| ៤០ | សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ | 1.00 | 0.00 | ទាបបំផុត |
| ៤១ | សាលាមិនមានសាមគ្គីភាពរវាងគណៈគ្រប់គ្រង | 1.67 | 1.21 | ទាប |
| ៤២ | សាលាមិនមានសាមគ្គីភាពរវាងគណៈគ្រប់គ្រង និងគ្រូ | 1.83 | 1.16 | ទាប |
| ៤៣ | សាលាមិនមានទំនាក់ទំនងខ្ពស់រវាងគ្រូសិស្ស និងអាណាព្យាបាល | 1.33 | 0.51 | ទាបបំផុត |
| **សរុប** | | **1.95** | **0.93** | **ទាប** |

តាមតារាងខាងលើ លទ្ធផលបង្ហាញថា **បញ្ហាប្រឈម និងកត្តាផ្សេងៗដែលធ្វើឱ្យចំនួនសិស្សកាន់តែថយចុះ របស់ភាគីពាក់ព័ន្ធ លើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ**

**និងសាលាដែលមានចំនួនសិស្សកាន់តែកើនឡើង** របស់ភាគីពាក់ព័ន្ធដែលមាន៖ គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាលសិស្សនៅកម្រិតទុតិយភូមិជារួមក្នុងកម្រិត «ទាប» (M: **1.95** និង SD: **0.93**) ។ បើមើលតាមរៀងតាមលំដាប់តម្លៃមធ្យម ខ្លឹមសារចំនុចចំនួនបីដែលមានតម្លៃខ្ពស់ជាងគេនោះគឺ៖

សូចនាករទី ៣០៖ «សាលាមានការខ្វះ និងលើសគ្រូបង្រៀនតាមឯកទេស( M: 3.67, SD: 1.03 )»ដែលសស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់» ។

សូចនាករទី៣៥៖ «សាលាមានក្មេងទំនើងដែលបន្តអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា( M: 3.67, SD: 0.81 )» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់»។ បញ្ហាទាំងពីរខាងលើនេះជាបញ្ហាប្រឈមខ្លាំងដែលត្រូវដោះស្រាយឱ្យបាន ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលាដើម្បីរក្សាភាពគង់វង្សនៃសិស្សនៅតាមសាលារៀននិមួយៗ។

ផ្ទុយទៅវិញ បើគេរៀងលំដាប់តាមតម្លៃមធ្យម ដែលទាបជាងគេមានបួនចំណុចផងដែរដែលមានដូចតទៅ៖

សូចនាករទី៤០៖ «សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ( M: 1.00, SD: 0.00» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាបបំផុត»។

សូចនាករទី៣៩៖ «សាលាមានក្មេងទំនើងដែលបន្តអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា( M: 1.17, SD: 0.40 )»ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាបបំផុត»។

ដូចនេះ គេអាចសន្និដ្ឋានបានថា បញ្ហាប្រឈមនៅសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិស្ថិតក្នុងម្រិតមួយដែលអាចគ្រប់គ្រង ដោយសារមានការសហការគ្នាបានល្អរវាង ថ្នាក់ជាតិ ក្រោមជាតិ និងថ្នាក់មូលដ្ឋាន (គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស) និងភាគី

ផ្សេងទៀត។ តែក៏នៅចំណុចមួយដែលត្រូវពង្រឹងបន្ថែម និងបន្តទៀតដើម្បីឱ្យបញ្ហាប្រឈមទាំងនេះឱ្យស្ថិតក្នុងកម្រិតជាអតិប្បរមា។

*តារាង 24៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើបញ្ហាប្រឈមរបស់គ្រូ*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៣០ | សាលាមានការខ្វះ និងលើសគ្រូបង្រៀនតាមឯកទេស | 3.23 | 1.10 | មធ្យម |
| ៣១ | មានភាពយឺតយ៉ាវក្នុងការបញ្ជូនលទ្ធផលសិក្សារបស់សិស្សពីគ្រូទទួលបន្ទុកថ្នាក់ | 2.73 | 1.23 | មធ្យម |
| ៣២ | បង្រៀនមិនទាន់កម្មវិធីសិក្សាដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ | 2.17 | 1.05 | ទាប |
| ៣៣ | គ្រូមកបង្រៀនមិនទៀងទាត់ (មកយឺត ចេញមុន អវត្តមានច្រើនដង) | 2.00 | 1.05 | ទាប |
| ៣៤ | ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត | 2.80 | 1.37 | មធ្យម |
| ៣៥ | សាលាមានក្មេងទំនើងដែលបង្កអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា | 2.90 | 1.18 | មធ្យម |
| ៣៦ | សាលាមានក្មេងទំនើងដែលបង្កអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា | 1.63 | 0.80 | ទាប |
| ៣៧ | សាលាមានសំឡេងរំខាន និងខ្លឹនមិនខ្ពស់ដែលបង្កផលប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស | 2.10 | 1.18 | ទាប |
| ៣៨ | សាលាបានយកលុយពីសិស្សពេលប្រឡង(ប្រចាំខែ ឆមាស ឬផ្សេងៗ) និងមិនបានផ្តល់ចំណាត់ថ្នាក់តាមសមត្ថភាពជាក់ស្តែងរបស់សិស្សទេ | 1.47 | 0.86 | ទាបបំផុត |
| ៣៩ | គ្រូបានគាបសិស្សឱ្យរៀនក្រៅម៉ោង | 1.50 | 0.86 | ទាប |
| ៤០ | សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ | 1.70 | 1.14 | ទាប |

| | | | | |
|---|---|---|---|---|
| ៤១ | សាលាមិនមានសាមគ្គីភាពរវាងគណៈគ្រប់គ្រង | 2.40 | 1.30 | ទាប |
| ៤២ | សាលាមិនមានសាមគ្គីភាពរវាងគណៈគ្រប់គ្រង និងគ្រូ | 1.87 | 0.97 | ទាប |
| ៤៣ | សាលាមិនមានទំនាក់ទំនងខ្ពស់រវាងគ្រូសិស្ស និងអាណាព្យាបាល | 1.77 | 0.81 | ទាប |
| **សរុប** | | **2.16** | **1.06** | ទាប |

តាមតារាងខាងលើ លទ្ធផលបង្ហាញថា តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា **បញ្ហាប្រឈម និងកត្តាផ្សេងៗ**ជារួមស្ថិតក្នុងកម្រិត «ទាប» (M = **2.16**, SD=**1.06**)។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ទាប» និង«ទាបបំផុត»។ បើមើលតាមរៀងតាមលំដាប់តម្លៃមធ្យម ខ្លឹមសារចំនុចចំនួនបីដែលមានតម្លៃខ្ពស់ជាងគេនោះគឺ៖

សូចនាករទី ៣០៖ «សាលាមានការខ្វះ និងលើសគ្រូបង្រៀនតាមឯកទេស(M: 3.67, SD: 1.03)»ដែលសស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់» ។

សូចនាករទី៣៥៖ «សាលាមានក្មេងទំនើងដែលបន្តអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា (M: 3.67, SD: 0.81)» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់»។

សូចនាករទី៣៤៖ «ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត(M: 2.80, SD:1.37)» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់»។

បញ្ហាទាំងពីរខាងលើនេះជាបញ្ហាប្រឈមខ្លាំងដែលត្រូវដោះស្រាយឱ្យបាន ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលាដើម្បីរក្សាភាពគង់វង្សនៃសិស្សនៅតាមសាលារៀននិមួយៗ។

ផ្ទុយទៅវិញ បើគេរៀងលំដាប់តាមតម្លៃមធ្យម ដែលទាបជាងគេមានបួនចំណុចផងដែរដែលមានដូចតទៅ៖

សូចនាករទី៣៨៖ «សាលាបានយកលុយពីសិស្សពេលប្រឡង(ប្រចាំខែ ឆមាស ឬផ្សេងៗ) និងមិនបានផ្តល់ចំណាត់ថ្នាក់តាមសមត្ថភាពជាក់ស្តែងរបស់សិស្សទេ(M: 1.47, SD: 0.86)» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាបបំផុត»។

សូចនាករទី៣៩៖ «គ្រូបានគាបសិស្សឱ្យរៀនក្រៅម៉ោង(M: 1.50, SD: 0.86)»ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាបបំផុត»។

សូចនាករទី៤០៖ «សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ(M: 1.70, SD: 1.14)»

ដូចនេះ គេអាចសន្និដ្ឋានបានថា បញ្ហាប្រឈមនៅសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិស្ថិតក្នុងម្រិតមួយដែលអាចគ្រប់គ្រង ដោយសារមានការសហការគ្នាបានល្អរវាង ថ្នាក់ជាតិ ក្រោមជាតិ និងថ្នាក់មូលដ្ឋាន (គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស) និងភាគីផ្សេងទៀត។ តែក៏នៅមានចំណុចមួយដែលត្រូវពង្រឹងបន្ថែម និងបន្តទៀតដើម្បីឱ្យបញ្ហាប្រឈមទាំងនេះឱ្យស្ថិតក្នុងកម្រិតជាអតិប្បរមា។

*តារាង 25 ៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញលើបញ្ហាប្រឈមរបស់សិស្ស*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៣០ | គ្រូពន្យល់មិនបានក្បោះក្បាយ | 2.17 | 1.19 | ទាប |
| ៣១ | គ្រូមិនដែលឱ្យសៀវភៅតាមដានមកអាណាព្យាបាល | 1.98 | 1.31 | ទាប |
| ៣២ | គ្រូបង្រៀនមិនទាន់ចប់សៀវភៅរបស់ក្រសួងអប់រំ | 2.23 | 1.23 | ទាប |

| | | | | |
|---|---|---|---|---|
| | យុវជន និងកីឡាបានកំណត់ | | | |
| ៣៣ | ចំនួនសិស្សច្រើនពេកក្នុងថ្នាក់ បណ្តាលឱ្យក្តៅដែលបង្កការរំខានដល់ការសិក្សា | 2.23 | 1.31 | ទាប |
| ៣៤ | គ្រូមកបង្រៀនមិនទៀងទាត់ (មកយឺត ចេញមុន អវត្តមានច្រើនដង) | 1.97 | 1.27 | ទាប |
| ៣៥ | ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត | 3.03 | 1.16 | ខ្ពស់ |
| ៣៦ | សាលាមានក្មេងទំនើងដែលបន្តអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា | 2.83 | 1.37 | ខ្ពស់ |
| ៣៧ | សាលាមានសំឡេងរំខាន និងក្លិនមិនខ្ពស់ដែលបង្កផលប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស | 2.49 | 1.32 | មធ្យម |
| ៣៨ | សាលាបានយកលុយពីសិស្សពេលប្រឡង(ប្រចាំខែ ឆមាស ឬផ្សេងៗ) និងមិនបានផ្តល់ចំណាត់ថ្នាក់តាមសមត្ថភាពជាក់ស្តែងរបស់សិស្សទេ | 1.97 | 1.27 | ទាប |
| ៣៩ | គ្រូបានគាបសិស្សឱ្យរៀនក្រៅម៉ោង | 1.93 | 1.16 | ទាប |
| ៤០ | សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ | 1.85 | 1.17 | ទាប |
| ៤១ | សាលាមិនមានសាមគ្គីភាពរវាងនាយក និងនាយករង | 2.06 | 1.15 | ទាប |
| ៤២ | សាលាមិនមានសាមគ្គីភាពរវាងនាយក នាយករង និងគ្រូ | 2.10 | 1.15 | ទាប |
| ៤៣ | សាលាមិនមានទំនាក់ទំនងខ្ពស់រវាងគ្រូសិស្ស និងអាណាព្យាបាល | 1.99 | 1.09 | ទាប |
| **សរុប** | | **2.20** | **1.22** | **ទាប** |

តាមតារាងខាងលើ លទ្ធផលបង្ហាញថា តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា **បញ្ហាប្រឈម និងកត្តាផ្សេងៗ**ជារួមស្ថិតក្នុងកម្រិត «ទាប» (M =2.20 , SD=1.22)។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «មធ្យម» និង«ទាបបំផុត»។ បើមើលតាមរៀងតាមលំដាប់តម្លៃមធ្យមខ្លឹមសារចំនុចចំនួនបីដែលមានតម្លៃខ្ពស់ជាងគេនោះគឺ៖

សូចនាករទី ៣៥៖ «ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត(M: 3.03 ,SD: 1.17)» ដែលសស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់» ។

សូចនាករទី៣៦៖ «សាលាមានក្មេងទំនើងដែលបន្កអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលា (M: 2.83, SD: 1.37)» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់»។

សូចនាករទី៣៧៖ «សាលាមានសំឡេងរំខាន និងក្លិនមិនខ្ពស់ដែលបង្កផលប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស(M: 2.49, SD:1.32)» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«មធ្យម»។ បញ្ហាទាំងពីរខាងលើនេះ ជាបញ្ហាប្រឈមខ្លាំងដែលត្រូវដោះស្រាយឱ្យបាន ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលាដើម្បីរក្សាភាពគង់វង្សនៃសិស្សនៅតាមសាលារៀននិមួយៗ។

ផ្ទុយទៅវិញ បើគេរៀងលំដាប់តាមតម្លៃមធ្យម ដែលទាបជាងគេមានបួនចំណុចផងដែរដែលមានដូចតទៅ៖

សូចនាករទី៤០៖ « សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ(M: 1.85, SD: 1.17)» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប»។

សូចនាករទី៣៩៖ «គ្រូបានគាបសិស្សឱ្យរៀនក្រៅម៉ោង (M: 1.93,SD: 1.16)»«ទាបបំផុត»។

សូចនាករទី៤០៖ «សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ(M: 1.93, SD: 1.14)»ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប»។

ដូចនេះ គេអាចសន្និដ្ឋានបានថា បញ្ហាប្រឈមនៅសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិស្ថិតក្នុងម្រិតមួយដែលអាចគ្រប់គ្រង ដោយសារមានការសហការគ្នាបានល្អរវាង ថ្នាក់ជាតិ ក្រោមជាតិ និងថ្នាក់មូលដ្ឋាន (គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស) និងភាគី

ផ្សេងទៀត។ តែក៏នៅចំណុចមួយដែលត្រូវពង្រឹងបន្ថែម និងបន្តទៀតដើម្បីឱ្យបញ្ហាប្រឈមទាំងនេះឱ្យស្ថិតក្នុងកម្រិតជាអតិប្បរមា។

*តារាង 26៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើបញ្ហាប្រឈមរបស់មាតាបិតា ឬអាណាព្យាបាល*

| លរ | **បរិយាយ** | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ៣០ | គ្រូពន្យល់មិនបានក្បោះក្បាយ | 2.10 | 1.17 | ទាប |
| ៣១ | គ្រូមិនដែលឱ្យសៀវភៅតាមដានមកអាណាព្យាបាល | 1.69 | 1.03 | ទាប |
| ៣២ | គ្រូបង្រៀនមិនទាន់ចប់សៀវភៅរបស់ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ | 2.06 | 1.17 | ទាប |
| ៣៣ | ចំនួនសិស្សច្រើនពេកក្នុងថ្នាក់ បណ្តាលឱ្យក្តៅដែលបង្កការរំខានដល់ការសិក្សា | 2.21 | 1.33 | ទាប |
| ៣៤ | គ្រូមកបង្រៀនមិនទៀងទាត់ (មកយឺត ចេញមុន អវត្តមានច្រើនដង) | 2.48 | 1.32 | ទាប |
| ៣៥ | ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត | 2.88 | 1.18 | ខ្ពស់ |
| ៣៦ | ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត | 2.62 | 1.27 | ខ្ពស់ |
| ៣៧ | សាលាមានសំឡេងរំខាន និងក្លិនមិនខ្ពស់ដែលបង្កផលប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស | 1.96 | 1.06 | ទាប |
| ៣៨ | សាលាបានយកលុយពីសិស្សពេលប្រឡង(ប្រចាំខែ ឆមាស ឬផ្សេងៗ) និងមិនបានផ្តល់ចំណាត់ថ្នាក់តាមសមត្ថភាពជាក់ស្តែងរបស់សិស្សទេ | 2.06 | 1.22 | ទាប |
| ៣៩ | គ្រូបានគាបសិស្សឱ្យរៀនក្រៅម៉ោង | 1.90 | 1.24 | ទាប |
| ៤០ | សាលាលក់ក្រដាសមេរៀនក្នុងតម្លៃមិនសមរម្យ | 1.88 | 1.23 | ទាប |
| ៤១ | សាលាមិនមានសាមគ្គីភាពរវាងនាយក និងនាយករង | 1.94 | 1.22 | ទាប |

| | | | | |
|---|---|---|---|---|
| ៤២ | សាលាមិនមានសាមគ្គីភាពរវាងនាយក នាយករង និងគ្រូ | 1.92 | 1.23 | ទាប |
| ៤៣ | សាលាមិនមានទំនាក់ទំនងខ្ពស់រវាងគ្រូសិស្ស និង អាណាព្យាបាល | 1.88 | 1.24 | ទាប |
| **សរុប** | | **2.11** | **1.21** | **ទាប** |

តាមតារាងខាងលើ លទ្ធផលបង្ហាញថា តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា **បញ្ហាប្រឈម និងកត្តាផ្សេងៗ**ជារួមស្ថិតក្នុងកម្រិត «ទាប» (M =**2.11** , SD=**1.21**)។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត «ខ្ពស់» និង«ទាបបំផុត»។ បើមើលតាមរៀងតាមលំដាប់តម្លៃមធ្យម ខ្លឹមសារចំនុចចំនួនបីដែលមានតម្លៃខ្ពស់ជាងគេនោះគឺ៖

សូចនាករទី ៣៥៖ «ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត( M: 2.88, SD: 1.18 )» ដែលសស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់» ។

សូចនាករទី៣៥ ៖ «ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត( M: 2.88, SD:1.18» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ខ្ពស់»។

សូចនាករទី៣៦៖ «ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត( M: 2.62, SD:1.27» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«មធ្យម»។ បញ្ហាទាំងបីខាងលើនេះជាបញ្ហាប្រឈមខ្លាំងដែលត្រូវដោះស្រាយឱ្យបាន ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលាដើម្បីរក្សាភាពគង់វង្សនៃសិស្សនៅតាមសាលារៀននិមួយៗ។

ផ្ទុយទៅវិញ បើគេរៀងលំដាប់តាមតម្លៃមធ្យម ដែលទាបជាងគេមានបួនចំណុចផងដែរដែលមានដូចតទៅ៖

សូចនាករទី៣១៖ «គ្រូមិនដែលឱ្យសៀវភៅតាមដានមកអាណាព្យាបាល ( M: 1.69, SD: 1.03 )» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប»។

សូចនាករទី៤៣៖ «សាលាមិនមានទំនាក់ទំនងខ្ពស់រវាងគ្រូសិស្ស និងអាណាព្យាបាល( M: 1.88, SD:1.24 )» ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប»។

សូចនាករទី៤២៖ « សាលាមិនមានសាមគ្គីភាពរវាងនាយក នាយករង និងគ្រូ( M: 1.92, SD:1.23 )»ដែលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប»។

ដូចនេះ គេអាចសន្និដ្ឋានបានថា បញ្ហាប្រឈមនៅសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិស្ថិតក្នុងម្រិតមួយដែលអាចគ្រប់គ្រង ដោយសារមានការសហការគ្នាបានល្អរវាង ថ្នាក់ជាតិ ក្រោមជាតិ និងថ្នាក់មូលដ្ឋាន (គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស) និងភាគីផ្សេងទៀត។ តែក៏នៅចំណុចមួយដែលត្រូវពង្រឹងបន្ថែម និងបន្តទៀតដើម្បីឱ្យបញ្ហាប្រឈមទាំងនេះឱ្យស្ថិតក្នុងកម្រិតជាអតិប្បរមា។

*តារាង 27៖ តម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតចង្អុលបង្ហាញ លើបញ្ហាប្រឈម និងកត្តាផ្សេងៗ របស់ក្រុមទាំង៤*

| លរ | បរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | គណៈគ្រងគ្រងសាលារៀន | 1.95 | 0.93 | ទាប |
| ២ | គ្រូ | 2.16 | 1.06 | ទាប |
| ៣ | សិស្ស | 2.20 | 1.22 | ទាប |
| ៤ | មាតាបិតា ឬអាណាព្យាបាល | 2.11 | 1.21 | ទាប |
| **សរុប** | | **2.10** | **1.10** | **ទាប** |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា **បញ្ហាប្រឈម និងកត្តាផ្សេងៗ** ជារួមស្ថិតក្នុងកម្រិត ខ្ពស់«ទាប» (M: 3.55, SD: 1.04)។ គ្រប់តម្លៃមធ្យមរបស់អ្នកឆ្លើយទាំងអស់ទទួលបានលទ្ធផលក្នុងកម្រិត«ទាប» ដោយមានតម្លៃដូចតទៅ៖ គណៈគ្រប់គ្រងសាលារៀនស្ថិតក្នុងកម្រិតចង្អុលបង្ហាញ

«ទាប» (M: 1.95 , SD: 0.93) គ្រូស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប» (M: 2.16 , SD: 1.06) សិស្សស្ថិតក្នុងកម្រិតចង្អុលបង្ហាញ «ទាប»(M: 2.20, SD: 1.22) និងចុងក្រោយគឺមាតាបិតា ឬអាណាព្យាបាលស្ថិតក្នុងកម្រិតចង្អុលបង្ហាញ«ទាប»(M: 2.11 , SD: 1.21)។

ដូចនេះ គេអាចសន្និដ្ឋានបានថា សាលារៀនអនុវត្តបានត្រឹមត្រូវស្របទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានត្រឹមត្រូវ ច្បាស់លាស់ មានគណនេយ្យភាព និងមានតម្លាភាពក្នុងអង្គភាពរបស់ខ្លួន។

## ៤.៦ ការពិភាក្សា

### ៤.២.១ ការពិភាក្សាទៅលើលទ្ធផលនៃការវិភាគ ផ្នែកទី២

តាមរយៈលទ្ធផលនៃការស្រាវជ្រាវបង្ហាញឱ្យឃើញថា **ទស្សនៈរបស់ភាគីពាក់ព័ន្ធចំពោះសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកាន់តែកើនឡើង** ជារួមស្ថិតក្នុងកម្រិតខ្ពស់។ លទ្ធផលនេះអាចពន្យល់បានថា ទស្សនៈរបស់ភាគីពាក់ព័ន្ធមានលក្ខណៈប្រហែលគ្នា និងអាចនិយាយបានទៀតថា ការអនុវត្តការងាររបស់គណៈគ្រប់គ្រងលើផ្នែកទាំង ៤ក្នុងអង្គភាពមានភាពល្អ នេះសបញ្ជាក់ឱ្យឃើញថាគណៈគ្រប់គ្រងសាលា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តការងារ ផ្តល់តម្លៃលើការងារ មានឆន្ទៈក្នុងការទទួលខុសត្រូវ មានការប្រកួតប្រជែង មានការសហការរវាងគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ មានការចែករំលែកនូវចំណេះដឹងបទពិសោធ និងផ្តល់នូវមតិយោបល់កែលម្អ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ នូវរបៀបរបបធ្វើការងារ ព្រមទាំងប្រែក្លាយអង្គភាពរបស់ខ្លួន (សាលារៀនរបស់ពួកគាត់)ឱ្យកាន់តែមានភាពទាក់ទាញដើម្បីទទួលបានកំណើនសិស្ស និងកេរ៏ឈ្មោះពីមួយឆ្នាំទៅមួយឆ្នាំ។ ក្នុងនោះដែរសង្កេតមើលតាមចំណុចនីមួយៗ យើងឃើញថា ការរៀបចំបរិស្ថានសាលារៀន ស្ថិតក្នុងកម្រិតល្អ លទ្ធផលនេះអាចពន្យល់បានថា៖អាចមកពីគណៈគ្រប់គ្រងសាលា មានការយល់ដឹងស៊ីជំរៅលើតួនាទីភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តការងារ ដោយផ្តោតសំខាន់ការរៀបបរិស្ថានសាលារៀនឱ្យមានលក្ខណៈបៃតង (Green Innovation) និងមានការបញ្ជ្រាប និងលើកតឹកចិត្តទាំងបុគ្គលិក និងសិស្សានុសិស្សក្នុងការចូលរួមផ្នែកបរិស្ថាននេះ។ ដោយមានការបែងចែកវេនសំអាតជាប្រចាំ និងម៉ឺងម៉ាត់ ហើយ

លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សបានចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទំនួលខុសត្រូវលើអនុវត្តការងាររបស់ខ្លួន។

### ៤.២.២ ការពិភាក្សាលទ្ធផលនៃការស្រាវជ្រាវ ផ្នែកទី៣

តាមរយៈលទ្ធផលនៃការស្រាវជ្រាវបង្ហាញឱ្យឃើញថា **បញ្ហាប្រឈម និងកត្តាផ្សេងៗ** ពិតជាមានបញ្ហាប្រឈម ជារួមស្ថិតក្នុងទាប។ លទ្ធផលនេះអាចពន្យល់បានថា ទាំងគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងអង្គភាព និងមាតាបិតាដែលចំណុះឱយសាលារៀនពិតបានចូលរួមយ៉ាងសកម្ម ព្រោះសាលារៀន និងសហគមន៍ជាភាគីដែលមិនអាចខ្វះគ្នាបានឡើយ។ តែនៅមានសូចនាករមួយចំនួនមិនទាន់អនុវត្តបានល្អគ្រប់ជ្រុងជ្រោយនៅឡើយទេ នេះសបញ្ជាក់ឱ្យឃើញថា គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាល គួរយកចិត្តទុកដាក់លើការបន្ថែមទៀតក្នុងចូលរួមកិច្ចការទាំងឡាយទៅតួនាទីរៀងៗខ្លួនរបស់អង្គភាព ដើម្បីវាក្លាយទីទាក់ទាញសម្រាប់ការសិក្សារបស់សិស្សទាំងអស់។

លទ្ធផលស្រាវជ្រាវបង្ហាញថា បញ្ហាប្រឈមខ្លាំងជាងគេ ក្នុងសាលារៀន គឺ ១.សាលាមានការខ្វះ និងលើសគ្រូបង្រៀនតាមឯកទេស ដែលការសិក្សានេះស្របគ្នាទៅនឹងការសិក្សា (សំណាង២០២០)លើបញ្ហាលើស និងខ្វះគ្រូតាមឯកទេសក្នុងខេត្តកណ្ដាល ដែលការលើស និងខ្វះគ្រូតាមទេសនេះបណ្ដាលមកពីលាសទើបបើកថ្មី លោកគ្រូ ឬអ្នកគ្រូផ្លាស់អង្គភាពតាមសហព័ន្ធ ឬតាមគ្រួសារ។២.ចំនួនសិស្សច្រើនពេកក្នុងថ្នាក់ បណ្ដាលឱ្យក្ដៅដែលបង្កការរំខានដល់ការសិក្សា ៣.គ្រូមកបង្រៀនមិនទៀងទាត់ (មកយឺតចេញមុន អវត្តមានច្រើនដង) ៤.ការអនុវត្តបទបញ្ជាផ្ទៃក្នុងសាលានៅមានកម្រិត ៤.សាលាមានក្មេងទំនើងដែលបន្តអនាធិបតេយ្យក្នុង និងក្រៅបរិវេណសាលាការរៀបចំក្ដារខៀនព័ត៌មាននៅក្នុងសាលារៀន។ បញ្ហានេះតម្រូវឱ្យ ក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាងសង់អាគារសិក្សាបន្ថែម គណៈគ្រប់គ្រងយកចិត្តទុកដាក់លើនិយ័ត្តភាពការងាររបស់បុគ្គលិក និងសុវត្ថិភាពរបស់លោកគ្រូ អ្នកគ្រូនិង សិស្សានុសិស្ស។

ការអនុវត្តលើការរៀបចំរដ្ឋបាលសាលា ក៏ជាចំណុចមួយដែលមានទាមទារឱ្យគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូទាំងអស់ក្នុងអង្គភាពសាមគ្គីគ្នា និងយកចិត្តទុកដាក់ខ្ពស់ជាប្រចាំ និងធ្វើការពិនិត្យតាមដានឱ្យបានល្អិតល្អន់។ របកគំហើញនេះស្របគ្នាទៅនិងការរកឃើញរបស់ STEPHEN B. LAWTON KENNETH A. LEITHWOOD (២០២២) ដែលធ្វើលើប្រធានបទ "ភាពគង់វង់របស់សិស្ស និងការផ្លាស់ប្តូរសាលារៀនរបស់សិស្ស" ។

លទ្ធផលនៃផ្នែកទី០៤ ត្រូវបានបង្ហាញដូចខាងក្រោម៖

**លទ្ធផលសំនួរសម្ភាសពីគណៈគ្រប់គ្រងសាលារៀនៈ**

តាមរយៈសំនួរសម្ភាសផ្ទាល់ពីគណៈគ្រប់គ្រងសាលារៀន បានបង្ហាញថា សាលារៀននៅមានបញ្ហាប្រឈមមួយចំនួនដូចជា៖ ១.មិនមានការសហការឱ្យបានពេញលេញរបស់បុគ្គលិកនៅក្នុងអង្គភាព ២. គ្រូមួយចំនួនមិនមានចំណេះដឹងលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា (ICT)

៣. កង្វះការចូលរួមពីសំណាក់មាតាបិតា ឬអាណាព្យាបាលសិស្ស ៤. ការបោះបង់ចោលការសិក្សាដោយសារកត្តាជីវភាព

**លទ្ធផលសំនួរសម្ភាសពីលោកគ្រូ អ្នកគ្រូៈ**

តាមរយៈសំនួរសម្ភាសផ្ទាល់ពីលោកគ្រូ អ្នកគ្រូ បានបង្ហាញថា ពួកគាត់ជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា៖ ១.ការអនុវត្តបទបញ្ជាផ្ទៃក្នុងនៅមានកម្រិត ២. សិស្សមិនប្រឹងប្រែងរៀនសូត្រទាំងក្នុងម៉ោងសិក្សា និងការស្វ័យសិក្សា ៣. សិស្សច្រើន ដោយមួយថ្នាក់មានសិស្សជាង ៥០នាក់ ពិសេសផ្នែកវិទ្យាសាស្ត្រសង្គម ៤.មាតាបិតា ឬអាណាព្យាបាលសិស្សមិនសូវសហការ និងទី៥. បញ្ហាជីវភាពរបស់លោកគ្រូ អ្នកគ្រូ

**លទ្ធផលសំនួរសម្ភាសពីសិស្សៈ**

តាមរយៈសំនួរសម្ភាសផ្ទាល់ពីសិស្សានុសិស្សបានបង្ហាញថា ពួកគេជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា៖ ១.ចំណាយច្រើនលើកាសិក្សា ២. ខ្វះសម្ភារៈនិងបន្ទប់ពិសោធ ៣. មានសិស្សទំនើងក្នុងសាលាបង្កឲ្យមានអំពើហិង្សារវាងសិស្សនិងសិស្ស និងទី៤. កង្វះបន្ទប់ទឹក និងកុំព្យូទ័រ

**លទ្ធផលសំនួរសម្ភាសពី មាតាបិតា ឬអាណាព្យាបាលសិស្ស**

តាមរយៈសំនួរបំពេញពីមាតាបិតា ឬអាណាព្យាបាលសិស្សបានបង្ហាញថា ពួកគាត់ជួបប្រទះបញ្ហាប្រឈមមួយចំនួនសម្រាប់ការសិក្សារបស់កូនដូចជា៖ ១.សាលាមិនបានឱ្យសៀវភៅតាមដាន ២.សិស្សច្រើនពេកក្នុងថ្នាក់និមួយៗ ៣.ចំណាយច្រើនលើសពីចំណូលលើការសិក្សារបស់កូន ៤. លេងទូរស័ព្ទច្រើនហើយហាមមិនស្តាប់ ៥. គ្រូមកបង្រៀនមិនទៀងទាត់។

# ជំពូកទី៥៖

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

ឆ្លងតាមរយៈលទ្ធផលសិក្សាស្រាវជ្រាវ និងការពិភាក្សាយ៉ាងល្អិតល្អន់ ពាក់ព័ន្ធនឹងកត្តាដែលនាំឱ្យមានតំថយសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ អ្នកស្រាវជ្រាវបានរកឃើញថា កម្រិតនៃការអនុវត្តទទួលលទ្ធផលខ្ពស់បង្គួរ និងបញ្ហាប្រឈម ស្ថិតក្នុងកម្រិតមធ្យម សម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍(សំណូមពរ)។

ការសិក្សាពីទស្សនៈ របស់គណៈគ្រប់គ្រងលើការថយចុះចំនួនសិស្សនៅកម្រិតទុតិយភូមិ មានគោលបំណងពីរសំខាន់គឺ ទី១- ) រកឱ្យឃើញនូវបញ្ហាប្រឈម និងកត្តាផ្សេងៗដែលធ្វើឱ្យចំនួនសិស្សកាន់តែថយចុះ និងទី(២) ឈ្វេងយល់ពីទស្សនៈភាគីពាក់ព័ន្ធចំពោះសាលារៀនដែលមានសិស្សកាន់តែថយចុះ និងសាលាដែលមានចំនួនសិស្សកើនឡើង។ ដោយការសិក្សាទាំងនេះមាន៥ចំណុចគោលធំៗដូចតទៅ៖ ផ្នែកទី I.ការរៀបចំបរិស្ថានសាលារៀន ផ្នែកទី II.ការគ្រប់គ្រងបុគ្គលិក ផ្នែកទីIII. ការគ្រប់គ្រងហិរញ្ញវត្ថុ ផ្នែកទី IV. ការគ្រប់គ្រងការរៀន និងបង្រៀន ផ្នែកទីV. ផ្នែកទីV. បញ្ហាប្រឈម។ សំណាកស្រាវជ្រាវដែលប្រើក្នុងការសិក្សាស្រាវជ្រាវនេះ គឺគណៈគ្រប់គ្រងសាលា គ្រូបង្រៀននៅកម្រិតវិទ្យាល័យ សិស្សានុសិស្សនៅកម្រិតវិទ្យាល័យ មាតាបិតាឬអាណាព្យាបាលសិស្ស ចំនួន២៤៨នាក់ ដែលជ្រើសរើសចេញពីសាលាចំនេះទូទៅសាធារណៈរបស់រដ្ឋកម្រិតទុតិយភូមិ ចំនួន០៦សាលាដែលស្ថិតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ក្នុងនោះមានវិទ្យាល័យវត្តកោះ ស្ថិតនៅខ័ណ្ឌដូនពេញ វិទ្យាល័យជាបឹងត្របែកស្ថិតនៅខ័ណ្ឌចំការមន វិទ្យាល័យបឹងកេងកង ស្ថិតនៅក្នុងខ័ណ្ឌបឹងកេងកង វិទ្យាល័យហ៊ុន សែនចាក់អង្រែស្ថិតនៅក្នុងខ័ណ្ឌមានជ័យ វិទ្យាល័យជាស៊ីមជ្រោយចង្វារស្ថិតនៅក្នុងខ័ណ្ឌជ្រោយចង្វារ វិទ្យាល័យបងទឹកស្ថិតនៅក្នុងខ័ណ្ឌដង្កោ។ ការជ្រើសរើសភាគសំណាកធ្វើឡើងដោយមិនចៃដន្យ តាមវិធីសាស្ត្រ Non-

Probability sampling ដោយយកមធ្យមសិក្សាទុតិយភូមិចំនួន ០៦សាលា ក្នុងចំណោម ៤១សាលា ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ស្ថិតិដែលប្រើក្នុងការប្រមូលទិន្នន័យ ជាកម្រងសំណួរដែលត្រូវបានបែងចែកជា៣ផ្នែកគឺ ផ្នែកទី១៖ ជាកម្រងសំណួរដែលពាក់ព័ន្ធទៅនឹងព័ត៌មានទូទៅរបស់ភាគសំណាក មាន ៧សំណួរដែលទាក់ទងទៅនឹងស្ថានភាពខ័ណ្ឌ បង្រៀនថ្នាក់ទី(១០-១២) ភេទ ស្ថានភាពគ្រួសារ អាយុ កម្រិតវប្បធម៌ និងបទពិសោធការងារ។ ផ្នែកទី២៖ ជាកម្រងសំណួរដែលពាក់ព័ន្ធ នឹងទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាដែលមានចំនួនសិស្សថយចុះ និងសាលាដែលមានចំនួនសិស្សកើនឡើង។ ផ្នែកទី៣៖ ជាកម្រងសំណួរ ដែលពាក់ព័ន្ធនឹងបញ្ហាប្រឈម និងកត្តាផ្សេងៗ និងផ្នែកទៅ៤៖ជាកម្រងសំនួរសម្ភាស។

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា ភាគីពាក់ព័ន្ធ(គណៈគ្រប់គ្រងសាលារៀនទាំង ៦ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាលមានទស្សនៈវិជ្ជមានលើចំណុចទាំង ៤ចំពោះសាលារៀន។ នេះសបញ្ជាក់ថា គ្រប់អង្គភាពទទួលបានជោគជ័យលើការអនុវត្តដែលបានដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡាពិតប្រាកដមែន ដើម្បីឆ្លើយតបទៅនឹងបរិបទនៃការអប់រំនៅលើពិភពលោក និងការរីកចម្រើននៃពិភពលោក ក៏ដូចជាកម្រិតនៃការអភិវឌ្ឍរបស់បណ្តាលប្រទេសមួយចំនួនក្នុងតំបន់ និងដើម្បីសម្រេចតាមទស្សនវិស័យ ចក្ខុវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្រសួងអប់រំ យុវជន និងកីឡា។

លទ្ធផលនៃការសិក្សាស្រាវជ្រាវ ពិតជាមានអត្ថន័យដែលអាចធ្វើឱ្យយើងដឹងពីចំណុចខ្លាំង និងចំណុចខ្វះខាតនៅតាមសាលាមធ្យមសិក្សាទុតិយភូមិលើផ្នែក៖ រៀបចំបរិស្ថាន គ្រប់គ្រងបុគ្គលិក គ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងការរៀន និងបង្រៀន និងបញ្ហាប្រឈមនានា ដែលអាចនាំទៅរកការពិភាក្សាពីដំណោះ

ស្រាយចំពោះបញ្ហាប្រឈមដែលមាននៅកម្រិតសាលារៀនដែលគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាលកំពុងជួបប្រទះ។

## ៥.២ អនុសាសន៍ និងសំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពី **ទស្សនៈរបស់ភាគីពាក់ព័ន្ធលើសាលាមធ្យមសិក្សាទុតិយភូមិដែលមានចំនួនសិស្សកាន់តែថយចុះ** ករណីសិក្សា៖ ក្នុងរាជធានីភ្នំពេញ’បានបង្ហាញ ពួកគាត់មានទស្សនៈប្រហាក់ប្រហែលគ្នាលើចំណុចទាំង ៥៖ ការរៀបចំបរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងការរៀន និងបង្រៀន និងទទួលបានលទ្ធផលក្នុងកម្រិតខ្ពស់ដោយ ការរៀបចំបរិស្ថាន (M: 3.76, SD: 0.97) ការគ្រប់គ្រងបុគ្គលិក (M:3.74, SD: 1.22) ការគ្រប់គ្រងការរៀន និងបង្រៀន (M: 3.62, SD: 1.00)។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានចំនុចខ្លះ ទទួលបានលទ្ធផលការយល់ស្រប ក្នុងកម្រិតមធ្យមដែរ នោះគឺការគ្រប់គ្រងហិរញ្ញវត្ថុ (M: 3.37, SD:1.26)។ ដូចនេះ អ្នកស្រាវជ្រាវ សូមសំណូមពរដល់ភាគីពាក់ព័ន្ធ នូវចំណុចមួយចំនួនដូចខាងក្រោម៖

### ក. កម្រិតក្រសួងអប់រំ យុវជន និងកីឡា

- ជួយសាងសង់អាគារសិក្សាបន្ថែម
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការគ្រប់គ្របស់គណៈគ្រប់គ្រងជាប់ជាប្រចាំ។
